មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

សៀវភៅមេរៀនស្តីពី

# និន្នាការភេទ និង អត្តសញ្ញាណយេនឌ័រ ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ



សម្រាប់អ្នកចូលរួម

ខែមករា ឆ្នាំ២០២២

ឧបត្ថម្ភដោយ
rfsu

## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (“ម.ស.ម.ក”) គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា។ ចក្ខុវិស័យរបស់ ម.ស.ម.ក គឺចង់ឃើញប្រទេសកម្ពុជាមានសន្តិភាពដែលពលរដ្ឋគ្រប់រូបអាចទទួលបានសិទ្ធិមនុស្សមូលដ្ឋានដែលខ្លួនមានពីកំណើត ទទួលបាននីតិរដ្ឋដោយគ្មាននិទណ្ឌភាព ទទួលបានការគោរពស្មើភាពគ្នាដោយគ្មានការរើសអើង ទទួលបានការពង្រឹងភាពអង់អាចក្លាហានដើម្បីចូលរួមយ៉ាងពេញលេញក្នុងដំណើរការលទ្ធិប្រជាធិបតេយ្យ ព្រមទាំងទទួលបានចំណែកនៃអត្ថប្រយោជន៍ពីការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពរបស់ប្រទេសកម្ពុជា។

## អំពីគម្រោងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ

សៀវភៅមេរៀននេះ គឺជាលទ្ធផលរបស់គម្រោងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ (“SOGIESC”) របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា។ គម្រោងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១០ ក្នុងគោលបំណងបង្កើនលទ្ធភាពទទួលបានព័ត៌មានអំពីសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា តាមរយៈការសិក្សាស្រាវជ្រាវអំពីស្ថានភាពរបស់អ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងព្រះរាជាណាចក្រកម្ពុជា និងផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងសិទ្ធិនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ ដល់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា សាធារណជនទូទៅ និងរាជរដ្ឋាភិបាល។ គម្រោងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ មានគោលបំណងផ្តល់ភាពអង់អាច និងពង្រីកសំឡេងរបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ក្នុងការតស៊ូមតិដើម្បីការផ្លាស់ប្តូរច្បាប់ និងគោលនយោបាយទាក់ទងនឹងសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នា នៅកម្រិតជាតិ ថ្នាក់តំបន់ និងអន្តរជាតិ។ គម្រោងនេះបានពិគ្រោះយោបល់ជាមួយបណ្តាញមូលដ្ឋានដែលជាដៃគូរួមមាន មូលនិធិឥន្ទធនូអន្តរជាតិ (MRI) ក្តីស្រឡាញ់គឺចម្រុះ (LoveIsDiversity) អង្គការអនាគតយុវជនកម្ពុជាអាស៊ាន (CamASEAN) និងអង្គការសហគមន៍ឥន្ទធនូកម្ពុជា (RoCK) ដើម្បីបង្កើនឥទ្ធិពលបន្ថែមទៀតក្នុងសហគមន៍ដែលបណ្តាញអង្គការដៃគូទាំងនេះធ្វើការ។

## សេចក្តីថ្លែងអំណរគុណ

សៀវភៅមេរៀននេះ ផលិតឡើងក្រោមការគាំទ្ររបស់សមាគមស៊ុយអែតសម្រាប់ការអប់រំផ្លូវភេទ (Riskförbundet för Sexuell Upplysning) (“RFSU”)។ ម.ស.ម.ក ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរ ចំពោះអង្គការដៃគូរបស់យើង ដែលបានចូលរួមផ្តល់ធាតុចូលដ៏មានតម្លៃក្នុងសៀវភៅមេរៀននេះ។ ខ្លឹមសារក្នុងសៀវភៅមេរៀននេះ គឺជាការទទួលខុសត្រូវរបស់ ម.ស.ម.ក ទាំងស្រុង។

## សំណួរ និងមតិយោបល់

ប្រសិនបើលោកអ្នកមានសំណួរ ឬត្រូវការព័ត៌មានបន្ថែមអំពីសៀវភៅមេរៀននេះ សូមផ្ញើអ៊ីម៉ែលមកកាន់ ម.ស.ម.ក info@cchrcambodia.org។

សៀវភៅមេរៀននេះ និងឯកសារបោះពុម្ពផ្សេងទៀតទាំងអស់របស់ ម.ស.ម.ក អាចរកមើលបាននៅលើគេហទំព័រដែលទទួលបានពានរង្វាន់ខាងផ្នែកសិទ្ធិមនុស្ស  តាមរយៈគេហទំព័រ www.sithi.org ដែលគ្រប់គ្រងដោយ ម.ស.ម.ក។


## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

ផ្ទះលេខ៧៩៨ ផ្លូវលេខ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ទូរស័ព្ទលេខ៖ +៨៥៥ (០) ២៣ ៧២ ៦៩ ០១

គេហទំព័រ៖ www.cchrcambodia.org

# មាតិកា


មេរៀនទី១៖ សេចក្តីណែនាំទូទៅអំពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ(SOGIESC)........................................................................................ /

មេរៀនទី២ ៖ ទិដ្ឋភាពទូទៅនៃប្រវត្តិរបស់អ្នកស្រឡាញ់ភេទដូចគ្នា (LGBTIQ+)................................ //

មេរៀនទី ៣ ៖  ច្បាប់សិទ្ធិមនុស្សអន្តរជាតិស្តីពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ ........................................................................................0.

មេរៀនទី៤៖ ទស្សនៈអន្តរជាតិលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ ........................................................................................ 11

មេរៀនទី៥៖ ក្របខ័ណ្ឌច្បាប់នៅប្រទេសកម្ពុជា ..........................................................22

មេរៀនទី៦៖ ទស្សនៈរបស់ពលរដ្ឋលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ ........................................................................................34

មេរៀនទី៧៖ ទ្រឹស្តីភាពប្រសព្វ........................................................................................ 51

មេរៀនទី៨៖ អំពើហិង្សាទាក់ទងនឹងផ្លូវភេទ និងយេនឌ័រ ............................................................ 56

មេរៀនទី៩៖ ការក្លាយជាអ្នកគាំទ្រ និងជំហានឆ្ពោះទៅរកសមភាព ..................................................65

# សៀវភៅមេរៀនសម្រាប់អ្នកចូលរួម

## ស្តីពី

## និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ

## និងលក្ខណៈភេទ

សៀវភៅមេរៀននេះ មានគោលបំណងផ្តល់ជូនអ្នកអានឱ្យយល់ដឹងកាន់តែច្បាស់អំពីស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ អន្តរភេទ និងអ្នកដែលមិនកំណត់យេនឌ័រខ្លួនឯង (សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា) ព្រមទាំងភាពចម្រុះនៃលក្ខណៈភេទ រួមមាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ តាមរយៈមេរៀនទាំង៩ នៅក្នុងសៀវភៅមេរៀននេះ។

មេរៀនទី១ នឹងមានបង្ហាញអំពីវាក្យសព្ទ និងនិយមន័យសំខាន់ៗនៃនិន្នាការភេទ និងអត្តសញ្ញាណរបស់អ្នកស្រឡាញ់ភេទដូចគ្នា ព្រមទាំងបទបញ្ញត្តិផ្សេងៗដែលពិពណ៌នាអំពីបទដ្ឋាន និងការយល់ឃើញរបស់សង្គមដែលបង្កផលប៉ះពាល់អវិជ្ជមានដល់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា។ មេរៀននេះក៏បានចងក្រងអំពីឫសគល់ពីប្រវត្តិសាស្ត្រ និងឥទ្ធិពលបច្ចុប្បន្ននៃការយល់ឃើញរបស់ប្រជាពលរដ្ឋកម្ពុជាទៅលើយេនឌ័រ និងបទដ្ឋានយេនឌ័រនៅក្នុងភាសាខ្មែរដែលបានកំណត់ប្រភេទ និងនិយមន័យនៃពាក្យយេនឌ័រ ភេទ និងអាកប្បកិរិយាផ្លូវភេទ មានភាពច្បាស់លាស់ជាងបណ្តាប្រទេសលោកខាងលិច។

មេរៀនទី២ នឹងបង្ហាញពីប្រវត្តិសង្ខេបនៃសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាទូទាំងពិភពលោកដោយគ្របដណ្តប់ប្រវត្តិនៃវត្តមានអ្នកស្រឡាញ់ភេទដូចគ្នា រួមមានប្រវត្តិនៃវត្តមានជំយូរអង្វែងនៃមនុស្សស្រឡាញ់ភេទដូចគ្នា និងការធ្វើទុក្ខបុកម្នេញមកលើពួកគាត់ ចលនាទាមទារសិទ្ធិពលរដ្ឋនៅសតវត្សរ៍ទី២០ និងចលនាទាមទារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នាសម័យទំនើប ក៏ដូចជាផលប៉ះពាល់នៃការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ មកលើសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា។ ប្រវត្តិនៃសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសកម្ពុជាក៏ត្រូវបានចងក្រងឡើងផងដែរ រួមមានទិដ្ឋភាពទូទៅនៃស្ថានភាពអ្នកស្រឡាញ់ភេទដូចគ្នាក្នុងសម័យកាលខុសៗគ្នានៃប្រវត្តិសាស្ត្រប្រទេសកម្ពុជា ដូចជា សម័យអង្គរ ការបង្រៀនបែបព្រះពុទ្ធសាសនា របបខ្មែរក្រហម និងសតវត្សរ៍ទី២១ ជាដើម។

លើសពីនេះទៅទៀត មេរៀនទី៣ នៃសៀវភៅមេរៀននេះ កំណត់នូវប្រភព និងស្តង់ដារសំខាន់ៗនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិស្តីពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ និងផ្តល់នូវការពិពណ៌នាអំពីសិទ្ធិនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ ដូចជាសិទ្ធិក្នុងការរៀបអាពាហ៍ពិពាហ៍ដោយស្មើភាព សិទ្ធិក្នុងការទទួលស្គាល់យេនឌ័រដោយស្របច្បាប់។

មេរៀនទី៤ នឹងលើកឡើងអំពីទស្សនៈអន្តរជាតិស្តីពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ ដោយបង្ហាញពីបណ្តាប្រទេសនៅទូទាំងពិភពលោកដែលដាក់ទណ្ឌកម្មលើអ្នកស្រឡាញ់ភេទដូចគ្នា ព្រមទាំងបណ្តាប្រទេសទទួលស្គាល់ និងការពារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នាផងដែរ។

មេរៀនទី៥ នៃសៀវភៅមេរៀននេះក៏បញ្ជាក់អំពីក្របខ័ណ្ឌច្បាប់កម្ពុជាស្តីពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ និងទម្រង់នៃការរើសអើងតាមផ្លូវច្បាប់ផ្សេងៗដែលអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាជួបប្រទះ ភាពខ្វះចន្លោះនៃច្បាប់បច្ចុប្បន្ន គោលនយោបាយ និងកម្មវិធីផ្សេងៗក្នុងគោលបំណងលើកស្ទួយសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា។

សៀវភៅមេរៀននេះក៏និយាយអំពីទស្សនៈនៃការយល់ឃើញអំពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ នៅក្នុងសង្គមកម្ពុជានៅក្នុង*មេរៀនទី៦* ទ្រឹស្តីភាពប្រសព្វនៅក្នុង*មេរៀនទី៧* និងបញ្ហានៃអំពើហិង្សាទាក់ទងនឹងផ្លូវភេទ និងយេនឌ័រ ដែលសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាតែងតែជួបប្រទះនៅក្នុងប្រទេសកម្ពុជានៅក្នុង*មេរៀនទី៨*។ មេរៀនចុងក្រោយ (មេរៀនទី៩) គឺនិយាយអំពីវិធីនៃសកម្មភាពដើម្បីក្លាយជាសម្ព័ន្ធអ្នកគាំទ្រអ្នកស្រឡាញ់ភេទដូចគ្នា និងរួមចំណែកធ្វើឱ្យមានសមភាពយេនឌ័រជាមួយនឹងការផ្តល់ជូននូវឧបករណ៍គន្លឹះដែលអាចជួយលើកកម្ពស់សំឡេងរបស់អ្នកស្រឡាញ់ភេទដូចគ្នា និងបង្ហាញសារគាំទ្រសម្រាប់សង្គមមួយដែលពោរពេញដោយការស្វាគមន៍ និងបរិយាប័ន្ន។

**“ប្រើសំឡេងរបស់អ្នកដើម្បីតស៊ូមតិសម្រាប់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា។”**

# មេរៀនទី ១៖ សេចក្តីណែនាំទូទៅអំពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ

នៅក្នុងមេរៀននេះនឹងពិភាក្សាអំពីនិយមន័យ និងពាក្យគន្លឹះសំខាន់ៗ ដើម្បីជួយឱ្យអ្នកអានកាន់តែងាយយល់អំពីអត្ថន័យនៃពាក្យដែលប្រើប្រាស់ក្នុងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាដូចជាពាក្យ ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ អន្តរភេទ និងអ្នកដែលមិនកំណត់យេនឌ័រខ្លួនឯង (“អ្នកស្រឡាញ់ភេទដូចគ្នា”) ព្រមទាំងដើម្បីងាយយល់អំពីភាពចម្រុះនៃនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ /ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទផងដែរ។ សូមបញ្ជាក់ផងដែរថា ទោះបីជាភាសា និងពាក្យគន្លឹះដែលបានប្រើប្រាស់ក្នុងមេរៀននេះ ជួយពន្យល់ឱ្យបានយល់ដឹងអំពីការយល់ឃើញលើពាក្យយេនឌ័រ និងពាក្យភេទនៅប្រទេសកម្ពុជា និងមជ្ឈដ្ឋានផ្សេងៗទៀតក្តី ក៏បុគ្គលិកលក្ខណៈ និងចំណង់ចំណូលចិត្តរបស់បុគ្គលម្នាក់ៗមានលក្ខណៈពិសេសរៀងៗខ្លួន គឺមិនដូចគ្នាទេ ហើយខ្លះទៀតក៏ប្រហែលជាមិនស្ថិតក្នុងការចាត់ចំណាត់ថ្នាក់ដែលមានលក្ខណៈទូលំទូលាយទាំងនេះទៀតផង។

## ១.១ គោលគំនិតនៃយេនឌ័រ

**ភេទ**

សំដៅទៅលើលក្ខណៈជីវសាស្ត្រ និងរាងកាយដែលកំណត់ ប្រុស និងស្រី តាមរយៈក្រូម៉ូសូម អ័រម៉ូនភេទ សរីរាង្គភេទ និងសរីរាង្គបន្តពូជខាងក្នុង និងខាងក្រៅ។ នេះគឺជាការសម្គាល់មួយដែលវេជ្ជបណ្ឌិតបានកំណត់ជាធម្មតាថាជាភេទប្រុស ឬភេទស្រី។

**យេនឌ័រ**

សំដៅទៅលើសកម្មភាព ឥរិយាបទ តួនាទីដែលបានបង្កើតឡើងផ្សារភ្ជាប់ទៅនឹងសង្គម និងជាគុណតម្លៃដែលសង្គមចាត់ទុកថាមានភាពសមស្របសម្រាប់បុរស និងស្ត្រី។ យេនឌ័រមិនជាប់ទាក់ទងនឹងសរីរវិទ្យា ឬជីវវិទ្យាទេ ប៉ុន្តែទាក់ទងនឹងឋានៈ ផ្លូវច្បាប់ និងសង្គម ព្រមទាំងការរំពឹងទុកពីសង្គមចំពោះអាកប្បកិរិយា ចរិតលក្ខណៈ និងគំនិត។ សង្គម និងវប្បធម៌នីមួយៗមានបទដ្ឋានអំពីរបៀបដែលមនុស្សគួរប្រព្រឹត្តិ ដោយផ្អែកលើភេទរបស់ពួកគេ ដែលនេះបង្កើតទៅជាគោលគំនិតដែលសង្គមកំណត់ភាពជាបុរស ឬស្ត្រី។

**បទដ្ឋានយេនឌ័រ**

គឺជាការកំណត់តាមរយៈវប្បធម៌ទៅលើតួនាទី ទំនួលខុសត្រូវ សិទ្ធិ ការផ្តល់សិទ្ធិ និងកាតព្វកិច្ចដែលផ្សារភ្ជាប់ទៅនឹងភាពជាបុរស ឬស្ត្រីព្រមទាំងទំនាក់ទំនងនៃអំណាចរវាងស្ត្រី បុរស ក្មេងប្រុស និងក្មេងស្រីផងដែរ។ បទដ្ឋានយេនឌ័រក៏កំណត់អំពីតួនាទី និងអាកប្បកិរិយារបស់យើងក្នុងទំនាក់ទំនងផ្លូវភេទផងដែរ។

### យេនឌ័រផ្សារភ្ជាប់ទៅនឹងអំណាច ហើយបទដ្ឋានយេនឌ័រដែលបង្កឱ្យមានអតុល្យភាពអំណាចក្នុងសង្គម៖

ទោះបីជាបទដ្ឋានយេនឌ័រកំណត់តួនាទីមនុស្សគ្រប់រូបក្នុងសង្គមក្តី ក៏ក្នុងពេលជំណាលគ្នានេះ បទដ្ឋានយេនឌ័រគាំទ្រនឹងជួយពង្រឹងឱ្យមានវិសមភាព និងអតុល្យភាពអំណាចផងដែរ។ ឧទាហរណ៍ដូចជា ការទូទាត់ប្រាក់កម្រៃជូនស្ត្រី និងបុរស ឬក៏ច្បាប់ទាក់ទងនឹងការបែងចែកមរតកមិនស្មើភាពគ្នារវាងបុរស និងស្ត្រីជាដើម។ តាមទំនៀមទម្លាប់ពីបុរាណកាលមក បុរស និងវត្ថុ/រឿងរ៉ាវដែលជាប់ទាក់ទងនឹងភាពជាបុរស គឺត្រូវបានគេផ្តល់តម្លៃខ្ពស់ជាងស្ត្រី ហើយវត្ថុ/រឿងរ៉ាវដែលជាប់ទាក់ទងនឹងភាពជាស្ត្រី បង្កើតនូវភាពមិនស្មើគ្នា និងការបែងចែកឋានានុក្រម។ សូមមើលឧទាហរណ៍ខាងក្រោមនេះជុំវិញការផ្តល់គុណតម្លៃ/គុណភាពរបស់សង្គមទៅលើភាពជាបុរស និងភាពជាស្ត្រីដែលបង្ហាញពីបទដ្ឋានដែលមានលក្ខណៈរើសអើងលើយេនឌ័រ។

| ភាពជាបុរស | ភាពជាស្ត្រី |
|---|---|
| ស្វាហាប់ | ខ្មាសអៀន |
| មោះមុត | ទុយមុយ |
| រឹងប៉ឹង | ទន់ខ្សោយ |
| ក្លាហាន | ប្រកាន់ច្រើន |

Q តើអ្នកអាចគិតអំពីលក្ខណៈសម្បត្តិផ្សេងទៀតនៃភាពជាបុរស ឬស្ត្រី បានដែរ ឬទេ?

## ១.២. និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ[1]

**អត្តសញ្ញាណយេនឌ័រ៖** សំដៅទៅលើអារម្មណ៍ខាងក្នុងរបស់បុគ្គលណាម្នាក់ និងបទពិសោធផ្ទាល់ផ្នែកយេនឌ័ររបស់គេ ដែលអាច ឬមិនអាចស្របទៅតាមភេទពីកំណើតរបស់បុគ្គលនោះ។

**ការបង្ហាញទំនោរយេនឌ័រ៖** សំដៅលើការបង្ហាញទំនោរយេនឌ័ររបស់បុគ្គលណាម្នាក់។ នេះអាចរាប់បញ្ចូលទាំងឥរិយាបថ និងឫកពាខាងក្រៅ ដូចជា តាមរយៈសម្លៀកបំពាក់ សក់ ការតុបតែងខ្លួន ការសម្តែងកាយវិការ ការនិយាយ ការដាក់ឈ្មោះ និងការបញ្ចេញសំឡេង។




**និន្នាការភេទ៖** សំដៅលើអារម្មណ៍ស្រឡាញ់ មនោសញ្ចេតនា ឬចំណង់ផ្លូវភេទ ទំនាក់ទំនងផ្លូវភេទចំពោះបុគ្គលម្នាក់ទៅលើបុគ្គលម្នាក់ផ្សេងទៀត ដែលអាចមានភេទដូចគ្នា ផ្ទុយគ្នា ឬទាំងពីរភេទ។

**លក្ខណៈភេទ៖** សំដៅទៅលើលក្ខណៈជីវសាស្ត្រ និងរាងកាយដែលកំណត់បុរស និងស្ត្រីតាមរយៈក្រូម៉ូសូម អ័រម៉ូនភេទ សរីរាង្គភេទ និងសេរីរាង្គបន្តពូជខាងក្នុង និងខាងក្រៅ។ នេះជាការសម្គាល់មួយដែលត្រូវបានកំណត់ដោយវេជ្ជបណ្ឌិតថាជាមនុស្សប្រុស ឬស្រី។

ប្រភព៖គម្រោងគោលនយោបាយសុខភាព “មេរៀនទី២៖ភាពចម្រុះនៃយេនឌ័រ និងភេទ៖ ផ្នត់គំនិត និងពាក្យគន្លឹះ” <http://www.healthpolicyproject.com/index.cfm?ID=GSDTrainingM2>.

[1] ឯកសារយោងផ្សេងទៀត៖
សហគមន៍ឥន្ទធនូកម្ពុជា “កំប៉ុងសូដា” <https://www.facebook.com/watch/?v=1677762915598451>.
សហគមន៍ឥន្ទធនូកម្ពុជា ‘SOGIE animation – KCD’ <https://www.youtube.com/watch?v=19r4uvLoSqQ&feature=emb_logo>.

## ១.៣ ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ អន្តរភេទ និងអ្នកដែលមិនកំណត់យេនឌ័រខ្លួនឯង (LGBTIQ)

និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ គឺសំដៅដល់ស្ថានភាព ប៉ុន្តែអ្នកស្រឡាញ់ភេទដូចគ្នាជាការសម្គាល់លើអត្តសញ្ញាណបុគ្គលម្នាក់ៗ។ មនុស្សមួយចំនួនប្រហែលមិនកំណត់អត្តសញ្ញាណរបស់ខ្លួន ដូចនេះជាការសំខាន់ណាស់ដែលយើងត្រូវគោរពអត្តសញ្ញាណផ្ទាល់ខ្លួនរបស់មនុស្សម្នាក់ៗ និងចៀសវាងការអនុវត្តបទដ្ឋានសង្គម ឬផ្ទត់គំនិតរើសអើងទៅលើបុគ្គលនោះ។



**ស្ត្រីស្រឡាញ់ស្ត្រី (Lesbian)**៖ មនុស្សដែលកំណត់អត្តសញ្ញាណខ្លួនឯងជាស្ត្រីហើយមានអារម្មណ៍នៃក្តីស្រឡាញ់ទៅលើអ្នកដែលមានអត្តសញ្ញាណជាមនុស្សស្រីដូចគ្នា។



**បុរសស្រឡាញ់បុរស (Gay)៖** មនុស្សដែលកំណត់អត្តសញ្ញាណខ្លួនឯងជាបុរសហើយមានអារម្មណ៍នៃក្តីស្រឡាញ់ទៅលើអ្នកដែលមានអត្តសញ្ញាណជាបុរសដូចគ្នា។



**អ្នកស្រឡាញ់ទាំងពីរភេទ (Bisexual)៖** មនុស្សដែលអាចស្រឡាញ់ទាំងមនុស្សប្រុស និងមនុស្សស្រី។



**អ្នកប្តូរយេនឌ័រ (Transgender)៖** គឺសំដៅទៅលើមនុស្សដែលមានអារម្មណ៍ និងកំណត់អត្តសញ្ញាណយេនឌ័រផ្ទុយពីភេទកំណើតរបស់ខ្លួន។



**អន្តរភេទ ឬភេទមិនច្បាស់លាស់ (Intersex)៖** ជាពាក្យស្ថិតក្នុងជំពូកតែមួយសម្រាប់ហៅមនុស្សដែលកើតមកមានភេទខុសប្រក្រតី ឬមិនពេញលក្ខណៈ។ នេះទាក់ទងនឹងសរីរវិភាគផ្នែកប្រដាប់បន្តពូជ ឬប្រដាប់ភេទដែលស្ថិតក្នុងលក្ខណៈវិនិច្ឆ័យស្រពេចស្រពិលលើភេទប្រុស ឬភេទស្រី។



**អ្នកដែលមិនកំណត់យេនឌ័រខ្លួនឯង(Queer)**៖ ដើមឡើយពាក្យនេះត្រូវបានគេប្រើក្នុងន័យមាក់ងាយទៅលើក្រុមអ្នកស្រឡាញ់ភេទដូចគ្នា តែក្នុងពេលបច្ចុប្បន្នពាក្យនេះត្រូវបានគេប្រើដើម្បីពណ៌នាអំពីមនុស្សដែលមិនកំណត់យេនឌ័ររបស់ខ្លួនឯង។

## ១.៤. និយមន័យ និងការយល់ឃើញផ្សេងទៀត

មានការយល់ឃើញមួយចំនួនទៀតលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ តាមទស្សនៈផ្សេងៗគ្នា៖



**Cisgender (cis)**៖ បុគ្គលដែលមានអត្តសញ្ញាណយេនឌ័រ និងបង្ហាញយេនឌ័រ ស្របទៅតាមភេទដែលមានពីកំណើត។

**យេនឌ័រដែលពុំស្ថិតក្នុងចំណោមយេនឌ័រទាំងពីរ/យេនឌ័រដែលពុំស្របទៅនឹងយេនឌ័រពីកំណើត/យេនឌ័រដែលពុំមែនជាភេទប្រុស ឬស្រី ៖** បុគ្គលដែលមិនអនុលោមតាមអត្តសញ្ញាណយេនឌ័រនីមួយៗ ដូចជាយេនឌ័រជាប្រុស ឬស្រី ភាពជាបុរស ឬភាពជាស្ត្រី។ យេនឌ័រដែលពុំស្ថិតក្នុងចំណោមយេនឌ័រទាំងពីរ គឺយល់ថាយេនឌ័រគឺមានភាពទូលំទូលាយលើសពីពីរទៅវិញ។





**អ្នកស្រឡាញ់ភេទផ្ទុយគ្នា (Heterosexual/Straight)**៖ ការប្រតិព័ទ្ធស្នេហា ការទាក់ទាញអារម្មណ៍ផ្លូវភេទ ឬអាកប្បកិរិយាផ្លូវភេទ រវាងមនុស្សភេទផ្ទុយគ្នា ឬយេនឌ័រផ្ទុយគ្នា។

មានវាក្យសព្ទបច្ចេកទេសមួយចំនួនទៀតបកស្រាយមានលក្ខណៈស្មុគស្មាញ ទៅលើបទដ្ឋានសង្គម និងការយល់ឃើញដែលបង្កផលប៉ះពាល់អវិជ្ជមានដល់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាផងដែរ៖

| | |
|---|---|
| Toxic masculinity | ទំនៀមទម្លាប់ និងវប្បធម៌ដែលមានឥទ្ធិពលលើភាពជាបុរស ដែលអាចបង្កគ្រោះថ្នាក់ដល់បុរស ស្ត្រី និងសង្គមទាំងមូល។ |
| Heteronormativity | គំនិតដែលយល់ថា ការស្រឡាញ់ ឬទំនាក់ទំនងស្នេហាភេទផ្ទុយគ្នាគឺជាបទដ្ឋាន/ជាទម្រង់ដើមនៃទំនាក់ទំនងផ្លូវភេទ។ វាបានចាក់ឫសនៅក្នុងជំនឿថា ភេទ និងយេនឌ័រ គឺមានតែពីរ ហើយមិនអាចផ្លាស់ប្តូរបានទេ។ |
| Homophobia/Biphobia/ Transphobia | ឥរិយាបថ និងអារម្មណ៍អវិជ្ជមានចំពោះអ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរយេនឌ័រ ឬបុគ្គលណាម្នាក់ក្នុងចំណោមអ្នកស្រឡាញ់ភេទដូចគ្នា។ |

## ១.៥ ការពន្យល់ពាក្យ «និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ» តាមអត្ថន័យភាសាខ្មែរ

ការយល់ឃើញរបស់ពលរដ្ឋខ្មែរទៅលើពាក្យ យេនឌ័រ តាមរយៈភាសាខ្មែរដែលចាត់ថ្នាក់ និងឱ្យនិយមន័យទៅលើពាក្យយេនឌ័រ ភេទ និងអាកប្បកិរិយាផ្លូវភេទ មានលក្ខណៈងាយស្រួលជាងបណ្ដាប្រទេសលោកខាងលិច។ ពេលខ្លះពលរដ្ឋប្រើពាក្យថា "ភេទទីបី" ដែលជាពាក្យក្រៅផ្លូវការសម្រាប់ហៅក្រុមមនុស្សក្នុងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា។ **ភេទទីបី** អាចបែងចែកចេញជាពីរពាក្យគឺ "**ភេទ**" និង "**ទីបី**"។ ពាក្យ "**ភេទ**" ជាភាសាខ្មែរនិងតាមអត្ថន័យគឺសំដៅទៅលើយេនឌ័រ ឬភេទ ដែលបញ្ជាក់លក្ខណៈរបស់មនុស្សប្រុស ឬស្រី។ ពាក្យ "**ទីបី**" គឺតំណាងឱ្យចំនួនលេខបី។ យោងតាមអត្ថន័យភាសាខ្មែរពាក្យថា "**ភេទទីបី**" គឺស្មើនឹងពាក្យជាភាសាអង់គ្លេសហៅថា "**Third Gender**"។ បើទោះបីជាគ្មានឯកសារផ្លូវការណាមួយបកស្រាយអំពីពាក្យនេះក៏ដោយ ពាក្យ **ភេទទីបី** នេះ ត្រូវបានគេប្រើប្រាស់ក្រៅផ្លូវការនៅទូទាំងប្រទេសកម្ពុជា។ យ៉ាងនេះក្ដី ជារឿយៗពាក្យនេះត្រូវបានគេប្រើប្រាស់ក្នុងន័យរើសអើង។ ហេតុដូច្នេះគួរគប្បីប្រើពាក្យថា **អ្នកស្រឡាញ់ភេទដូចគ្នា** ជំនួសវិញ។

ភេទទីបី ✗ → អ្នកស្រឡាញ់ភេទដូចគ្នា ✓

### ១.៥.១ ការពន្យល់ពាក្យ «ភេទ ឬយេនឌ័រ» តាមអត្ថន័យភាសាខ្មែរ

| ប្រុស / បុរស | ស្រី / ស្ត្រី | ខ្ទើយ |
|---|---|---|
| មនុស្សដែលមានភេទប្រុស។<br>♂ | មនុស្សដែលមានភេទស្រី។<br>♀ | ពុំមែនប្រុស ពុំមែនស្រី ឬស្ទើរប្រុសស្ទើរស្រី៖ មនុស្សដែលមានប្រដាប់ភេទជាបុរសផង និងស្ត្រីផង ឬមនុស្សដែលបង្ហាញបុគ្គលិកលក្ខណៈឬអាកប្បកិរិយាផ្ទុយពីភេទកំណើតរបស់ខ្លួន។ |

ពាក្យ **ខ្ទើយ** ត្រូវបានគេប្រើសម្រាប់ពិពណ៌នាអំពី **ភេទទីបី** ក្នុងប្រទេសកម្ពុជា និងជារឿយៗគេប្រើសម្រាប់អ្នកប្ដូរយេនឌ័រពីបុរសទៅស្ត្រី ឬក៏បុរសដែលស្លៀកពាក់ជាមនុស្សស្រី។ ទោះបីជាពាក្យនេះ ត្រូវបានប្រើជាទូទៅ ក៏ប៉ុន្តែបច្ចុប្បន្ននេះ ពាក្យនោះត្រូវបានគេមើលឃើញថាជាពាក្យមាក់ងាយ ហើយប៉ះពាល់ដល់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាទាំងសុខភាពផ្លូវចិត្ត ផ្លូវកាយ និងអារម្មណ៍របស់ពួកគាត់ផងដែរ។ អ្នកស្រឡាញ់ភេទដូចគ្នាភាគច្រើនយល់ថាពាក្យនេះជាពាក្យប្រមាថ ជាពិសេសនៅពេលដែលប្រើដើម្បីពិពណ៌នាអំពីអ្នកប្ដូរយេនឌ័រ។[2]

---

[2] ម.ស.ម.ក "ការសិក្សាតាមដានអំពីអ្នកស្រឡាញ់ភេទដូចគ្នា នៅតាមសាលារៀនក្នុងប្រទេសកម្ពុជា" (ខែធ្នូ ឆ្នាំ២០១៥) <https://docs.google.com/viewerng/viewer?url=https://cchrcambodia.org/admin/media/report/report/english/2015_12_17_CCHR_REPORT_LGBT_Bullying_in_Cam_School_(ENG).pdf>.

ខ្ទើយ ❌ ➡ អ្នកប្តូរយេនឌ័រ ✅

### ១.៥.២ ការពន្យល់ពាក្យ «និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ» តាមអត្ថន័យភាសាខ្មែរ

ពុំមាននិយមន័យជាក់លាក់ណាមួយពន្យល់អំពីចំណង់ចំណូលចិត្តផ្លូវភេទនៅក្នុងប្រទេសកម្ពុជានោះទេ ដូច្នេះហើយពលរដ្ឋពន្យល់ ឬហៅនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រខុសៗគ្នាអាស្រ័យទៅតាមបុគ្គលិកលក្ខណៈ ឬចរិតលក្ខណៈ[3]។

| ខ្ទើយស្រី | ចរិតស្រី / ទន់ភ្លន់ | ចរិតប្រុស / រឹងប៉ឹង |
|---|---|---|
| បុគ្គលដែលកំណត់អត្តសញ្ញាណយេនឌ័ររបស់ខ្លួនជាស្ត្រី ហើយមានចិត្តប្រតិព័ទ្ធស្នេហាចំពោះមនុស្សស្រីដូចគ្នា។ | មានន័យថា *សុភាពរាបសា* ឬ *ស្រគត់ស្រគំ* និងសំដៅទៅលើការមានបុគ្គលិកលក្ខណៈរបស់មនុស្សស្រី។ | មានន័យថា *រឹងមាំ* ឬ *រឹងប៉ឹង* និងសំដៅទៅលើការមានចរិត ឬកពាជា «បុរសពេញលក្ខណៈ» ដែលត្រូវបានវប្បធម៌ កំណត់ថាជាបុគ្គលិកលក្ខណៈរបស់បុរស។ |

ចំណុចសំខាន់គឺផ្តោតទៅលើបុគ្គលិកលក្ខណៈ និងចរិតលក្ខណៈខាងក្រៅដែលអាចមើលឃើញរបស់បុគ្គលម្នាក់ៗ ដូច្នេះពលរដ្ឋជាច្រើនដែលស្រឡាញ់ភេទដូចគ្នា គឺគេមិនចាំបាច់កំណត់ខ្លួន ឬកំណត់សម្គាល់ខ្លួនពួកគេថាជាមនុស្សស្រឡាញ់ភេទដូច ឬផ្ទុយគ្នានោះទេ បើទោះបីជាពួកគេស្រឡាញ់ភេទដូចគ្នាក៏ដោយ។ ម៉្យាងវិញទៀត នៅពេលដែលពលរដ្ឋប្រើពាក្យថា “ខ្ទើយ” គឺពួកគេច្រើនតែសំដៅទៅលើមនុស្សប្រុសដែលស្លៀកពាក់និងតុបតែងខ្លួនជាមនុស្សស្រី ឬមនុស្សស្រីដែលមើលពីក្រៅទៅមានលក្ខណៈដូចជាមនុស្សប្រុស។

ខ្ទើយស្រី ❌ ➡ ស្ត្រីស្រឡាញ់ភេទដូចគ្នា ✅

### ១.៥.៣ ការសម្គាល់ចរិតលក្ខណៈបុរសស្រឡាញ់ភេទដូចគ្នា តាមអត្ថន័យភាសាខ្មែរ

| សក់ខ្លី | ស្រីស្រស់ | បុរសពិតប្រាកដ |
|---|---|---|
| “***សក់ខ្លី***” គឺសំដៅលើបុរសដែលស្លៀកពាក់ និងកំណត់ខ្លួនឯងជាមនុស្សប្រុស ប៉ុន្តែ អាចរួមភេទជាមួយបុរសផង និង | “***សក់វែង ឬស្រីស្រស់***” គឺសំដៅលើបុគ្គលប្តូរយេនឌ័រ ដែលពាក់សក់វែង ស្លៀកពាក់ និងបញ្ចេញអាកប្ប- | “បុរសពិត ឬភាពជាបុរស” |

[3] Roland Meyer, ‘Saramani: Danseuse Khmer’ (ឆ្នាំ១៩១៩), និង ម.ស.ម.ក “ចេញជាចំហនៅព្រះរាជាណាចក្រកម្ពុជា៖ ពលរដ្ឋខ្មែរដែលស្រលាញ់ភេទដូចគ្នា” (ខែធ្នូ ឆ្នាំ២០១០) <http://sogi.sithi.org/admin/upload/media/118-egkykni1336367358.pdf> p. 10-11.

| | | |
|---|---|---|
| ស្ត្រីផង។ ពួកគេប្រហែលជាបង្ហាញចរិតជាស្ត្រីច្រើនជាងចរិតជាបុរសជាធម្មតា ពួកគេប្រកាន់ឥរិយាបថចម្រុះក្នុងសង្គមច្រើនតែរៀបការហើយ ហើយប្រពន្ធរបស់ពួកគេភាគច្រើនមិនដឹងទេថាពួកគេមានចំណង់ចំណូលចិត្តរួមភេទជាមួយនឹងបុរសដូចគ្នាទេ។ | កិរិយាជាមនុស្សស្រី។ ពួកគេមួយចំនួនក៏អាចប្រើប្រាស់អ័រម៉ូនផ្លាស់ប្តូររាងកាយទៅជាស្រី ហើយប្រសិនបើពួកគេមានលទ្ធភាព ពួកគេនឹងធ្វើការវះកាត់ប្តូរភេទផងដែរ។ ពួកគេគឺកំណត់ខ្លួនឯងជាស្ត្រី ហើយពួកគេស្រឡាញ់មនុស្សប្រុស។ | |

| | | | | |
|---|---|---|---|---|
| សក់ខ្ចី | ☒ | → | អ្នកស្រឡាញ់ទាំងពីរភេទ | ✓ |
| ស្រីស្រស់ | ☒ | → | អ្នកប្តូរយេនឌ័រជាស្ត្រី | ✓ |

# មេរៀនទី ២ ៖ ទិដ្ឋភាពទូទៅនៃប្រវត្តិរបស់អ្នកស្រឡាញ់ភេទដូចគ្នា (LGBTIQ+)

## ២.១ ទិដ្ឋភាពទូទៅនៃប្រវត្តិសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅលើពិភពលោក

ប្រទេសនីមួយៗមានប្រវត្តិសាស្ត្រ និងសាវតាររៀងៗខ្លួន ព្រមទាំងមានការប្រតិបត្តិទៅលើសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ខុសៗគ្នាពីសង្គមមួយទៅសង្គមមួយ។ ទោះបីយ៉ាងណាក្តី និន្នាការអន្តរជាតិមួយចំនួន និងចលនាជាសកលរបស់អ្នកស្រឡាញ់ភេទដូចគ្នាបានជះឥទ្ធិពលដល់អ្នកស្រឡាញ់ភេទដូចគ្នានៅទូទាំងពិភពលោក។

### ២.១.១ វត្តមានអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រវត្តិសាស្ត្រ

សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាបានកើតឡើងតាំងពីមានវត្តមាននៃមនុស្សជាតិមកម្ល៉េះ។ ទោះបីជាមានការយល់ច្រឡំជាច្រើនថា និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ គឺជាជម្រើស ឬជាចំណង់ចំណូលចិត្តយ៉ាងណាក្តី ក៏ប៉ុន្តែភាពខុសគ្នាផ្នែកយេនឌ័រ ចំណង់ចំណូលចិត្តផ្នែកផ្លូវភេទ និងសេចក្តីប្រាថ្នាក្នុងការរួមបវេណីភេទដូចគ្នាកើតមានក្នុងចំណោមមនុស្សគ្រប់សម័យកាលនៅទូទាំងពិភពលោក។ ឯកសារ និងភ័ស្តុតាងបានបង្ហាញសាវតារនៃសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ដូចជាការប្រតិព័ទ្ធស្នេហា អត្តសញ្ញាណ

**ពាក្យគន្លឹះសំខាន់ៗសម្រាប់មេរៀនទី ២**

- **អ្នកស្រឡាញ់ភេទដូចគ្នា (LGBTIQ+)៖** ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ អន្តរភេទ និងអ្នកដែលមិនកំណត់យេនឌ័ររបស់ខ្លួន។
- **សូជី (SOGIESC)៖** និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ។
- **ការស្អប់ខ្ពើមអ្នកស្រឡាញ់ភេទដូចគ្នា៖** ឥរិយាបថ និងអារម្មណ៍អវិជ្ជមានចំពោះការស្រឡាញ់ភេទដូចគ្នា ឬមនុស្សដែលបង្ហាញអត្តសញ្ញាណ ឬត្រូវបានគេយល់ថាជាមនុស្សស្រឡាញ់ភេទដូចគ្នា។
- **ការកំណត់ជាបទល្មើសព្រហ្មទណ្ឌ៖** ជាទង្វើដែលកំណត់ឥរិយាបថណាមួយទៅជាបទល្មើស ឬបុគ្គលណាម្នាក់ទៅជាជនមានកំហុសតាមរយៈការដាក់ទណ្ឌកម្ម ឬពិន័យ។
- **ការសន្មតភាពខុសច្បាប់៖** ធ្វើឱ្យអ្វីមួយខុសច្បាប់ ឬធ្វើឱ្យសកម្មភាពផ្ទុយពីបទបញ្ញត្តិអ្វីមួយ។
- **ចលនាទាមទារសិទ្ធិ៖** សកម្មភាព និងព្រឹត្តិការណ៍ជាបន្តបន្ទាប់បង្កើតដោយមនុស្សមួយក្រុមដែលស្ថិតក្នុងរយៈពេលណាមួយដើម្បីស្វែងរកការផ្លាស់ប្តូរគោលការណ៍ ឬគោលនយោបាយមួយចំនួន។
- **វីរុសហ៊ីវ៖** គឺជាវីរុសដែលបំផ្លាញប្រព័ន្ធភាពស៊ាំរបស់មនុស្សដែលធ្វើឱ្យប្រព័ន្ធភាពស៊ាំលំបាកក្នុងការប្រឆាំងនឹងការឆ្លងមេរោគផ្សេងៗ។
- **ជំងឺអេដស៍៖** គឺបណ្តាលមកពីមេរោគអេដស៍។
- **បុរសដែលរួមភេទជាមួយបុរស៖** គឺជាពាក្យដែលត្រូវបានប្រើក្នុងបរិបទសុខភាពដើម្បីចៀសវាងការមាក់ងាយដែលបង្កប់ក្នុងសង្គម។ ពាក្យនេះមិនចាំបាច់មានន័យថាបុរសទាំងនេះកំណត់ខ្លួនឯងថាជាបុរសស្រឡាញ់បុរសនោះទេ។
- **ឧភតោភេទ (អន្តរភេទ)៖** បុគ្គលដែលមានលក្ខណៈភេទប្រែប្រួលដោយសារសរីរាង្គបន្តពូជមានទាំងភេទប្រុសនិងភេទស្រី។

របស់អ្នកប្តូរយេនឌ័រថាមានអាយុកាល យ៉ាងហោចណាស់ ២៥០០ ឆ្នាំមកហើយ[4]។

## ២.១.២ ការរើសអើង និងការធ្វើទុក្ខបុកម្នេញលើអ្នកស្រឡាញ់ភេទដូចគ្នា

ការរើសអើងលើអ្នកស្រឡាញ់ភេទដូចគ្នាដែលបានចាប់ផ្តើមឡើងតាំងពីសតវត្សរ៍ទី១៥ និងទី១៦ មកនោះ ត្រូវបានគេជឿថាចេញមកពីសាសនាដែលថ្កោលទោសចំពោះការប្រតិព័ទ្ធភេទដូចគ្នា។ បន្ទាប់មកការស្រឡាញ់ភេទដូចគ្នាត្រូវបានចាត់ទុកជាទង្វើខុសច្បាប់ដោយសារថា និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័ររបស់ក្រុមអ្នកស្រឡាញ់ភេទដូចគ្នាត្រូវបានកំណត់ជាបទល្មើសព្រហ្មទណ្ឌនៅក្នុងច្បាប់ជាតិដែលត្រូវទទួលរងទណ្ឌកម្មតាមផ្លូវច្បាប់ដោយសារពួកគេជាអ្នកស្រឡាញ់ភេទដូចគ្នានៅទូទាំងពិភពលោក។ ការកំណត់ទោសទៅលើសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា រួមមាន ការកាត់ទោសប្រហារជីវិត និងការដាក់ពន្ធនាគារអស់មួយជីវិត។ ការដាក់ទណ្ឌកម្មនានាតាមផ្លូវច្បាប់លើការស្រឡាញ់ភេទដូចគ្នា ឬអាកប្បកិរិយារបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាមានលក្ខណៈខុសៗគ្នានៅតាមប្រទេសនានា ហើយវិសាលភាពនិងការអនុវត្តទោសនៃបណ្តាប្រទេសទាំងនោះក៏ខុសៗគ្នាផងដែរ។

**ការសន្មតភាពមិនស្របច្បាប់៖**

រដ្ឋចាត់ទុកឥរិយាបថទាំងនេះថាខុសច្បាប់៖

- ការបង្ហាញទំនោរយេនឌ័រក្នុងទម្រង់ផ្សេងៗ
- ការប្រតិព័ទ្ធ ឬទំនាក់ទំនងស្នេហាភេទដូចគ្នា

*ករណីសិក្សា៖ នៅក្នុងប្រទេសស្រីលង្កា ទំនាក់ទំនងស្នេហាភេទដូចគ្នាគឺខុសច្បាប់។ ប៉ុន្តែ ច្បាប់នេះមិនត្រូវបានតុលាការកំពូលអនុវត្តឡើយ ដូច្នេះហើយពុំមានការកំណត់ជាទោសទណ្ឌនោះទេ តែក៏ពុំមានភាពស្របច្បាប់ដែរ។*

**និង**

**ការកំណត់ជាបទល្មើសព្រហ្មទណ្ឌ ៖**

រដ្ឋដាក់ទោសពន្ធនាគារ ឬពិន័យជាប្រាក់៖

- ការស្លៀកពាក់ សកម្មភាព ឬការបង្ហាញដែលផ្ទុយនឹងភេទ
- ការសេពសន្ថវៈដោយមានការព្រមព្រៀងជាមួយបុគ្គលដែលមានភេទដូចគ្នា។

*ករណីសិក្សា៖ នៅក្នុងប្រទេសប្រ៊ុយណេ ការរួមភេទជាមួយមនុស្សភេទដូចគ្នា គឺត្រូវទទួលការផ្តន្ទាទោសដោយគប់ដុំថ្មសម្លាប់។*

ជាច្រើនទសវត្សរ៍មកហើយដែលក្រុមអ្នកស្រឡាញ់ភេទដូចគ្នារងការធ្វើទុក្ខបុកម្នេញ ហើយជាញឹកញាប់ប្រឈមនឹងការវះកាត់ចងបំពង់បង្ករមេជីវិតឈ្មោល ការក្រៀវ ឬការព្យាបាលដើម្បីឱ្យផ្លាស់ប្តូរអារម្មណ៍។ ក្រៅពីវិធីសាស្ត្រដ៏គ្រោះថ្នាក់និងតក់ស្លុតទាំងនេះ អ្នកស្រឡាញ់ភេទដូចគ្នាជាច្រើនបានផ្លាស់ប្តូរអាកប្បកិរិយារបស់ខ្លួនដើម្បីស្របទៅតាមសង្គម ដែលនេះធ្វើឱ្យមានការកើនឡើងខ្ពស់នៃអត្រាធ្វើអត្តឃាត ការប្រើប្រាស់គ្រឿងញៀន និងភាពគ្មានផ្ទះសម្បែង។

[4] Andrew Dobbin, អ្នកស្រលាញ់ភេទដូចគ្នាមានតាំងពីមុនឆ្នាំ១៩៦៧ – ដូចដែលសារមន្ទីរអង់គ្លេសបង្ហាញ, (*The Guardian*, ថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០១៣ ) < https://www.theguardian.com/commentisfree/2013/jun/20/lbgt-people-1967-british-museum>. សូមមើល, ប្រវត្តិនៃសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា - ជារៀងរាល់ឆ្នាំ( ១៧៩០- បច្ចុប្បន្ន ) <https://www.youtube.com/watch?v=4YFJcwolFRA>.

## ២.១.៣ ចលនាទាមទារសិទ្ធិពលរដ្ឋនៅសតវត្សរ៍ទី ២០

នៅសតវត្សរ៍ទី២០ ការរីកវិវឌ្ឍបានចាប់ផ្ដើមកើតមានតាមរយៈការផុសឡើងនូវចលនាទាមទារសិទ្ធិពលរដ្ឋ។ ចលនាទាមទារសិទ្ធិពលរដ្ឋនៅក្នុងឆ្នាំ១៩៥០ និងឆ្នាំ១៩៦០ បានផ្ដើមចេញជាចលនាមួយទាមទារសមភាពជាតិសាសន៍នៅសហរដ្ឋអាមេរិក។ ចលនាទាមទារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នាក៏បានលេចចេញជាផ្នែកមួយនៃចលនាទាមទារសិទ្ធិពលរដ្ឋ សមភាព និងយុត្តិធម៌សង្គម។ អ្នកប្ដូរយេនឌ័រជាស្ត្រីជនជាតិស្បែកខ្មៅបានឈានមុខគេក្នុងចលនាទាមទារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នានេះ។ ការបង្ក្រាបរបស់នគរបាលទៅលើក្លឹបកំសាន្តរបស់អ្នកស្រឡាញ់ភេទដូចគ្នា គឺជារឿងធម្មតានៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ហើយជាលទ្ធផល អ្នកស្រឡាញ់ភេទដូចគ្នាជាច្រើនត្រូវបានចាប់ខ្លួន។ ការបង្ក្រាបទាំងនេះបានបង្កឱ្យមានជម្លោះហិង្សារវាងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា និងកងកម្លាំងនគរបាល។



Marsha P Johnson *និង* Sylvia Rivera *ដើរក្បួនដើម្បីសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នានៅទីក្រុងញូវយ៉ក*, Netflix ។

នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៦៩ នគរបាលបានចូលបង្ក្រាបក្លឹបកំសាន្តដ៏ពេញនិយមមួយឈ្មោះ **ស្តូនវ៉ូល អ៊ិន (Stonewall Inn)** ស្ថិតនៅទីក្រុងញូវយ៉កជាទីដែលអ្នកស្រឡាញ់ភេទដូចគ្នាតែងតែទៅកំសាន្ត។ ដោយធុញទ្រាន់នឹងការយាយីរបស់នគរបាលឥតឈប់ឈរ ព្រមទាំងទទួលការរើសអើងពីសង្គមផងនោះ ទាំងភ្ញៀវនិងម្ចាស់ក្លឹបចាប់ផ្ដើមមានអារម្មណ៍មួម៉ៅបាននាំគ្នាគប់ដប ដុំថ្ម និងវត្ថុផ្សេងៗដាក់នគរបាល ដែលនាំឱ្យមនុស្សជាច្រើនរយនាក់ធ្វើកុបកម្ម។ ការណ៍នេះនាំឱ្យមនុស្សរាប់ពាន់នាក់បន្តតវ៉ានៅក្នុងតំបន់នោះអស់រយៈពេលជាង៥ថ្ងៃ។ ក្លឹបកំសាន្ត **ស្តូនវ៉ូល** នេះត្រូវបានចាត់ទុកថាជាចំណុចប្រសព្វមួយសម្រាប់ចលនាទាមទារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នាសម័យទំនើប។ ក្លឹប**ស្តូនវ៉ូល** ជាទីកន្លែងប្រមូលផ្ដុំកម្លាំងដ៏រឹងមាំសម្រាប់សកម្មជនអ្នកស្រឡាញ់ភេទដូចគ្នា ការបង្កើតបាននូវអង្គការការពារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នាជាច្រើន និងជាទីកន្លែងចាប់

ផ្តើមការទាមទារឱ្យបញ្ឈប់ការកំណត់ជាទោសទណ្ឌលើអ្នកស្រឡាញ់ភេទដូចគ្នា។ មួយឆ្នាំបន្ទាប់ពីកុបកម្មនៅ **ស្តូនវូល** ការហែរក្បួនមោទកភាពសម័យទំនើបក៏ចាប់មានឡើង និងត្រូវបានមើលឃើញនៅទូទាំងពិភពលោក។



*ប៉ូលីសរុញច្រានមនុស្សនៅខាងស្តូនវូលនៅថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ១៩៦៩ WikiMedia* *<https://en.wikipedia.org/wiki/File:Stonewall_riots.jpg>.*

## ២.១.៤ ការរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍



នៅទសវត្សរ៍ឆ្នាំ១៩៨០ និងដើមទសវត្សរ៍ឆ្នាំ១៩៩០ ការផ្ទុះឡើងនៃជំងឺអេដស៍/មេរោគអេដស៍បានរីករាលដាលពាសពេញពិភពលោក។ អេដស៍ គឺជាមេរោគដែលវាយប្រហារប្រព័ន្ធការពារចម្លងតាមរយៈអង្គធាតុរាវ។ ផ្អែកតាមបទពិសោធកន្លងមក មេរោគអេដស៍ភាគច្រើនត្រូវបានចម្លងតាមរយៈការរួមភេទដោយមិនបានការពារ ការប្រើប្រាស់គ្រឿងញៀនដោយចាក់សឺរ៉ាំងម្ជុលរួមគ្នា និងតាមរយៈការផ្តល់កំណើត។ មេរោគអេដស៍អាចវិវឌ្ឍន៍សន្សឹមៗទៅជាជំងឺអេដស៍។ អ្នកមានជំងឺអេដស៍ គឺងាយប្រឈមមុខនឹងជំងឺផ្សេងដទៃៗទៀត។ ការរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ មានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើក្រុមបុរសស្រឡាញ់បុរស បុរសស្រឡាញ់ទាំងពីរភេទ បុរសប្តូរយេនឌ័រជាស្ត្រី និងបុរសរួមភេទជាមួយបុរស។ នៅក្នុងដំណាក់កាលនៃការរីករាលដាលដំបូង អ្នកវិទ្យាសាស្ត្រមិនបានដឹងអំពីរបៀបដែលវីរុសរាលដាលនោះទេ ប៉ុន្តែអត្រាខ្ពស់បំផុតនៃមេរោគអេដស៍បានកើតឡើងនៅក្នុងសហគមន៍បុរសស្រឡាញ់បុរស ឬបុរសរួមភេទជាមួយបុរស។ ជំងឺអេដស៍ដែលបណ្តាលមកពីមេរោគអេដស៍ត្រូវបានគេចាត់ទុកដូចជាទោសប្រហារជីវិតសម្រាប់បុរសស្រឡាញ់បុរស។ មេរោគនេះបានក្លាយជាឃាតករសម្លាប់បុរសវ័យក្មេងដ៏ច្រើនបំផុតនៅសហរដ្ឋអាមេរិកនៅឆ្នាំ១៩៨៤។ នៅឆ្នាំ១៩៩៥ បុរសស្រឡាញ់បុរសម្នាក់ក្នុងចំណោម៩នាក់ ត្រូវបានរកឃើញថាមានឆ្លង

បុរសស្រឡាញ់
ភេទដូចគ្នាម្នាក់
ក្នុងចំណោម១៥
នាក់បានស្លាប់

មេរោគអេដស៍ និងម្នាក់ក្នុងចំណោម១៥នាក់បានស្លាប់ ហើយ១០% នៃបុរសចំនួន ១.៦០០.០០០ នាក់ដែលមានអាយុពី ២៥ ដល់៤៤ ឆ្នាំ ដែលកំណត់អត្តសញ្ញាណថាជាបុរសស្រឡាញ់បុរសបានស្លាប់។

ក្នុងអំឡុងពេលនៃការរកឃើញជំងឺអេដស៍ដំបូង ជាទូទៅគេហៅជំងឺនេះថាជាជំងឺអូតូអ៊ុយមីនកើតចេញពីក្រុម បុរសស្រឡាញ់បុរស (Gay-Related Autoimmune Disease) ដែលបង្កឱ្យមានការមាក់ងាយយ៉ាងខ្លាំងទៅលើសហគមន៍បុរសស្រឡាញ់ភេទដូចគ្នា។ ម្យ៉ាងវិញទៀត ការរាយការណ៍គួរឱ្យភ្ញាក់ផ្អើលបានហៅជំងឺអេដស៍ថាជា "*រោគប៉េស្តបុរសស្រឡាញ់ភេទដូចគ្នា*" (*Gay Plague*) ដែលកាន់តែធ្វើឱ្យបុរសស្រឡាញ់ភេទដូចគ្នាប្រឈមថែមទៀត។ ទោះបីជាបច្ចុប្បន្ននេះមានថ្នាំជួយអ្នកផ្ទុកមេរោគអេដស៍ឱ្យមានជីវិតធម្មតាជាងមុន ក៏មេរោគអេដស៍នៅតែបន្តកើតមានជាវិបត្តិសុខភាពសាធារណៈដ៏ធំមួយនៅជុំវិញពិភពលោក ដោយសារតែមិនមានវ៉ាក់សាំងបង្ការ ឬព្យាបាលបានទេ ហើយវាមានឥទ្ធិពលយូរអង្វែងមកលើសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា។

### ២.១.៥ ចលនាទាមទារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នាសម័យទំនើប

នៅទសវត្សរ៍ឆ្នាំ១៩៩០ ក្រុមសកម្មជនអ្នកស្រឡាញ់ភេទដូចគ្នាបានលេចចេញជារូបរាងឡើង ហើយនេះជាការចាប់ផ្តើមនៃចលនាទាមទារសិទ្ធិស្មើគ្នាសម័យទំនើប។ ចលនានេះបានទាមទារ (និងនៅតែបន្តទាមទារ)នូវការទទួលស្គាល់តាមផ្លូវច្បាប់ ការបញ្ឈប់ការចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ និងការមិនរើសអើងចំពោះការស្រឡាញ់ភេទដូចគ្នា។ សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាបានប្រមូលផ្តុំគ្នាបង្កើតអង្គការមិនមែនរដ្ឋាភិបាលដើម្បីលើកកម្ពស់សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា និងរៀបចំចលនាសកលដើម្បីអំពាវនាវឱ្យមានសិទ្ធិស្មើគ្នា។ ចលនានេះបានធ្វើឱ្យមានសមិទ្ធផលគួរឱ្យកត់សម្គាល់នៅទូទាំងពិភពលោក រួមទាំងមានការលុបចោលច្បាប់ដែលដាក់ទោសលើអ្នកស្រឡាញ់ភេទដូចគ្នាផងដែរ។ លើសពីនេះទៅទៀត ក៏មានការប្រារព្ធព្រឹត្តិការណ៍មោទកភាពនានា ដើម្បីអបអរសាទរសមិទ្ធផល និងការទទួលស្គាល់អ្នកស្រឡាញ់ភេទដូចគ្នានៅទូទាំងពិភពលោក។ ទោះបីជាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់យ៉ាងណាក្តី ក៏នៅមានប្រទេសជាច្រើនទៀត នៅតែអនុវត្តច្បាប់ដាក់ទោស និងរើសអើងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា។

> **សមិទ្ធផលមួយចំនួននៃចលនាទាមទារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នាសម័យទំនើប**
>
> - សិទ្ធិរៀបអាពាហ៍ពិពាហ៍ ឬបង្កើតគ្រួសារ
> - សិទ្ធិសុំកូនដោយស្របច្បាប់
> - ការទទួលស្គាល់យេនឌ័រតាមផ្លូវច្បាប់
> - ការការពារប្រឆាំងនឹងការរើសអើងនៅក្នុងផ្នែកខ្លះ ឬលើជីវិតទាំងមូល
> - សិទ្ធិប្រើប្រាស់បន្ទប់ទឹកដាច់ដោយឡែកសម្រាប់អ្នកប្តូរយេនឌ័រ

### ២.២ ប្រវត្តិសង្ខេបនៃសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាក្នុងប្រទេសកម្ពុជា

នៅប្រទេសកម្ពុជាពុំមានកំណត់បទល្មើសព្រហ្មទណ្ឌទៅលើអ្នកស្រឡាញ់ភេទដូចគ្នាឡើយ។ វត្តមានរបស់អ្នកស្រឡាញ់ភេទដូចគ្នាមានចំនួនកាន់តែច្រើនឡើងៗក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ហើយទោះបីមានជំហានវិជ្ជមានដើម្បីសម្រេចបាននូវសមភាពកន្លងមកក៏ដោយ ក៏សមភាពពេញលេញនៅតែមិនទាន់សម្រេចបាននៅឡើយទេ។

## ២.២.១ ស្ថានភាពអ្នកស្រឡាញ់ភេទដូចគ្នាក្នុងសម័យអង្គរ

នៅក្នុងសម័យបុរាណកម្ពុជាគឺជាប្រទេសមានអរិយធម៌ដ៏ល្បីល្បាញមួយដែលមានវប្បធម៌ផ្ទាល់ខ្លួន និងឯករាជ្យ។ បូជនីយដ្ឋាន និងប្រាង្គប្រាសាទបុរាណនៅប្រទេសកម្ពុជាមានរូបចម្លាក់និងរូបសំណាកតាំងពីសតវត្សរ៍ទី៤ មកដែលបង្ហាញពីវប្បធម៌ និងបទដ្ឋានយេនឌ័រ ឬការយល់ឃើញរបស់ជនជាតិខ្មែរ។



រូបសំណាកអាទិទេពមួយអង្គព្រះនាមអឌ្ឍរីស្វៈ (**Ardharishvara**) តម្កល់នៅក្នុងសារមន្ទីរជាតិក្នុងរាជធានីភ្នំពេញនៃប្រទេសកម្ពុជា មានលក្ខណៈសម្គាល់ពិសេសផ្នែកយេនឌ័រ។ រូបសំណាកអឌ្ឍរីស្វៈបង្ហាញរាងកាយពាក់កណ្តាលជាស្ត្រី ពាក់កណ្តាលជាបុរស។ រូបសំណាកនេះស្លៀកសំពត់ខ្លីដល់ជង្គង់ ហើយដៃស្តាំដាក់ទៅមុខដោយកាយវិការផ្តល់អំណោយ។ អឌ្ឍរីស្វៈកើតចេញពីដំណើររឿងស្នេហារវាងព្រះសិវៈ និងព្រះនាងបវ៌តី។ ព្រះនាងបវ៌តី គឺជាអគ្គមហេសីរបស់ព្រះសិវៈបានតូចចិត្តនឹងព្រះអង្គដែលមិនមើលថែនាង ហើយមិនផ្តល់ភាពសុខដុមដល់នាង។ ដើម្បីផ្គាប់ចិត្តភរិយានិងផ្តល់សុភមង្គលដល់នាង ព្រះសិវៈបានបំបែករាងកាយរបស់ព្រះអង្គពាក់កណ្តាល និងភរិយាពាក់កណ្តាលដើម្បីបង្រួមរាងកាយទាំងពីររួមគ្នាតែមួយដែលបង្កើតបានជាអឌ្ឍរីស្វៈ (**Ardharishvara**)។ ទោះបីជាមានការរួមបញ្ចូលគ្នានៃយេនឌ័ររបស់រូបចម្លាក់នេះក៏ដោយ ក៏នៅតែមានភាពអាថ៌កំបាំងនៅឡើយរហូតមកដល់សព្វថ្ងៃនេះចំពោះអត្តន័យដ៏អស្ចារ្យទាក់ទងទៅនឹងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទនៅក្នុងសង្គមកម្ពុជាសម័យបុរាណ។

នៅក្នុងសៀវភៅកំណត់ហេតុអំពីប្រពៃណីនៃអ្នកស្រុកចេនឡារបស់លោក ជីវ តាក្វាន់ ជនជាតិចិនដែលបានរស់នៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ១២៩៦/៩៧ ក្នុងអំឡុងយុគកណ្តាលនៃចក្រភពអង្គរ។ កំណត់ហេតុរបស់គាត់មានរៀបរាប់អំពីទំនៀមទម្លាប់របស់ប្រទេសកម្ពុជា និងបង្ហាញនូវអាកប្បកិរិយាចម្រុះតាំងពីសតវត្សរ៍ទី១៣មកម្ល៉េះ។

*«ស្ត្រីខ្លះឈរនោមដូចបុរស»*

សកម្មភាពនេះផ្តល់នូវការយល់ដឹងយ៉ាងទូលំទូលាយអំពីអត្តសញ្ញាណយេនឌ័រក្នុងសម័យអង្គរ និងផ្ទុយជាមួយនឹងការបកស្រាយដែលថាសកម្មភាពទាំងនោះ គឺសម្រាប់សម្គាល់តែទៅលើលក្ខណៈភេទតែពីរប៉ុណ្ណោះគឺបុំលិង្គ (ភេទប្រុស) និងឥត្ថីលិង្គ (ភេទស្រី)។

«*នៅតាមទីផ្សារ គេឃើញមានមនុស្ស១០នាក់ ឬច្រើនជាងនេះ (បុរសដែលតែងខ្លួនជាស្ត្រី) ជារៀងរាល់ថ្ងៃដែលកំពុងព្យាយាមទាញចំណាប់អារម្មណ៍ពីបុរសអ្នកមានជនជាតិចិន*»។

នៅក្នុងសេចក្តីថ្លែងនេះបរិយាយអំពីក្រុមអ្នកប្តូរយេនឌ័រជាស្ត្រីដែលដើរដោយបើកចំហនៅក្នុងទីផ្សារ ដោយមិនលាក់បាំងអត្តសញ្ញាណយេនឌ័ររបស់ខ្លួនឡើយ ហើយនេះគឺជាភស្តុតាងដំបូងនៃភាពចម្រុះនៃយេនឌ័រក្នុងប្រទេសកម្ពុជា។

### ២.២.២ ស្ថានភាពអ្នកស្រឡាញ់ភេទដូចគ្នាតាមទ្រឹស្តីនៃព្រះពុទ្ធសាសនា

ក្នុងព្រះពុទ្ធសាសនា មានការយោងយេនឌ័រចំនួន ៤៖ បុរស ស្ត្រី ឧភតោព្យញ្ជនកៈ និងបណ្ឌក។ ពាក្យថា **ឧភតោព្យញ្ជនកៈ** ជាធម្មតាត្រូវបានប្រើសម្រាប់ពិពណ៌នាលើមនុស្សដែលមានប្រដាប់ភេទពីរគឺប្រុសផង ស្រីផង (ឧភតោភេទ)។ ពាក្យ **បណ្ឌក** គឺជាប្រភេទមួយដែលមានលក្ខណៈស្មុគស្មាញដែលត្រូវបានកំណត់អត្ថន័យផ្សេងៗក្នុងគម្ពីរនៃព្រះពុទ្ធសាសនា។ ប៉ុន្តែការបកប្រែពាក្យនាសម័យទំនើបនេះហាក់ដូចជាសំដៅទៅលើបុរសស្រឡាញ់បុរស និងស្ត្រីស្រឡាញ់ស្ត្រី។

### ២.២.៣ ស្ថានភាពអ្នកស្រឡាញ់ភេទដូចគ្នាក្នុងរបបខ្មែរក្រហម

ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ខ្មែរក្រហមបានគ្រប់គ្រងប្រទេសកម្ពុជា និងបានដាក់ចេញនូវគោលនយោបាយឃោរឃៅដែលជាលទ្ធផលបានធ្វើឱ្យពលរដ្ឋស្លាប់ប្រមាណជា ១,៧ លាននាក់ ជិតមួយភាគបួននៃពលរដ្ឋសរុប ដោយសារការអត់ឃ្លាន ការនឿយហត់ ការធ្វើទារុណកម្ម និងការប្រហារជីវិត។ ទោះបីស្ថិតក្រោមរបបគាបសង្កត់ខ្លាំងយ៉ាងនេះក្តី ក៏នៅមានគូស្នេហ៍ស្រឡាញ់ភេទដូចគ្នាមួយចំនួនអាចលាក់បាំងទំនាក់ទំនងស្នេហា និងអត្តសញ្ញាណយេនឌ័ររបស់ពួកគេបាន។ ជាពិសេស មានអ្នកប្តូរយេនឌ័រពីស្ត្រីទៅបុរសម្នាក់បានលាក់អត្តសញ្ញាណពិតរបស់ខ្លួនក្នុងរបបប្រល័យពូជសាសន៍ខ្មែរក្រហម និងបានចែករំលែករឿងរ៉ាវរបស់ខ្លួន។

*«នៅលើផ្លូវក្តោះតាមមាត់ប្រឡាយក្នុងចម្ងាយផ្លូវដ៏វែងឆ្ងាយរាប់រយគីឡូម៉ែត្រ ពីខេត្តនេះរហូតដល់ក្រុងបាត់ដំបង។ នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានបង្ខំឱ្យ **ស៊ីថា** ជាស្ត្រីប្តូរយេនឌ័រជាបុរស អ្នកចម្រៀង និងជាសកម្មជនចេញពីផ្ទះរបស់គាត់ក្នុងទីក្រុងភ្នំពេញទៅធ្វើការនៅក្នុងក្រុមស្ត្រីយុវវ័យក្មេងនៅក្នុងភូមិនេះ។ បួនទសវត្សរ៍កន្លងមកបន្ទាប់ពីរបបខ្មែរក្រហមដួលរលំ **ស៊ីថា**បានដើរចេញពីយានយន្តដោយពាក់អាវពណ៌ផ្កាឈូក និងខោពណ៌ផ្កាឈូកមួយ ជាពណ៌ដែលគាត់ចូលចិត្ត។ **ស៊ីថា**បានពោលឡើងថា "នេះហើយជាកន្លែងដែលខ្ញុំបានជួបប្រពន្ធរបស់ខ្ញុំ"។*

*ក្នុងសម័យប្រល័យពូជសាសន៍នេះ ស្ទើរតែមិនមានកន្លែងណាដែលអាចឱ្យមនុស្សនឹកស្រមៃអំពីរឿងរ៉ាវស្នេហាមួយដែលកំពុងរីកដុះដាលរវាងអ្នកប្តូរយេនឌ័រជាបុរសម្នាក់ និងស្ត្រីម្នាក់បាន។ ប៉ុន្តែអ្វីដែលគួរឱ្យកត់សម្គាល់នោះគឺ កន្លែងនេះហើយជាកន្លែងដែលមានអ្នកប្តូរយេនឌ័រជាបុរសយ៉ាងតិច៣នាក់ និងស្ត្រីស្រឡាញ់ភេទដូចគ្នាបានជួបគ្នា និងក្លាយជាមិត្តជិតស្និទ្ធនឹងគ្នា។ ពួកគាត់ម្នាក់ៗបានរកឃើញស្នេហាក្រោមរបបនេះ ពេលខ្លះមានច្រើនជាងម្នាក់ក្នុងពេលនោះ។ គូស្នេហ៍ខ្លះនៅតែរស់នៅជាមួយគ្នារហូតមកដល់បច្ចុប្បន្ននេះ»។*

នៅក្នុងអំឡុងពេលនោះ មន្ត្រីខ្មែរក្រហមបានរៀបចំអាពាហ៍ពិពាហ៍ភាគច្រើនដោយផ្អែកទៅលើគោលការណ៍របស់រដ្ឋដ៏តឹងរ៉ឹងបំផុត។ អាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានរៀបចំឡើងដោយខ្មែរក្រហម ដើម្បីបង្កើតមនុស្សជំនាន់ថ្មីឱ្យបម្រើរបបនេះ និងបដិសេធការជ្រើសរើសគូស្រករតាមការសម្រេចចិត្តដោយខ្លួនឯង។ អ្នកប្តូរ

យេនឌ័រជាស្ត្រីម្នាក់បានរម្លឹកពីរបបខ្មែរក្រហមនេះដែលបានបង្ខំគាត់ឱ្យរៀបការជាមួយស្ត្រីម្នាក់ ពីព្រោះកាល នោះគាត់បានលាក់អត្តសញ្ញាណយេនឌ័ររបស់ខ្លួន។

*«ពួកគេបានបង្ខំខ្ញុំ ពីព្រោះពួកគេមិនបានដឹងថាខ្ញុំគឺជាអ្នកប្តូរយេនឌ័រជាស្ត្រីនោះទេ។ ជាក់ស្តែងពេល នោះ ខ្ញុំមើលទៅដូចជាបុរសអញ្ចឹង ប៉ុន្តែធម្មជាតិរបស់ខ្ញុំគឺខ្ញុំមានអាកប្បកិរិយាជាមនុស្សស្រីម្នាក់។ ពួកគេ ទាំងអស់គ្នា មិនបានដឹងថាខ្ញុំគឺជាអ្នកប្តូរយេនឌ័រជាស្ត្រីនោះទេ ព្រោះខ្ញុំមិនដែលប្រាប់នរណាម្នាក់ឡើយ ព្រោះខ្ញុំខ្លាចថាខ្មែរក្រហមដឹង ពួកគេនឹងសម្លាប់ខ្ញុំ.... ប៉ុន្តែដោយសារខ្ញុំមិនបានស្រឡាញ់ស្ត្រីម្នាក់នោះទេ ពួកគេក៏បានពិភាក្សាគ្នា ហើយបន្ទាប់មកក៏ប្រាប់ខ្ញុំថា ខ្ញុំត្រូវតែរៀបការជាមួយស្ត្រីម្នាក់នោះ»។ (គន្ធោយ* **Kuthoy** *) អ្នកប្តូរយេនឌ័រជាស្ត្រីនៅខេត្តសៀមរាប។*

មានការលើកឡើងថា ភ័ស្តុតាងប្រវត្តិសាស្ត្រផ្សេងៗទៀតដែលបញ្ជាក់ពីភាពចម្រុះនៃនិន្នាការភេទ និង អត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទត្រូវបានបំផ្លាញចោលក្នុងសម័យខ្មែរក្រហម។



### ២.២.៤ ស្ថានភាពអ្នកស្រឡាញ់ភេទដូចគ្នានៅទសវត្សរ៍ឆ្នាំ១៩៩០ និងសតវត្សរ៍ទី ២១

ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៩០ មក សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាកើនច្រើនឡើងៗនៅកម្ពុជា។

- ការសិក្សាអំពីផ្លូវភេទ និងអាកប្បកិរិយា ដែលចាប់ផ្ដើមនៅទសវត្សរ៍ឆ្នាំ១៩៩០ ដែលជំរុញឱ្យមានការសិក្សានេះដោយសារការរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ជាសកល បានធ្វើឱ្យមានការយល់ដឹង និងមានការពិភាក្សាច្រើនអំពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទនៅកម្ពុជា។
- ការប្រារព្ធព្រឹត្តិការណ៍មោទកភាពនៅក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ២០០៣មក ជាការលើកកម្ពស់វត្តមានរបស់អ្នកស្រឡាញ់ភេទដូចគ្នា និងធ្វើឱ្យមានការទទួលស្គាល់ច្រើនទៅៗ។
- ព្រះបាទសម្ដេចព្រះនរោត្តមសីហនុ អតីតព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់បានមានព្រះរាជឱង្ការជាសាធារណៈសម្ដែងព្រះរាជហឫទ័យគាំទ្រដល់ទំនាក់ទំនងស្នេហាភេទដូចគ្នាក្នុងឆ្នាំ២០០៤។
- អង្គការអ្នកស្រឡាញ់ភេទដូចគ្នាត្រូវបានបង្កើតឡើងជាផ្លូវការក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ២០១៤។



# មេរៀនទី ៣៖ ច្បាប់សិទ្ធិមនុស្សអន្តរជាតិស្តីពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ

## ៣.១ ប្រភពច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ

ប្រភពច្បាប់សិទ្ធិមនុស្សអន្តរជាតិទាក់ទងនឹងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិសុខភាពផ្លូវភេទ និងសុខភាពបន្តពូជរួមមាន៖

- *សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស*[5]
- *កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ*[6]
- *កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌*[7]
- *អនុសញ្ញាអង្គការពលកម្មអន្តរជាតិ*
- *អនុសញ្ញាស្តីពីសិទ្ធិកុមារ*[8]
- *គោលការណ៍យ៉កយ៉ាកាតានៃការអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិស្តីពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ*[9]
- *គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព*
- *ការពិនិត្យជាសកលតាមកាលកំណត់ (UPR) កម្ពុជា (ជុំទី៣នៃកិច្ចប្រជុំលើកទី៣២)*[10]

**ពាក្យគន្លឹះសំខាន់ៗសម្រាប់មេរៀនទី ៣**

- **ឯកសារមិនជាប់កាតព្វកិច្ច៖** ឯកសារដែលមិនមានកាតព្វកិច្ចតាមផ្លូវច្បាប់ជាផ្លូវការ។
- **សេចក្តីប្រកាស៖** ឯកសារមិនជាប់កាតព្វកិច្ចដែលឈរលើការព្រមព្រៀងឬគោលការណ៍ជាសកល។
- **កតិកាសញ្ញា ឬសន្ធិសញ្ញា៖** កិច្ចព្រមព្រៀងដែលមានកាតព្វកិច្ចអន្តរជាតិដែលបង្កើតកាតព្វកិច្ចខាងផ្លូវច្បាប់។
- **ការផ្តល់សច្ចាប័ន៖** ការយល់ព្រមជាផ្លូវការដោយរដ្ឋភាគីលើកិច្ចព្រមព្រៀងអន្តរជាតិដែលរដ្ឋសន្យាយល់ព្រមភ្ជាប់កាតព្វកិច្ចខ្លួនទៅនឹងកិច្ចព្រមព្រៀងនោះ។
- **អត្តសញ្ញាណយេនឌ័រ៖** សំដៅលើអារម្មណ៍ខាងក្នុងផ្ទាល់ខ្លួន និងបទពិសោធរបស់បុគ្គលម្នាក់ទៅលើយេនឌ័ររបស់ខ្លួនដែលអាច ឬ មិនអាចស៊ីសង្វាក់ទៅនឹងភេទពីកំណើតរបស់បុគ្គលនោះ។
- **យូ.ភី.អ៖** យន្តការពិនិត្យជាសកលតាមកាលកំណត់របស់អង្គការសហប្រជាជាតិដែលជាកន្លែងដែលរដ្ឋជាសមាជិកត្រូវបានពិនិត្យឡើងវិញជាទៀងទាត់នូវវិវឌ្ឍន៍ភាពផ្នែកសិទ្ធិមនុស្ស នៅក្នុងប្រទេសរបស់ខ្លួននីមួយៗនិងទទួលបានអនុសាសន៍ពីសមាជិកផ្សេងៗទៀត។

---

[5] ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស "សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស" (អនុម័ត ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨) ដំណោះស្រាយលេខ ២១៧ A(III) (UDHR) <https://www.ohchr.org/EN/UDHR/Documents/UDHR_Translations/eng.pdf>.

[6] ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស "កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ" (អនុម័ត ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ចូលជាធរមានថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦ ) (ICCPR) <https://www.ohchr.org/en/professionalinterest/pages/ccpr.aspx>.

[7] ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស "កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌" (អនុម័ត ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ចូលជាធរមាន ថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦ ) 993 UNTS 3 (ICESCR) <https://www.ohchr.org/EN/ProfessionalInterest/Pages/CESCR.aspx>.

[8] ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស "អនុសញ្ញាស្តីពីសិទ្ធិកុមារ" (អនុម័ត ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩ ចូលជាធរមានថ្ងៃទី ២ ខែកញ្ញា ឆ្នាំ១៩៩០ ) <https://www.ohchr.org/en/professionalinterest/pages/crc.aspx>

[9] គណៈកម្មាធិការអ្នកច្បាប់អន្តរជាតិ ("ICJ") «គោលការណ៍យ៉កយ៉ាកាតា៖ ស្តីពីការអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិទាក់ទងជាមួយនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ( ខែមីនា ឆ្នាំ២០០៧ ) <http://yogyakartaprinciples.org/wp-content/uploads/2016/08/principles_en.pdf>.

[10] ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ «របាយការណ៍របស់ក្រុមការងារទទួលបន្ទុកលើការពិនិត្យជាសកលតាមកាលកំណត់» (3d Cycle, 32d Session) (ប្រទេសកម្ពុជា) <https://documents-dds-ny.un.org/doc/UNDOC/GEN/G18/341/00/PDF/G1834100.pdf?OpenElement>

### *សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (ស.ប.ស.ស)*

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ជាឯកសារប្រវត្តិសាស្ត្រមួយបានអនុម័តដោយអង្គការសហប្រជាជាតិនៅក្នុងឆ្នាំ១៩៤៨ បន្ទាប់ពីសង្គ្រាមលោកលើកទីពីរត្រូវបានបញ្ចប់ ដើម្បីទប់ស្កាត់អំពើឃោរឃៅស្រដៀងគ្នានេះកុំឱ្យកើតឡើងម្តងទៀត។ សេចក្តីប្រកាសនេះជាកិច្ចព្រមព្រៀងអន្តរជាតិទីមួយដែលឈរលើគោលការណ៍មូលដ្ឋាននៃសិទ្ធិមនុស្ស។ សិទ្ធិដែលមានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សត្រូវបានបែងចែកចេញជាលិខិតូបករណ៍អន្តរជាតិចំនួនពីរគឺកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីឱ្យសេចក្តីប្រកាសនេះកាន់តែមានប្រសិទ្ធភាព។

### *កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ក.អ.ស.ព.ន)*

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយបានកំណត់យ៉ាងច្បាស់អំពីសិទ្ធិសេរីភាពរួមទាំងសិទ្ធិមួយចំនួនទៀត ដែលរដ្ឋមិនអាចដកហូតបានពីបុគ្គលម្នាក់ៗដូចជាសិទ្ធិគ្មានការរើសអើង។

កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវបានអនុម័តនៅឆ្នាំ១៩៦៦ និងចូលជាធរមាននៅក្នុងឆ្នាំ១៩៧៦។ កតិកាសញ្ញានេះ ត្រូវបានផ្តល់សច្ចាប័នដោយរដ្ឋចំនួន១៧៣ ហើយប្រទេសកម្ពុជាក៏បានផ្តល់សច្ចាប័នលើកតិកាសញ្ញាអន្តរជាតិនេះក្នុងឆ្នាំ១៩៩២។

### *កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.អ.ស.ស.វ)*

កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌បានកំណត់យ៉ាងច្បាស់ពីសិទ្ធិមូលដ្ឋានសំខាន់ៗ ដែលរដ្ឋត្រូវតែផ្តល់ជូនប្រជាពលរដ្ឋដូចជា សិទ្ធិទទួលបានការងារ និងសិទ្ធិទទួលបានលំនៅដ្ឋានសមរម្យជាដើម។កតិកាសញ្ញាអន្តរជាតិនេះត្រូវបានអនុម័តនៅឆ្នាំ១៩៦៦ និងចូលជាធរមាននៅក្នុងឆ្នាំ១៩៧៦។ កតិកាសញ្ញានេះត្រូវបានផ្តល់សច្ចាប័នដោយរដ្ឋចំនួន១៧១ ក្នុងនោះប្រទេសកម្ពុជាក៏បានផ្តល់សច្ចាប័នលើកតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៅក្នុងឆ្នាំ១៩៩២។

### *អនុសញ្ញានៃអង្គការពលកម្មអន្តរជាតិ(អាយឡូ)*

អង្គការពលកម្មអន្តរជាតិ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩១៩ និងបានក្លាយជាភ្នាក់ងារពិសេសរបស់អង្គការសហប្រជាជាតិក្នុងឆ្នាំ១៩៤៦។ អនុសញ្ញានេះមានគោលបំណងក្នុងការ“*លើកកម្ពស់សិទ្ធិនៅកន្លែងធ្វើការ បង្កើតឱកាសការងារសមរម្យ លើកកម្ពស់កិច្ចគាំពារសង្គម និងពង្រឹងការពិភាក្សាលើបញ្ហាទាក់ទងនឹងការងារ*”[11]។ អង្គការពលកម្មអន្តរជាតិ មានរដ្ឋជាសមាជិកចំនួន១៨៧ប្រទេស។ ប្រទេសកម្ពុជាបានក្លាយជាសមាជិកនៃអង្គការពលកម្មអន្តរជាតិនៅក្នុងឆ្នាំ១៩៦៩។ អង្គការពលកម្មអន្តរជាតិបានអនុម័ត

### *អនុសញ្ញាស្តីពីសិទ្ធិកុមារ (អនុ.ស.ក)*

អនុសញ្ញាស្តីពីសិទ្ធិកុមារត្រូវបានអនុម័តនៅក្នុងឆ្នាំ១៩៨៩ ហើយអនុសញ្ញានេះ បានពន្យល់អំពីសិទ្ធិដែលកុមារត្រូវតែមាន ដូចជាទំនួលខុសត្រូវរបស់រដ្ឋត្រូវមានលើសិទ្ធិកុមារ។ អនុសញ្ញានេះជាលិខិតូបករណ៍អន្តរជាតិចងកាតព្វកិច្ចផ្លូវច្បាប់ដែលចែងអំពីសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់កុមារ។ អនុសញ្ញានេះជាសន្ធិសញ្ញាសិទ្ធិមនុស្សដែលត្រូវបានផ្តល់សច្ចាប័នជាទូទៅបំផុតនៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ដោយមានប្រទេសចំនួន ១៩៦ បានផ្តល់ សច្ចាប័ន

---

[11] អង្គការពលកម្មអន្តរជាតិ “ស្តីអំពីអង្គការពលកម្មអន្តរជាតិ” <https://www.ilo.org/global/about-the-ilo/lang--en/index.htm>.

| | |
|---|---|
| បទដ្ឋានការងារអន្តរជាតិក្នុងទម្រង់ជាកតិកាសញ្ញា និងអនុសញ្ញានានាដែលរដ្ឋអាចផ្តល់សច្ចាប័ន។ អនុសញ្ញាស្តីពីអង្គការពលកម្មអន្តរជាតិមានមូលដ្ឋានគ្រឹះចំនួន ៨ ក្នុងនោះរួមមាន៖ **អនុសញ្ញាលេខ១១១ ស្តីពីការគ្មានការរើសអើង**(ការងារនិងមុខរបរ) ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ននៅឆ្នាំ១៩៩៩។ | ហើយមានប្រទេសកម្ពុជាក៏បានផ្តល់ សច្ចាប័នលើអនុសញ្ញានេះនៅក្នុងឆ្នាំ១៩៩២។ អនុសញ្ញាស្តីពីសិទ្ធិកុមារ ក៏មានអនុភាពអនុវត្តស្មើៗគ្នាចំពោះកុមារទាំងអស់ដែលមានអាយុក្រោម១៨ឆ្នាំ ។ |

*គោលការណ៍យ៉កយ៉ាកាតា នៃការអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិស្តីពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ (គោលការណ៍យ៉កយ៉ាកាតា)*

គោលការណ៍យ៉កយ៉ាកាតា ផ្តល់នូវក្របខ័ណ្ឌគ្រប់ជ្រុងជ្រោយសម្រាប់ការអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិ *ជាពិសេស* ចំពោះស្ថានភាពរបស់អ្នកស្រឡាញ់ភេទដូចគ្នា។ គោលការណ៍យ៉កយ៉ាកាតាត្រូវបានអនុម័តនៅក្នុងឆ្នាំ២០០៦ ដើម្បីឆ្លើយតបទៅនឹងការរំលោភសិទ្ធិមនុស្សនៅទូទាំងពិភពលោក ជាពិសេសផ្តោតសំខាន់លើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ រួមមាន មនុស្សឃាត ការធ្វើទារុណកម្ម អំពើឃោរឃៅ ការបៀតបៀនផ្លូវភេទ ការរំលោភសេពសន្ថវៈ និងការរើសអើងជាដើម។ ទោះបីគោលការណ៍យ៉កយ៉ាកាតា មិនមានកាតព្វកិច្ចផ្លូវច្បាប់ក៏ដោយ ក៏គោលការណ៍នេះត្រូវស្ថាប័នជាច្រើននៃអង្គការសហប្រជាជាតិយកធ្វើជាមូលដ្ឋានសម្រាប់គាំទ្រដល់ការធ្វើសេចក្តីសម្រេចចិត្តក្នុងការកំណត់សកម្មភាពការពារអ្នកស្រឡាញ់ភេទដូចគ្នានៅថ្ងៃអនាគតផងដែរ ហើយគោលការណ៍នេះក៏ជាបទដ្ឋានគតិយុត្តិមួយដែលបង្ហាញពីរបៀបដែលរដ្ឋ និងតួអង្គផ្សេងៗទៀតអាចចូលរួមសហការគ្នាដើម្បីបញ្ចប់អំពើហិង្សាការបៀតបៀន និងការរើសអើងលើអ្នកស្រឡាញ់ភេទដូចគ្នា។ ក្នុងឆ្នាំ២០១៧ គោលការណ៍នេះបានបំពេញបន្ថែមនូវ "គោលការណ៍យ៉កយ៉ាកាតាបូក ១០" ដោយបញ្ចូលការវិវឌ្ឍទាំងនេះក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការអនុវត្តចាប់ពីពេលអនុម័តគោលការណ៍យ៉កយ៉ាកាតាក្នុងឆ្នាំ២០០៦។ គោលការណ៍យ៉កយ៉ាកាតាមាន ២៩ គោលការណ៍ និង ១៦ អនុសាសន៍បន្ថែម ដែលបង្ហាញពីទិដ្ឋភាពនៃការអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិចំពោះការរស់នៅ និងបទពិសោធរបស់បុគ្គលដែលមានភាពចម្រុះនៃនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ។

*គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព(គោលដៅអភិវឌ្ឍន៍)*

នៅក្នុងឆ្នាំ២០១៥ អង្គការសហប្រជាជាតិបានអនុម័តរបៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ គោលដៅអភិវឌ្ឍន៍នេះមានគោលដៅស្នូលចំនួន ១៧ ដើម្បីបញ្ចប់ភាពក្រីក្រ លុបបំបាត់វិសមភាព និងអំពើអយុត្តិធម៌ ដោះស្រាយការប្រែប្រួលអាកាសធាតុ និងបង្កើតពិភពលោកមួយដែលមានការចូលរួមពីពលរដ្ឋគ្រប់រូបដើម្បីសម្រេចនូវគោលដៅទាំងនោះនៅត្រឹមឆ្នាំ២០៣០[12]។ គោលដៅ អភិវឌ្ឍន៍នេះបានកំណត់ថា «មិនទុកនរណាម្នាក់ចោល»។

[12] Agence Française de Développement, "គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព" <https://www.afd.fr/en/sustainable-development-goals>.

ក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ១០«កាត់បន្ថយវិសមភាព» គឺមានចំណុចដៅជាច្រើន។ ក្នុងចំណោមចំណុចដៅទាំងនេះគឺចំណុចដៅ ១០៣ តម្រូវឱ្យរដ្ឋ» ធានាផ្តល់នូវឱកាសស្មើៗគ្នា និងកាត់បន្ថយវិសមភាព រួមទាំងការលុបបំបាត់ច្បាប់ និងគោលនយោបាយដែលមានលក្ខណៈរើសអើង ហើយនិងការអនុវត្តនានា ព្រមទាំងបង្កើតច្បាប់ គោលនយោបាយ និងសកម្មភាពសមស្របទាក់ទងនឹងបញ្ហាទាំងនេះ[13]។

## ៣.២ សិទ្ធិនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ

### ៣.២.១ សិទ្ធិគ្មានការរើសអើង



- មាត្រា ១ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស៖ «*មនុស្សទាំងអស់កើតមកមានសេរីភាព និងសមភាពក្នុងផ្នែកសេចក្តីថ្លៃថ្នូរ និងសិទ្ធិ*»។
- មាត្រា ២ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស៖«*មនុស្សម្នាក់ៗអាចប្រើប្រាស់សិទ្ធិ និងសេរីភាពទាំងអស់ដែលបានប្រកាសក្នុងសេចក្តីប្រកាសនេះ ដោយគ្មានការប្រកាន់បែងចែកបែបណាមួយមានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬ* ***ស្ថានភាពដទៃៗទៀតឡើយ***»។
- មាត្រា ២ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងមាត្រា ២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌បានតម្រូវឱ្យរដ្ឋភាគីនៃកតិកាសញ្ញានេះប្តេជ្ញាធានាសិទ្ធិទាំងឡាយ ដែលចែងក្នុងកតិកាសញ្ញានេះ នឹងត្រូវប្រើប្រាស់ដោយគ្មានការរើសអើងណាមួយផ្អែកលើ «*ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬ****ស្ថានភាពដទៃៗទៀតឡើយ***»។
- មាត្រា ២ នៃ អនុសញ្ញាស្តីពីសិទ្ធិកុមារ តម្រូវឱ្យរដ្ឋភាគីត្រូវតែគោរព និងធានាសិទ្ធិរបស់កុមារគ្រប់រូបក្នុងដែនសមត្ថកិច្ចរបស់ខ្លួន «*ដោយគ្មានការរើសអើងណាមួយ ដោយឥតគិតពីពូជសាសន៍ ពណ៌សម្បុរ*

**“ស្ថានភាពផ្សេងទៀត”**

ថ្វីបើសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិមិនបានកំណត់យ៉ាងជាក់លាក់ថានិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទជាប្រភេទហាមឃាត់ពីការរើសអើងក៏ដោយ។ បន្ថែមលើនេះ “**ស្ថានភាពផ្សេងទៀត**” បានបង្ហាញការមិនផាត់ចេញ និងអាចរាប់បញ្ចូលប្រភេទផ្សេងទៀតដូចជា និន្នាការភេទ អត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទបាន ។ លើសពីនេះទៅទៀត ពាក្យ “**ស្ថានភាពផ្សេងទៀត** ”ត្រូវបានបកស្រាយដោយអង្គភាពសន្ធិសញ្ញា និងនៅក្នុងសេចក្តីសម្រេចចិត្តរបស់គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិដើម្បីហាមឃាត់ការរើសអើងអ្នកស្រឡាញ់ភេទដូចគ្នាផងដែរ[14]។

[13] នាយកដ្ឋានសេដ្ឋកិច្ចនិងសង្គមរបស់អង្គការសហប្រជាជាតិ "គោលដៅទី១០" <https://sdgs.un.org/goals/goal10>.

[14] ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមអង្គការសហប្រជាជាតិ "យោបល់ទូទៅលេខ២០" "ការមិនរើសអើងសិទ្ធិសេដ្ឋកិច្ច សង្គមនិងវប្បធម៌ ( មាត្រា២ កថាខណ្ឌ ២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (E/C.12/GC/20) (ឆ្នាំ២០០៩); គណៈកម្មាធិការសិទ្ធិមនុស្សសហប្រជាជាតិ, Toonen v Australia, បណ្តឹងលេខ ៤៨៨/១៩៩២ (CCPR/C/50/D/488/1992) (ថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៩៤)

*ភេទ សាសនា មតិនយោបាយ ឬមតិផ្សេងទៀត ដើមកំណើតជាតិ ដើមកំណើតជនជាតិ ឬសង្គម ទ្រព្យសម្បត្តិ អសមត្ថភាព កំណើត ឬស្ថានភាពផ្សេងទៀតរបស់កុមារ របស់ឪពុកម្តាយកុមារ ឬអ្នកអាណាព្យាបាលស្របច្បាប់របស់កុមារ*»។

- គោលការណ៍ទី ២ នៃ គោលការណ៍យ៉ូកយ៉ាកាតា តម្រូវឱ្យរដ្ឋភាគី «*ដាក់បញ្ចូលគោលការណ៍សមភាព និងមិនរើសអើងដែលឈរលើមូលដ្ឋាននៃនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ*» និង «*ចាត់វិធានការនីតិបញ្ញត្តិ និងវិធានការសមស្របផ្សេងទៀត ដើម្បីហាមឃាត់ និងលុបបំបាត់ការរើសអើងខាងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រនៅក្នុងរង្វង់បុគ្គល និងសាធារណជន*»។
- គោលដៅទី១០ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព «*កាត់បន្ថយវិសមភាព*»។
- រាជរដ្ឋាភិបាលកម្ពុជាបានទទួលយកអនុសាសន៍ជាច្រើនក្នុងកិច្ចប្រជុំលើកទី៣២ នៃដំណើរការពិនិត្យជាសកលតាមកាលកំណត់ (យូភីអ) ជុំទី៣ ដូចជា៖ (១) តាក់តែងច្បាប់ថ្មីដែលធានាសមភាព (២) អនុម័តនូវវិធាននានាដើម្បីប្រយុទ្ធប្រឆាំងនឹងការរើសអើង និងដាក់ទណ្ឌកម្មលើបុគ្គលទាំងឡាយណាដែលរើសអើងអ្នកស្រឡាញ់ភេទដូចគ្នា (៣) តាក់តែងច្បាប់ប្រឆាំងនឹងការរើសអើងដែលហាមប្រាមការរើសអើងគ្រប់ប្រភេទ រួមទាំងការរើសអើងលើក្រុមអ្នកស្រឡាញ់ភេទដូចគ្នាផងដែរ។



### ៣.២.២ សិទ្ធិទទួលបានសមភាពអាពាហ៍ពិពាហ៍

- មាត្រា ១៦ (១) នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សចែងថា «*មនុស្សប្រុសស្រីដល់អាយុគ្រប់ការ មានសិទ្ធិរៀបអាពាហ៍ពិពាហ៍ និងកសាងគ្រួសារដោយមិនប្រកាន់ពូជសាសន៍ សញ្ជាតិ ឬសាសនាឡើយ*»។ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស



នេះពុំមានបញ្ជាក់ពាក្យពេចន៍ណាមួយជាក់លាក់ បដិសេធនូវសិទ្ធិក្នុងការរៀបអាពាហ៍ពិពាហ៍ភេទដូចគ្នាឡើយ។

- មាត្រា ២៣ (២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានបញ្ញត្តិថា «*សិទ្ធិរបស់មនុស្សប្រុស ស្រីពេញវ័យក្នុងការរៀបអាពាហ៍ពិពាហ៍ និងក្នុងការកសាងគ្រួសារត្រូវតែទទួលស្គាល់*»។ នេះគឺជាបញ្ញត្តិដែលមានខ្លឹមសារទូលំទូលាយ និងច្បាស់ជាងខ្លឹមសារមានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។ ទោះជាដូច្នេះក្តី ករណី **ចូសលីន** និងប្រទេសនូវែលសេឡង់[15] ដែលមានក្តីក្តាំ បានដាក់បណ្តឹងជាលក្ខណៈបុគ្គល និងត្រូវបានគណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិលើកមកពិភាក្សា ហើយគណៈកម្មាធិការសិទ្ធិមនុស្សបានបញ្ជាក់ថាមាត្រា ២៣ (២) នេះពុំបានការពារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នាក្នុងការរៀបអាពាហ៍ពិពាហ៍ឡើយ។ ចំណុចគួរកត់សម្គាល់នោះនៅត្រង់ថា សេចក្តីសម្រេចនេះមានអាយុកាល១៥ ឆ្នាំមកហើយ ហើយទោះជាយ៉ាងណាសេចក្តីសម្រេចនេះមានអំណាចតែលើបញ្ហានេះប៉ុណ្ណោះ។
ទោះបីជាច្បាប់សិទ្ធិមនុស្សអន្តរជាតិមិនទាន់បានទទួលស្គាល់សិទ្ធិជាក់លាក់ចំពោះសមភាពអាពាហ៍-ពិពាហ៍ក្តី តែបានធានានូវសមភាព និងការមិនរើសអើងនៅគ្រប់វិស័យក្នុងជីវភាពរស់នៅ។
- គោលការណ៍ទី ២៤ នៃគោលការណ៍យ៉កយ៉ាកាតា ចែងថា « *បុគ្គលគ្រប់រូបមានសិទ្ធិក្នុងការកសាងគ្រួសារ ដោយមិនគិតពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ* »។ តាមទំនៀមទម្លាប់ពីបុរាណកាលមកអាពាហ៍ពិពាហ៍គឺជាផ្នែកមួយដ៏សំខាន់នៃការកសាងគ្រួសារ។ ការបដិសេធលទ្ធភាពនៃការរៀបអាពាហ៍-ពិពាហ៍របស់គូស្រករស្រឡាញ់ភេទដូចគ្នា គឺជាការដកហូតសិទ្ធិក្នុងការកសាងគ្រួសាររបស់ពួកគេផងដែរ។
- គោលការណ៍ទី ១៣ នៃគោលការណ៍យ៉កយ៉ាកាតាចែងថា «*បុគ្គលគ្រប់រូប មានសិទ្ធិទទួលបានសុវត្ថិភាពសង្គម និងវិធានការការពារសង្គមឯទៀត ដោយគ្មានការរើសអើងដោយសារតែនិន្នាការភេទ ឬ អត្តសញ្ញាណយេនឌ័រនោះឡើយ*»។ នៅក្នុងដែនយុត្តាធិការភាគច្រើន ជាក់ស្តែងដូចនៅប្រទេសកម្ពុជា អត្ថប្រយោជន៍នៃការការពារសង្គមកើតចេញពីអាពាហ៍ពិពាហ៍។ ការបដិសេធសិទ្ធិរបស់ដៃគូឥន្ទធនូក្នុងការរៀបអាពាហ៍ពិពាហ៍ជាការផាត់ពួកគេចេញមិនឱ្យទទួលបានសិទ្ធិជាច្រើន ដែលគូស្រកររៀបអាពាហ៍ពិពាហ៍រួចហើយត្រូវទទួលបាន។
- អនុសាសន៍ទី៥៥ (១១០.៥៥) ដែលរាជរដ្ឋាភិបាលកម្ពុជាបានទទួលយកនៅក្នុងកិច្ចប្រជុំលើកទី៣២ នៃដំណើរការពិនិត្យជាសកលតាមកាលកំណត់ជុំទី៣បានផ្តល់អនុសាសន៍ឱ្យធ្វើវិសោធនកម្មលើមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញដើម្បីអនុញ្ញាតឱ្យគូស្រករអ្នកស្រឡាញ់ភេទដូចគ្នាអាចរៀបអាពាហ៍ពិពាហ៍បាន

[15] គណៈកម្មាធិការសិទ្ធិមនុស្សសហប្រជាជាតិ បណ្តឹងលេខ ៩០២/១៩៩ ឯកសារអង្គការសហប្រជាជាតិលេខ ក/៥៧/៤០ ២១៤ (ឆ្នាំ២០០២)

- ទោះយ៉ាងនេះក្តី អនុសាសន៍នោះនៅមិនទាន់បានអនុវត្តនៅឡើយ។




## ៣.២.៣ សិទ្ធិក្នុងការកសាងគ្រួសារ /សិទ្ធិសុំកូន

សិទ្ធិសុំកូនសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា ត្រូវបានលើកឡើងនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។



- គោលការណ៍ទី២៤ នៃគោលការណ៍យ៉កយ៉ាកាតា លើកឡើងទាក់ទងនឹងសិទ្ធិក្នុងការកសាងគ្រួសារ ព្រមទាំងបានបញ្ជាក់អំពីសិទ្ធិរបស់ដៃគូឥន្ទធនូក្នុងការសុំកូនផងដែរ។ គោលការណ៍នេះបញ្ជាក់ថា «*គ្រួសារកើតឡើងតាមទម្រង់ផ្សេងៗ*» និងជំរុញឱ្យរដ្ឋ «*ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការចាំបាច់ផ្សេងៗទៀត ដើម្បីធានាថាបុគ្គលគ្រប់រូបទទួលបានសិទ្ធិក្នុងការកសាងគ្រួសារ ដោយរួមទាំងទទួលបានសិទ្ធិក្នុងការសុំកូន [.....] ដោយគ្មានការរើសអើងលើនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ*»។



- មាត្រា ២១ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារចែងថា «*ប្រព័ន្ធសុំកូនត្រូវធានាថា ឧត្តមប្រយោជន៍របស់កុមារត្រូវស្ថិតក្នុងការពិចារណាខ្ពស់បំផុត*»។ មាត្រា ២១ ត្រូវបានបកស្រាយថាជាការទទួលស្គាល់សិទ្ធិរបស់គូស្រករអ្នកស្រឡាញ់ភេទដូចគ្នា ដើម្បីមានសិទ្ធិក្នុងការចិញ្ចឹមកូនរួមគ្នានៅប្រទេសអៀឡង់។

### ៣.២.៤ សិទ្ធិទទួលបានការទទួលស្គាល់យេនឌ័រតាមផ្លូវច្បាប់



ការទទួលស្គាល់យេនឌ័រតាមផ្លូវច្បាប់តម្រូវឱ្យមានការដាក់ចេញនូវនីតិវិធីច្បាប់និងរដ្ឋបាលសម្រាប់អនុវត្តដែលអនុញ្ញាតឱ្យអ្នកប្តូរយេនឌ័រអាចកំណត់អត្តសញ្ញាណយេនឌ័រដោយខ្លួនឯងបាន ហើយមានបញ្ជាក់នៅក្នុងឯកសារសម្គាល់អត្តសញ្ញាណផ្លូវការដូចជា សំបុត្រកំណើត អត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន និងប័ណ្ណបើកបរជាដើម។

- គោលការណ៍ទី ៣ នៃគោលការណ៍យ៉កយ៉ាកាតា ផ្តល់សិទ្ធិដល់មនុស្សគ្រប់រូបក្នុងការទទួលបានការទទួលស្គាល់នៅគ្រប់ទីកន្លែងថាជាមនុស្សចំពោះមុខច្បាប់។ គោលការណ៍នេះតម្រូវឱ្យរដ្ឋ «*ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាឱ្យបានថា នីតិវិធីដែលរដ្ឋចេញលិខិតស្នាមបញ្ជាក់អំពីភេទ/យេនឌ័ររបស់បុគ្គលនីមួយៗរួមមាន សំបុត្រកំណើត លិខិតឆ្លងដែន ឯកសារបោះឆ្នោត និងឯកសារផ្សេងទៀត ពិតជាឆ្លុះបញ្ចាំងពីអត្តសញ្ញាណយេនឌ័រ ដែលត្រូវបានកំណត់ដោយសាមីខ្លួននោះផ្ទាល់*»។

ក្នុងខណៈពេលដែលគ្មានសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិណាមួយ ទទួលស្គាល់សិទ្ធិក្នុងការទទួលស្គាល់យេនឌ័រតាមផ្លូវច្បាប់ថាជាសិទ្ធិឯករាជ្យទេនោះការទទួលស្គាល់យេនឌ័រតាមផ្លូវច្បាប់ជារឿងចាំបាច់សម្រាប់អ្នកប្តូរយេនឌ័រដើម្បីទទួលបានសិទ្ធិមនុស្សដទៃទៀត ដូចជា៖

- សិទ្ធិរួចផុតពីការរើសអើងមានចែងក្នុងមាត្រា ២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ព្រមទាំងមាត្រា ៧ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។
- សិទ្ធិក្នុងការទទួលស្គាល់គ្រប់ទីកន្លែងក្នុងនាមជាមនុស្សចំពោះមុខច្បាប់ មានចែងក្នុងមាត្រា ១៦ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងមាត្រា ៦ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។
- សិទ្ធិក្នុងការអភិវឌ្ឍដោយសេរីនូវបុគ្គលិកលក្ខណៈរបស់ខ្លួន មានចែងក្នុងមាត្រា ២៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។

ក្នុងអនុសាសន៍ទី៤៥ (១១០.៤៥) ដែលរាជរដ្ឋាភិបាលកម្ពុជាបានទទួលយកនៅក្នុងកិច្ចប្រជុំលើកទី ៣២ នៃដំណើរការពិនិត្យជាសកលតាមកាលកំណត់ជុំទី៣ បានផ្តល់អនុសាសន៍ឱ្យបង្កើតច្បាប់ទទួលស្គាល់យេនឌ័រ។



### ៣.២.៥ សិទ្ធិទទួលបានការងារ



- មាត្រា ៦ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ទទួលស្គាល់សិទ្ធិធ្វើការងារ រួមមាន «*សិទ្ធិរបស់មនុស្សគ្រប់រូប មានលទ្ធភាពចិញ្ចឹមជីវិតដោយការងារដែលជ្រើសរើស ឬព្រមទទួលយកដោយសេរី*»។ មាត្រា ៦ នៃកតិកាសញ្ញានេះ ត្រូវបានបកស្រាយយ៉ាងច្បាស់អំពីអត្ថន័យទីផ្សារការងារដែលមានន័យថាទីផ្សារការងារត្រូវតែបើកចំហសម្រាប់មនុស្សគ្រប់រូប ដោយគ្មានការរើសអើងណាមួយឡើយ ក្នុងនោះរួមទាំងការរើសអើងផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទផងដែរ[16]។
- មាត្រា ៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ទទួលស្គាល់ «*សិទ្ធិរបស់បុគ្គលគ្រប់រូបក្នុងការទទួលបាននូវលក្ខខណ្ឌការងារត្រឹមត្រូវ និងប្រកបដោយអំណោយផលដែលជានាដាពិសេសនូវ [....] ឱកាសដូចគ្នាសម្រាប់មនុស្សគ្រប់រូប ដើម្បីបានឡើងឋានៈក្នុងការងារ ទៅកម្រិតខ្ពស់សមស្រប ដោយមិនពិចារណាទៅលើអ្វីផ្សេងក្រៅពីអតីតភាពការងារ និងសមត្ថភាព*»។
- អនុសញ្ញាលេខ១១១ នៃអង្គការពលកម្មអន្តរជាតិ ស្តីពីការរើសអើងក្នុងការងារ និងមុខរបរ បញ្ជាក់យ៉ាងច្បាស់អំពីការលើកកម្ពស់ « *ឱ្យមានឱកាស និងការទទួលផលស្មើភាពគ្នាក្នុងមុខរបរ និងការងារសំដៅលុបបំបាត់រាល់ការរើសអើងដូចមានចែងក្នុងអនុសញ្ញានេះ* »។ និយមន័យរបស់ពាក្យ គ្មានការរើសអើង រាប់បញ្ចូលទាំង «*ការប្រកាន់ ការបដិសេធ ឬសេចក្តីស្រឡាញ់ ដែលមានឥទ្ធិពលនាំឱ្យបាត់បង់ ឬបន្ទច់បង្អាក់ឱកាសឬការទទួលផលស្មើភាពគ្នាក្នុងមុខរបរ ឬការងារ* »។ លើសពីនេះ អនុសាសន៍ចំនួន២ ទៀតនៃអង្គការពលកម្មអន្តរជាតិ បានបញ្ជាក់បន្ថែមលើនិន្នាការភេទថាជាមូលដ្ឋានមួយនៃការគ្មានការរើសអើង។
- គោលការណ៍យ៉កយ៉ាកាតាទី១២ «*មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការងារធ្វើ និងជ្រើសរើសការងារដោយសេរី ទទួលបានលក្ខខណ្ឌការងារត្រឹមត្រូវ និងពេញចិត្ត និងមានកិច្ចការងារប្រឆាំងនឹងភាពអត់ការងារធ្វើ ដោយមិនមានការរើសអើង ពីហេតុនៃនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រនោះឡើយ* »។
- គោលការណ៍យ៉កយ៉ាកាតាទី២៥ «*ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិ [.....] ទទួលបានសិទ្ធិពេញលេញក្នុងការចូលរួមក្នុងជីវភាពសាធារណៈ និងនយោបាយ រួមទាំងសេវាកម្មរដ្ឋាភិបាល និងការងារនៅក្នុងមុខងារសាធារណៈគ្រប់កម្រិតទាំងអស់ ទាំងសេវាកម្មផ្នែកប៉ូលីស និងយោធា ដោយមិនរើសអើង ហើយត្រូវបានគោរពទាំងស្រុងលើនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ* »។
- ការលុបបំបាត់ការរើសអើងទាក់ទងនឹងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទនៅក្នុងវិស័យការងារអាចចូលរួមសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

[16] គណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីសិទ្ធសេដ្ឋកិច្ច សង្គម និងវប្បធម៌ 'យោបល់ទូទៅលេខ១៨៖ សិទ្ធិក្នុងការធ្វើការ ( មាត្រា៦ នៃកតិកាសញ្ញា ) ឯកសារអង្គការសហប្រជាជាតិលេខ E/C.12/GC/18 (ឆ្នាំ២០០៦), para 12 (b) (i) <http://www.refworld.org/docid/4415453b4.html>.

គោលដៅទី១ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព គ្មានភាពក្រីក្រ អនុញ្ញាតឱ្យបុគ្គលអ្នកស្រឡាញ់ភេទដូចគ្នាអាចចូលរួមនិងទទួលបានការងារមួយដើម្បីបង្កើនកំណើនស្ថានភាពសេដ្ឋកិច្ចរបស់ខ្លួន។

គោលដៅទី៨ នៃគោលដៅអភិវឌ្ឍន៍ប្រកដដោយចីរភាព ការងារសមរម្យ និងកំណើនសេដ្ឋកិច្ច លើកកម្ពស់បុគ្គលអ្នកស្រឡាញ់ភេទដូចគ្នាសម្រេចឱ្យបាន «ការងារពេញលេញប្រកបដោយផលិតភាព និងការងារសមរម្យ» ចំណុចដៅ ៨.៥។

គោលដៅទី ១០ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព កាត់បន្ថយវិសមភាព ធានានូវឱកាសការងារស្មើភាពគ្នា និងកាត់បន្ថយវិសមភាព[17]។



[17] ម.ស.ម.ក "សិទ្ធិមិនត្រូវបានរើសអើងដោយផ្អែកលើមូលដ្ឋាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ និងការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទក្នុងវិស័យការងារនៅប្រទេសកម្ពុជា" (ខែធ្នូ ឆ្នាំ២០១៩) <https://cchrcambodia.org/admin/media/report/report/english/CCHR_SOGIE%20Employment%20Research%20Report_ENG_Final_24Jan2020.pdf>; មហាសន្និបាតអង្គការសហប្រជាជាតិ "ការផ្លាស់ប្រែពិភពលោករបស់យើង៖ របៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព" (ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥) ឯកសារអង្គការសហប្រជាជាតិលេខ ក/ដំណោះស្រាយ/៧០/១ គោលដៅទី៨ ចំណុចដៅទី ៨.៥ <http://www.un.org/en/development/desa/population/migration/generalassembly/docs/globalcompact/A_RES_70_1_E.pdf>.

## ៣.២.៦ សិទ្ធិទទួលបានសុខុមាលភាព សុខភាពផ្លូវភេទ និងសុខភាពបន្តពូជ

- មាត្រា ១២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌បានទទួលស្គាល់ *«បុគ្គលគ្រប់រូបមានសិទ្ធិទទួលបាននូវទាំងសុខភាពរាងកាយ និងផ្លូវចិត្តតាមកម្រិតបទដ្ឋានខ្ពស់បំផុតមួយ»*។
- សេចក្តីពន្យល់ទូទៅលេខ ២២ លើមាត្រា១២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌បញ្ជាក់ថាក្រុមមនុស្សទាំងអស់អាចទទួលបាន *«ស្មើភាពគ្នាក្នុងកម្រិតដូចគ្នា គុណភាពសុខភាពផ្លូវភេទ និងមណ្ឌលសុខភាពដែលមានបទដ្ឋាន ព័ត៌មាន ទំនិញ និងសេវាកម្ម និងការអនុវត្តសិទ្ធិផ្នែកសុខភាពផ្លូវភេទ និងសុខភាពបន្តពូជដោយគ្មានការរើសអើងណាមួយឡើយ»*។ ដូច្នេះនៅពេលក្រុមជាក់លាក់ណាមួយត្រូវទទួលសេវាថែទាំសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ចាំបាច់ត្រូវមានការយកចិត្តទុកដាក់ខ្ពស់ក្នុងការមើលថែ។
- គោលការណ៍ទី១៧ នៃគោលការណ៍យ៉កយ៉ាកាតាចែងថា *«បុគ្គលគ្រប់រូប មានសិទ្ធិទទួលបានកម្រិតសុខភាពទាំងខាងរាងកាយ និងខាងផ្លូវចិត្តខ្ពស់បំផុត តាមដែលអាចធ្វើទៅបាន ដោយគ្មានការរើសអើងពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រនោះឡើយ។ សុខភាពផ្លូវភេទ និងសុខភាពបន្តពូជ គឺជាមូលដ្ឋានគ្រឹះនៃសិទ្ធិនេះ»*។ តាមគោលការណ៍ទី១៧ នេះ បានផ្តល់អនុសាសន៍ឱ្យរដ្ឋត្រូវតែជានាលើចំណុចមួយចំនួនផ្សេងទៀតផងដែរដូចជា៖
  - *«សេវាថែទាំសុខភាព ទំនិញ និងសេវាកម្មផ្សេងៗ ត្រូវបានបង្កើតឡើងដើម្បីជួយលើកកម្ពស់ស្ថានភាពសុខភាព និងឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់មនុស្សគ្រប់រូប ដោយគ្មានការរើសអើងពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រនោះឡើយ»* និង
  - *«ផ្តល់ភាពងាយស្រួលដល់បុគ្គលទាំងឡាយណាដែលស្វែងរកការប្រែរាងកាយដែលជាប់ទាក់ទងនឹងការវះកាត់ប្តូរភេទដើម្បីឱ្យពេញលក្ខណៈ ការទទួលបានការព្យាបាល ការថែទាំ និងដោយគ្មានការរើសអើង»*។
- គោលដៅទី ៣ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព៖ សុខភាពល្អ និងសុខុមាលភាព។ ដើម្បីសម្រេចបានគោលដៅទី ៣ រដ្ឋត្រូវតែអនុវត្តតាមចំណុចដៅ ៣.៧ បានកំណត់ថា *«ធានាថាការទទួលបានជាសកលនូវសេវាថែទាំសុខភាពផ្លូវភេទ និងសេវាសុខភាពបន្តពូជ រួមទាំងផែនការគ្រួសារ ព័ត៌មាន និងការអប់រំ និងការធ្វើសមាហរណកម្មសុខភាពបន្តពូជទៅក្នុងកម្មវិធីនិងយុទ្ធសាស្ត្រជាតិ»* ។
- អនុសាសន៍ទី៥០ (១១០.៥០) ដែលរាជរដ្ឋាភិបាលកម្ពុជាបានទទួលយកនៅក្នុងកិច្ចប្រជុំលើកទី៣២ នៃដំណើរការពិនិត្យជាសកលតាមកាលកំណត់ ជុំទី៣ បានផ្តល់អនុសាសន៍ឱ្យអនុម័តនៅច្បាប់ និង

គោលនយោបាយប្រឆាំងនិងការរើសអើង និងអំពើហិង្សាទាក់ទងនឹងនិន្នាការភេទ ឬយេនឌ័រក្នុងវិស័យនានារួមទាំងវិស័យសុខាភិបាលផងដែរ។



# មេរៀនទី ៤៖ ទស្សនៈអន្តរជាតិលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ

## ៤.១ បណ្តាប្រទេសដែលដាក់ទោសទណ្ឌលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទរបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា[18]

ច្បាប់ជាតិនៅក្នុងប្រទេសកម្ពុជា មិនមានកំណត់បទល្មើសព្រហ្មទណ្ឌ ទៅលើអ្នកស្រឡាញ់ភេទដូចគ្នានោះទេ។ ប៉ុន្តែគួរឱ្យសោកស្តាយប្រទេសជាច្រើននៅជុំវិញពិភពលោកមានច្បាប់ផ្តន្ទាទោសទៅលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទរបស់អ្នកស្រឡាញ់ដូចគ្នា។

- **រដ្ឋចំនួន៦៩** ចាត់ទុកឥរិយាបថ ឬទំនាក់ទំនងផ្លូវភេទរបស់អ្នកមានភេទដូចគ្នាថាជាអំពើខុសច្បាប់
- **រដ្ឋចំនួន ១១** មានបទប្បញ្ញត្តិកំណត់ពីការដាក់ទោសប្រហារជីវិតចំពោះអ្នកដែលមានទំនាក់ទំនងផ្លូវភេទលើភេទដូចគ្នា[19] រដ្ឋទាំងនោះរួមមាន៖

**ពាក្យគន្លឹះសំខាន់ៗសម្រាប់មេរៀនទី ៤**

- **អនីតិសង្វាស៖** ការទទួលស្គាល់ភាពជាដៃគូ "ដូចអាពាហ៍ពិពាហ៍" របស់បុគ្គលពីរនាក់ដែលផ្តល់ឱ្យគូស្រករទទួលបាននូវអត្ថប្រយោជន៍ស្របច្បាប់មួយចំនួន។
- **អាពាហ៍ពិពាហ៍៖** ការទទួលស្គាល់ស្របច្បាប់របស់មនុស្សពីរនាក់ជាដៃគូក្នុងទំនាក់ទំនងផ្ទាល់ខ្លួន។
- **ប្តីប្រពន្ធប្តូរភេទឆ្លងប្រទេស៖** ប្តីប្រពន្ធដែលមានដៃគូគឺជាពលរដ្ឋមកពីប្រទេសផ្សេងៗគ្នា។
- **យេនឌ័រពីកំណើត៖** បុគ្គលដែលមានអត្តសញ្ញាណយេនឌ័រ និងការបង្ហាញទំនោរយេនឌ័រស្របតាមភេទពីកំណើតរបស់ពួកគេ។
- **ការក្រៀវ៖** ការវះកាត់ដែលមានបំណងចង់ឱ្យបុគ្គលណាម្នាក់លែងមានលទ្ធភាពក្នុងការបន្តពូជ ឬការមានកូន។
- **ការទទួលស្គាល់យេនឌ័រស្របច្បាប់៖** ជាដំណើរការនៃការផ្លាស់ប្តូរនៃព័ត៌មានយេនឌ័រលើឯកសារច្បាប់ដើម្បីទទួលស្គាល់អត្តសញ្ញាណយេនឌ័ររបស់បុគ្គលណាម្នាក់ដែលសាមីខ្លួនពេញចិត្ត។
- **បុគ្គលមិនកំណត់យេនឌ័ររបស់ខ្លួន៖** ជាបុគ្គលដែលមិនកំណត់ខ្លួនឯង ឬមិនអនុលោមតាមអត្តសញ្ញាណយេនឌ័រនៃភាពជាបុរស និងភាពជាស្ត្រី។

---

[18] មាតិកានៅក្នុងមេរៀននេះ មានភាពត្រឹមត្រូវស្របទៅនឹងពេលវេលានៃការផ្សព្វផ្សាយ (ខែធ្នូ) ២០២១។ ប្រទេសនានាផ្លាស់ប្តូរច្បាប់របស់ខ្លួនជាញឹកញាប់ដើម្បីការពារ ឬដាក់ឱ្យមានទោសទៅលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ។

[19] សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាអន្តរជាតិ ILGA «ការរើសអើងលើអ្នកស្រឡាញ់ភេទដូចគ្នាដោយមានការគាំទ្រពីរដ្ឋ៖ ការធ្វើបច្ចុប្បន្នភាពលើទិដ្ឋភាពទូទៅនៃច្បាប់សកល» (ឆ្នាំ២០២០) <https://ilga.org/downloads/ILGA_World_State_Sponsored_Homophobia_report_global_legislation_overview_update_December_2020.pdf>.



អាហ្វហ្គានីស្ថាន



ព្រុយណេ



អ៊ីរ៉ង់



ម៉ូរីតានី



នីហ្សេរីយ៉ា



ប៉ាគីស្ថាន



កាតា



អារ៉ាប់ប៊ីសាអូឌីត



សូម៉ាលី



អេមីរ៉ាត់អារ៉ាប់រួម



យេម៉ែន

## ៤.២ ប្រទេសមួយចំនួនដែលមានការទទួលស្គាល់ និងការពារសិទ្ធិនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ

មានរដ្ឋជាច្រើនបានប្រកាន់ជំហររបស់ខ្លួនយ៉ាងសកម្មក្នុងការចូលរួម និងអនុញ្ញាតឱ្យបុគ្គលអនុវត្តសិទ្ធិទាក់ទងនឹងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទរបស់ពួកគេដោយសេរី។ បណ្តាប្រទេសជាច្រើនជុំវិញពិភពលោកបានបង្កើតច្បាប់ហាមឃាត់ការរើសអើងដោយផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ ដូចជាការអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ភេទដូចគ្នា ការផ្តល់ឱ្យនូវសិទ្ធិស្មើភាពគ្នាក្នុងការសុំកូនសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា និងអនុញ្ញាតឱ្យមានការទទួលស្គាល់យេនឌ័រតាមផ្លូវច្បាប់សម្រាប់អ្នកប្តូរយេនឌ័រ។

### ៤.២.១ ការមិនរើសអើង

បណ្តារដ្ឋជាច្រើនជុំវិញពិភពលោក បានចាត់វិធានការយ៉ាងសកម្មដើម្បីប្រយុទ្ធប្រឆាំងនឹងការរើសអើងចំពោះអ្នកស្រឡាញ់ភេទដូចគ្នា[20] ។

១២ បណ្តារដ្ឋមួយចំនួនមានរដ្ឋធម្មនុញ្ញដើម្បីការពារប្រឆាំងទៅនឹងការរើសអើងដោយផ្អែកលើនិន្នាការភេទ។

៦០ បណ្តារដ្ឋមួយចំនួនមានកិច្ចការពារ "ទូលំទូលាយ" ប្រឆាំងនឹងការរើសអើងដោយផ្អែកលើនិន្នាការភេទតាមរយៈក្រមព្រហ្មទណ្ឌ ឬច្បាប់សហព័ន្ធដើម្បីហាមឃាត់ការរើសអើង និងតាមរយៈបទប្បញ្ញត្តិរដ្ឋធម្មនុញ្ញមួយចំនួនហាមឃាត់ការរើសអើងទូទៅ។

[20] មាតិកានេះ មានភាពត្រឹមត្រូវស្របទៅនឹងពេលវេលានៃការផ្សព្វផ្សាយ (ខែធ្នូ) ២០២១។

៨១ បណ្ដារដ្ឋមួយចំនួនមានការការពារប្រឆាំងនឹងការរើសអើងលើនិន្នាការភេទនៅក្នុងបរិបទការងារ[21]។

៤៧ បណ្ដារដ្ឋមួយចំនួនចែងជាបទល្មើសព្រហ្មទណ្ឌចំពោះការរើសអើង និងការប្រព្រឹត្តអំពើហិង្សាដោយផ្អែកលើនិន្នាការភេទ។

៤៥ បណ្ដារដ្ឋមួយចំនួនហាមឃាត់លើការញុះញង់ឱ្យមានការស្អប់ខ្ពើម អំពើហិង្សា ឬការរើសអើងដោយផ្អែកលើនិន្នាការភេទ។

ទន្ទឹមនេះមានប្រទេសមួយចំនួនបានពង្រីកវិសាលភាពនៃកិច្ចការពាររបស់ខ្លួនកាន់តែទូលំទូលាយក្នុងចំណោមសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ដូចជាការហាមឃាត់ការរើសអើងដោយផ្អែកលើអត្តសញ្ញាណយេនឌ័រ[22] /ការបង្ហាញទំនោរយេនឌ័រ[23] ខណៈដែលប្រទេសភាគច្រើនផ្ដោតតែទៅលើការការពារលើនិន្នាការភេទជាមូលដ្ឋានសម្រាប់ការមិនរើសអើង។

### ៤.២.២. អាពាហ៍ពិពាហ៍ភេទដូចគ្នា

ប្រទេសកាន់តែច្រើនឡើងៗកំពុងផ្ដល់ភាពស្របច្បាប់ចំពោះអាពាហ៍ពិពាហ៍ភេទដូចគ្នា ឬការរួមសង្វាសភេទដូចគ្នា។




[21] នេះរួមបញ្ចូលទាំងប្រទេសមួយចំនួននៅអាស៊ីរួមមាន ប្រទេសម៉ុងហ្គោលី នេប៉ាល់ តៃវ៉ាន់ និងថៃ។

[22] រដ្ឋធម្មនុញ្ញនៃប្រទេសគុយបា (ឆ្នាំ២០១៩) មាត្រា ៤២។

[23] ច្បាប់រើសអើងរបស់ប្រទេសស៊ុយអែត (ឆ្នាំ២០០៨)។

ដំណាក់កាលផ្សព្វផ្សាយ៖

៣០ រដ្ឋផ្តល់ភាពស្របច្បាប់ចំពោះអាពាហ៍ពិពាហ៍ភេទដូចគ្នា

៣១ រដ្ឋផ្តល់ភាពស្របច្បាប់ចំពោះការរួមបវេណីភេទដូចគ្នា

**អាពាហ៍ពិពាហ៍**

ការទទួលស្គាល់តាមផ្លូវច្បាប់នូវភាពជាដៃគូរួមជាមួយលទ្ធភាពក្នុងការអនុវត្តសិទ្ធិនានា ដូចជា ករណីកិច្ចថែទាំកុមារ សិទ្ធិក្នុងការសុំកូន ការយកពន្ធ អាណាព្យាបាលលើកុមារ និងសិទ្ធិលើទ្រព្យសម្បត្តិ។ល។

និង

**អនីតិសង្វាស**

ការទទួលស្គាល់តាមផ្លូវច្បាប់នូវភាពជាដៃគូ តែមានការរឹតត្បិតសិទ្ធិមួយចំនួន។ គូស្រករពុំទទួលបានឋានៈ "អាពាហ៍ពិពាហ៍" ទេ។ ការរួមអនីតិសង្វាសត្រូវគេមើលឃើញថាទទួលបានឋានៈនៅក្នុងកម្រិតទី២ ហើយពុំទទួលបានសមភាពពេញលេញសម្រាប់គូស្រករភេទដូចគ្នាទេ។

អនីតិសង្វាសមានភាពខុសគ្នាជុំវិញពិភពលោកអាស្រ័យលើនិយមន័យ និងបទប្បញ្ញត្តិរបស់ប្រទេសនីមួយៗដែលចែងអំពីអនីតិសង្វាសនេះ ជាមួយនឹងសិទ្ធិ និងការទទួលខុសត្រូវផ្សេងៗ។ នៅក្នុងបណ្តាប្រទេសមួយចំនួន ដៃគូដែលរួមអនីតិសង្វាសមានសិទ្ធិ និងកាតព្វកិច្ចស្មើរតែទាំងអស់ដូចគ្នានឹងដៃគូដែលបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ដែរ។ ដោយឡែកប្រទេសមួយចំនួនទៀត រឹតត្បិតសិទ្ធិមួយចំនួនរបស់ដៃគូដែលរួមអនីតិសង្វាស ដូចជា រឹតត្បិតសិទ្ធិក្នុងការសុំកូនជាដើម។

**ករណីសិក្សា៖ តៃវ៉ាន់-ប្រជាជាតិអាស៊ីដំបូងគេដែលផ្តល់ភាពស្របច្បាប់ចំពោះអាពាហ៍ពិពាហ៍ភេទដូចគ្នា**[24]

ក្នុងឆ្នាំ២០១៩ តៃវ៉ាន់បានក្លាយជាប្រទេសក្នុងតំបន់អាស៊ីដំបូងគេ ដែលផ្តល់ភាពស្របច្បាប់ចំពោះអាពាហ៍ពិពាហ៍ភេទដូចគ្នា។ ក្នុងឆ្នាំ២០១៧ តុលាការធម្មនុញ្ញរបស់តៃវ៉ាន់បានរកឃើញថា ច្បាប់នាពេលបច្ចុប្បន្នដែលផ្តល់និយមន័យលើ "ការរួមសង្វាស" រវាងបុរស និងស្ត្រីមិនផ្អែកលើទិដ្ឋភាពជាក់ស្តែងឡើយ និងបានលើកឡើងថានោះជាការរារាំងគូស្រករភេទដូចគ្នាពីការរៀបអាពាហ៍ពិពាហ៍ ដែលបំពានទៅលើ "សេរីភាព

24 សូមមើលឧទាហរណ៍៖ តុលាការកំពូលរបស់តៃវ៉ាន់គាំទ្រដល់អាពាហ៍ពិពាហ៍ភេទដូចគ្នា ថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០១៧ <https://www.theguardian.com/world/2017/may/24/taiwans-top-court-rules-in-favour-of-same-sex-marriage>; NPR, សភាតៃវ៉ាន់ធ្វើឱ្យអាពាហ៍ពិពាហ៍ភេទដូចគ្នាស្របច្បាប់ជាលើកដំបូងនៅអាស៊ីថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ២០១៩ <https://www.npr.org/2019/05/17/724222598/taiwans-parliament-legalizes-same-sex-marriage-a-first-in-asia>; ព័ត៌មានពីតុលាការតៃវ៉ាន់ក្លាយជាប្រទេសអាស៊ីដំបូងគេដែលធ្វើឱ្យអាពាហ៍ពិពាហ៍ភេទដូចគ្នាមានលក្ខណៈស្របច្បាប់នៅ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ ២០១៩ <https://www.courthousenews.com/taiwan-becomes-first-asian-nation-to-legalize-same-sex-marriage/>; វ៉ាស៊ីនតោនប៉ុស្ដិ៍៖ កោះតៃវ៉ាន់ក្លាយជាប្រទេសដំបូងគេនៅអាស៊ីដែលធ្វើឱ្យអាពាហ៍ពិពាហ៍ភេទដូចគ្នាមានលក្ខណៈស្របច្បាប់នៅថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ២០១៩ <https://www.washingtonpost.com/world/asia_pacific/taiwan-becomes-first-country-in-asia-to-legalize-same-sex-marriage/2019/05/17/d60e511e-7893-11e9-bd25-c989555e7766_story.html>; រ៉យទ័រ៖ ភាពរីករាយមិនធ្លាប់មានបន្ទាប់ពីកោះតៃវ៉ាន់មួយឆ្នាំបន្ទាប់ ពីអាពាហ៍ពិពាហ៍ភេទភេទដូចគ្នាដំបូងរបស់អាស៊ីនៅ ថ្ងៃទី២០ ខែឧសភា ឆ្នាំ ២០២០ <https://www.reuters.com/article/us-taiwan-lgbt-rights-feature-trfn/happily-ever-after-eludes-taiwan-a-year-after-asias-first-gay-marriages-idUSKBN22X03A>; Taipei Times៖ អាពាហ៍ពិពាហ៍ភេទដូចគ្នា៖ មួយឆ្នាំបន្ទាប់ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ ២០២០ <https://www.taipeitimes.com/News/editorials/archives/2020/05/17/2003736539>.

របស់ប្រជាពលរដ្ឋក្នុងការរៀបអាពាហ៍ពិពាហ៍ ″និង‶ សិទ្ធិស្មើភាពគ្នារបស់ប្រជាពលរដ្ឋ″។ បន្ទាប់មកតុលាការធម្មនុញ្ញបានសម្រេចបង្គាប់ឱ្យស្ថាប័នសភាធ្វើវិសោធនកម្មច្បាប់នានា ឬអនុម័តច្បាប់ស្តីពីការរៀបអាពាហ៍ពិពា-ហ៍ភេទដូចគ្នាក្នុងរយៈពេលពីរឆ្នាំ។ សេចក្តីសម្រេចនេះ គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្រ្តដ៏សំខាន់សម្រាប់សិទ្ធិស្មើភាពគ្នារបស់អ្នកស្រឡាញ់ភេទដូចគ្នាក្នុងតំបន់អាស៊ី។ ទោះបីមានការប្រឆាំងខ្លាំងពីសំណាក់ក្រុមសាសនាក៏ដោយ ក៏នៅក្នុងឆ្នាំ២០១៩ ស្ថាប័នសភាតៃវ៉ាន់ បានអនុម័តច្បាប់ស្តីពីអាពាហ៍ពិពាហ៍ភេទដូចគ្នា។ តាំងពីពេលនោះមកមានគូស្រករស្រឡាញ់ភេទដូចគ្នាប្រមាណ ៣៥០០ គូ បានរៀបអាពាហ៍ពិពាហ៍នៅប្រទេសតៃវ៉ាន់។

ទោះជាយ៉ាងណានៅក្នុងស្ថានភាពជាក់ស្តែងអាពាហ៍ពិពាហ៍ភេទដូចគ្នាគឺនៅតែរឿងពិបាកសម្រាប់មនុស្សជាច្រើន ជាពិសេសអ្នកស្រឡាញ់ភេទដូចគ្នាដែលមានដៃគូជាជនបរទេស។ ប្រជាពលរដ្ឋតៃវ៉ាន់ អាចរៀបការបានតែជាមួយជនបរទេសដែលមកពីប្រទេសដែលមានច្បាប់ទទួលស្គាល់អាពាហ៍ពិពាហ៍ភេទដូចគ្នាដែរតែប៉ុណ្ណោះ។ ដូច្នេះហើយ សម្រាប់គូស្រករអ្នកប្តូរភេទដែលរស់នៅតៃវ៉ាន់ ដែលមានដៃគូម្ខាងទៀតមកពីចិនដីគោកមិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ ដោយសារតែច្បាប់ចិនដីគោកមិនទទួលស្គាល់សិទ្ធិនេះទេ ដែលនោះនៅតែពុំផ្តល់សមភាពក្នុងការរៀបអាពាហ៍ពិពាហ៍ដដែល។ ផលលំបាកមួយទៀតនោះ គឺអនុញ្ញាតឱ្យមានអាពាហ៍ពិពាហ៍ភេទដូចគ្នា ប៉ុន្តែមានសិទ្ធិសុំកូនបានតែក្នុងរង្វង់ញាតិលោហិតខ្សែផ្ទាល់ប៉ុណ្ណោះ យ៉ាងហោចណាស់ជាប់សាច់ឈាមមួយក្នុងចំណោមពួកគេ។

**ករណីសិក្សា៖ ច្បាប់ស្តីពីអនីតិសង្វាសភេទដូចគ្នា**[25]

ក្នុងខែមិថុនា ឆ្នាំ២០២០ ទីស្តីការគណៈរដ្ឋមន្រ្តីថៃបានអនុម័តសេចក្តីព្រាងច្បាប់ស្តីពីអនីតិសង្វាសភេទដូចគ្នាដែលនឹងមានការទទួលស្គាល់ដៃគូរួមសង្វាសភេទដូចគ្នាដោយស្របច្បាប់។ ប្រសិនបើសេចក្តីព្រាងនេះចូលជាធរមាន នោះប្រទេសថៃនឹងក្លាយជាប្រជាជាតិអាស៊ីទីពីរដែលផ្តល់ភាពស្របច្បាប់ចំពោះការរួមសង្វាសភេទដូចគ្នា ហើយជាប្រទេសដំបូងគេបង្អស់នៅតំបន់អាស៊ីអាគ្នេយ៍ដែលមានការទទួលស្គាល់បែបនេះ។ ទោះបីជាសេចក្តីព្រាងច្បាប់នេះ មិនបានចែងជាក់លាក់ពីការរួមសង្វាសដៃគូភេទដូចគ្នាថាមានឋានៈដូចជា ‶អាពាហ៍-ពិពាហ៍″ ក្តីតែច្បាប់នេះអនុញ្ញាតឱ្យគូស្រករភេទដូចគ្នាមានសិទ្ធិកាន់តែប្រសើរ ជាងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ភេទដូចគ្នាក្នុងប្រទេសតៃវ៉ាន់។

ច្បាប់ស្តីពីអនីតិសង្វាសភេទដូចគ្នានឹងអនុញ្ញាតឱ្យគូស្រករភេទដូចគ្នា អាចមានលទ្ធភាពចុះបញ្ជីអំពីការរួមសង្វាសរបស់ពួកគេ ក្នុងនោះរួមទាំងសិទ្ធិសុំកូន សិទ្ធិទាមទារមរតក និងសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិរួមផងដែរ។ ដើម្បីចុះបញ្ជីក្លាយជាគូស្រករភេទដូចគ្នាបាន គូស្រករត្រូវមានអាយុយ៉ាងតិចណាស់ ១៧ឆ្នាំ ហើយភាគីម្ខាងទៀតត្រូវមានសញ្ជាតិជាជនជាតិថៃ ដើម្បីអនុញ្ញាតឱ្យគូស្រករប្តូរយេនឌ័រដែលមានដៃគូជាជនបរទេសមានសិទ្ធិ

[25] CNN, ច្បាប់ស្តីពីអនីតិសង្វាសភេទដូចគ្នានៅប្រទេសថៃ ថ្ងៃទី៩ ខែកក្កដា ឆ្នាំ ២០២០ <https://www.cnn.com/2020/07/09/asia/thailand-same-sex-union-bill-intl-hnk/index.html>; រ៉យទ័រ៖ គណៈរដ្ឋមន្រ្តីថៃគាំទ្រច្បាប់ដែលអនុញ្ញាតឱ្យមាននីតិសង្វាសភេទដូចគ្នា ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២០ <https://www.reuters.com/article/us-thailand-lgbt/thai-cabinet-backs-bill-allowing-same-sex-unions-idUSKBN2491W4>; Forbes, ប្រទេសថៃក្លាយជាប្រទេសអាស៊ីអាគ្នេយ៍ដំបូងគេដែលធ្វើឱ្យការរួមសង្វាសភេទដូចគ្នាមានលក្ខណៈស្របច្បាប់នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២០ <https://www.forbes.com/sites/alexandrasternlicht/2020/07/08/thailand-to-become-first-southeast-asian-country-to-legalize-same-sex-unions/#6e130b66584c>.

រួមសង្វាសក្នុងឋានៈជាគូស្រករភេទដូចគ្នា។ ប៉ុន្តែច្បាប់នេះ មិនបានផ្តល់សិទ្ធិ និងអត្ថប្រយោជន៍ដល់គូស្រករដែលបានរៀបអាពាហ៍ពិពាហ៍នោះទេ ដូចជា ការលើកលែងពន្ធ របបសន្តិសុខសង្គម និងសិទ្ធិខាងវេជ្ជសាស្ត្រ។ ចាប់តាំងពីប្រទេសថៃមិនអនុញ្ញាតឱ្យបុគ្គលម្នាក់ៗផ្លាស់ប្តូរការទទួលស្គាល់យេនឌ័រតាមផ្លូវច្បាប់នូវភេទដែលមានមកពីកំណើតរបស់ពួកគេមក សេចក្តីព្រាងច្បាប់នេះ អនុញ្ញាតឱ្យមានការរួមសង្វាសភេទដូចគ្នារវាងគូស្រករដែលមានយេនឌ័រស្របពីកំណើត។

សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាក្នុងប្រទេសថៃ យល់ឃើញថាច្បាប់ស្តីពីអនីតិសង្វាសមិនបានផ្តល់វិសាលភាពឱ្យបានគ្រប់គ្រាន់ និងចង់ឱ្យគូស្រករទាំងអស់ត្រូវបានចាត់ទុកថាជាគូស្វាមីភរិយាដែលបានរៀបការហើយ ដោយមិនគិតពីភេទ និងយេនឌ័រ។ សហគមន៍ខ្លះការមានយល់ថា ច្បាប់នេះគឺ "មានលក្ខណៈរើសអើងប្រឡាំប្រកូវ" និងចង់ឱ្យមានការប្រព្រឹត្តស្មើភាពគ្នាចំពោះមជ្ឈដ្ឋានផ្សេងៗក្នុងសង្គម។ ក្រុមអ្នកស្រឡាញ់ភេទដូចគ្នាក្នុងប្រទេសថៃកំពុងធ្វើការតស៊ូមតិដើម្បីឱ្យមានការកំណត់និយមន័យនៃអាពាហ៍ពិពាហ៍ដើម្បីឱ្យមានអព្យាក្រឹតភាពយេនឌ័រ និងឱ្យមានការកែសម្រួលឡើងវិញរវាងពាក្យថា "មនុស្សពីរនាក់"។

### ៤.២.៣ សិទ្ធិស្មើភាពគ្នាក្នុងការសុំកូន

ប្រទេសមួយចំនួនបានផ្តល់សិទ្ធិស្មើភាពគ្នាក្នុងការសុំកូនសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា។ ក្នុងពេលចងក្រងមេរៀននេះ មានការកត់ត្រា៖

២៨ រដ្ឋជាសមាជិកអង្គការសហប្រជាជាតិ អនុញ្ញាតជាក់លាក់សម្រាប់ការសុំកូនរួមគ្នា ដោយគូស្រករភេទដូចគ្នា។



## ៤.២.៤ ការទទួលស្គាល់យេនឌ័រស្របតាមផ្លូវច្បាប់

នៅក្នុងប្រទេសជាច្រើនពុំទទួលស្គាល់ស្របតាមផ្លូវច្បាប់ចំពោះអត្តសញ្ញាណយេនឌ័រតាមការកំណត់ដោយខ្លួនឯងនោះទេ ហើយប្រទេសខ្លះដែលមានច្បាប់ដែរតែច្បាប់ទាំងនោះបង្កនូវការរឹតត្បិតហួសហេតុ និងប៉ះពាល់ដល់អ្នកស្រឡាញ់ភេទដូចគ្នាទៀតផង។ មានការយល់ច្រឡំជាទូទៅថាការអនុម័តច្បាប់ស្តីពីការទទួលស្គាល់យេនឌ័រស្របតាមផ្លូវច្បាប់ជាជំហានវិជ្ជមានមួយសម្រាប់ការទទួលបានសិទ្ធិស្មើភាពគ្នា និងការទទួលស្គាល់អ្នកស្រឡាញ់ភេទដូចគ្នា។ ផ្ទុយមកវិញ ច្បាប់ស្តីពីការទទួលស្គាល់យេនឌ័រស្របតាមផ្លូវច្បាប់ ត្រូវបានគេយកមកអនុវត្តក្នុងន័យរារាំងបុគ្គលអ្នកស្រឡាញ់ភេទដូចគ្នាពីការទទួលបានសិទ្ធិពេញលេញ ហើយច្បាប់ខ្លះទៀតបានបង្កគ្រោះថ្នាក់ និង ផ្តល់ផលប៉ះពាល់ទាំងផ្លូវកាយ និងផ្លូវចិត្តចំពោះអ្នកប្តូរយេនឌ័រក្នុងរយៈពេលយូរទៀតផង។

### លក្ខខណ្ឌរឹតត្បិតលើការទទួលស្គាល់យេនឌ័រតាមផ្លូវច្បាប់

ឧបសគ្គរារាំងតាមរយៈការកំណត់នៃច្បាប់ស្តីពីការទទួលស្គាល់យេនឌ័រស្របតាមផ្លូវច្បាប់មួយចំនួននៅជុំវិញពិភពលោក រួមមាន៖

- ការព្យាបាលតាមបែបវេជ្ជសាស្ត្រ និងចិត្តសាស្ត្រក្នុងបរិមាណច្រើន។
- ការវះកាត់ រួមទាំងការតម្រូវឱ្យបុគ្គលម្នាក់ៗទទួលការវះកាត់ប្តូរយេនឌ័រទាំងស្រុង។
- ការក្រៀវដោយបង្ខំ។



ក្នុងពេលចងក្រងមេរៀននេះ មានការកត់ត្រា៖

- ៤៥ — រដ្ឋអនុញ្ញាតឱ្យមានការទទួលស្គាល់យេនឌ័រស្របតាមផ្លូវច្បាប់ ប៉ុន្តែរដ្ឋបានដាក់លក្ខខណ្ឌខ្លះជាឧបសគ្គរាំង និងលក្ខខណ្ឌតម្រូវមិនច្បាស់លាស់មួយចំនួនដើម្បីឱ្យមានការទទួលស្គាល់អត្តសញ្ញាណយេនឌ័រដែលបានកំណត់ដោយខ្លួនឯង។
- ៣០ — រដ្ឋមានច្បាប់ស្តីពីការទទួលស្គាល់យេនឌ័រស្របតាមផ្លូវច្បាប់ដែលជាវឌ្ឍនភាព និងមានឧបសគ្គតិចតួចក្នុងការទទួលបាននូវការទទួលស្គាល់តាមផ្លូវច្បាប់ចំពោះ អត្តសញ្ញាណយេនឌ័រតាមការកំណត់ដោយខ្លួនឯង។
- ២១ — រដ្ឋតម្រូវឱ្យមានការវះកាត់ប្តូរភេទ ឬទទួលការវះកាត់ប្តូរយេនឌ័រដើម្បីមានការទទួលស្គាល់តាមផ្លូវច្បាប់។
- ៦ — រដ្ឋមួយចំនួនខាងក្រោមនេះតម្រូវឱ្យវះកាត់ ដើម្បីទទួលបានការទទួលស្គាល់យេនឌ័រស្របតាមផ្លូវច្បាប់៖


ឆែក


ជប៉ុន


កាហ្សាក់ស្ថាន


សាធារណរដ្ឋកូរ៉េ


ស្លូវ៉ាគី


តួកគី

### *ករណីសិក្សា៖ ការទទួលស្គាល់យេនឌ័រស្របតាមផ្លូវច្បាប់នៅប្រទេសជប៉ុន*[26]

ក្នុងឆ្នាំ២០០៣ ប្រទេសជប៉ុនបានអនុម័តច្បាប់ស្តីពីករណីពិសេសក្នុងការដោះស្រាយបញ្ហាយេនឌ័រ សម្រាប់មនុស្សមានអត្តសញ្ញាណយេនឌ័រមិនស្របទៅនឹងការចង់បានរបស់ពួកគេ ហើយច្បាប់នេះអនុញ្ញាតឱ្យអ្នកស្រឡាញ់ភេទដូចគ្នាប្តូរយេនឌ័ររបស់ខ្លួននៅក្នុងសៀវភៅគ្រួសារ ប៉ុន្តែច្បាប់នេះមានលក្ខខណ្ឌមួយចំនួនតម្រូវឱ្យពួកគេបំពេញគឺ៖

- ត្រូវទទួលបាន «ការវិនិច្ឆ័យ» បញ្ជាក់ថា ជាអ្នកប្តូរយេនឌ័រ ដោយគ្រូពេទ្យពីរនាក់ ឬច្រើននាក់
- មានសរីរាង្គខាងក្រៅស្រដៀងទៅនឹងបុគ្គលផ្សេងទៀតដែលប្តូរភេទតាមបំណងរបស់ពួកគេរួចហើយ និង
- ត្រូវទទួលការក្រៀវមេជីវិត។

ច្បាប់នេះ លើកឡើងទាក់ទងនឹងការយល់ច្រឡំថា ការកំណត់អត្តសញ្ញាណរបស់អ្នកប្តូរយេនឌ័រ គឺបណ្តាលមកពីបញ្ហាផ្លូវចិត្ត និងបង្ខំឱ្យអ្នកប្តូរយេនឌ័រឆ្លងកាត់នីតិវិធីវេជ្ជសាស្ត្រ ដែលចំណាយពេលវេលាយូរលំបាក និងមិនអាចវិលត្រឡប់ទៅភាពដើមវិញ ដែលនេះជាការដកហូតសិទ្ធិផ្នែកបន្តពូជរបស់ពួកគេ។ ប្រជាពលរដ្ឋជាច្រើនបានជំទាស់នឹងច្បាប់រហូតដល់តុលាការ ប៉ុន្តែក្នុងឆ្នាំ២០១៩ តុលាការកំពូលជប៉ុនបានចេញសេចក្តីសម្រេចជាឯកច្ឆន្ទថា លក្ខខណ្ឌតម្រូវឱ្យមានការក្រៀវមេជីវិត គឺស្របតាមរដ្ឋធម្មនុញ្ញដោយសារតែវិធីនេះ «*ធ្វើឡើងដើម្បីកុំឱ្យមានការច្រឡំនៅក្នុងគ្រួសារ និងសង្គមជាតិ*»។

អ្នកប្តូរយេនឌ័រជាបុរស និងស្ត្រីក្នុងប្រទេសជប៉ុន យល់ឃើញថាការតម្រូវឱ្យធ្វើការវះកាត់នោះ គឺជាការបង្ខិតបង្ខំ ហើយជាបន្ទុកយ៉ាងធ្ងន់ធ្ងរសម្រាប់ពួកគេក្នុងការអនុវត្តសិទ្ធិឱ្យបានពេញលេញស្របតាមផ្លូវច្បាប់។ ហេតុដូច្នេះហើយបានជាអ្នកប្តូរយេនឌ័រជាច្រើនបានជ្រើសរើសយកការមិនវះកាត់ប្តូរភេទ និងពុំទទួលបានការទទួលស្គាល់យេនឌ័រស្របតាមផ្លូវច្បាប់ ដែលនាំឱ្យមានផលប៉ះពាល់ជាអវិជ្ជមានយូរអង្វែងទៅថ្ងៃអនាគតចំពោះសុខភាពផ្លូវកាយ និងសុខភាពផ្លូវចិត្តរបស់ពួកគេ។

[26] អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ (Human Rights Watch) ‘ឧបសគ្គដ៏ធំមួយ៖ដំណើរការទទួលស្គាល់តាមផ្លូវច្បាប់ដ៏បំពាន ចំពោះអ្នកប្តូរយេនឌ័ររបស់ប្រទេសជប៉ុន’ (២០១៩) < Japan’s Abusive Transgender Legal Recognition Process | HRW>; Hiroyuki Taniguchi, ‘ច្បាប់ស្តីពីបញ្ហាអត្តសញ្ញាណយេនឌ័រឆ្នាំ២០០៣៖ ការវះកាត់ប្តូរភេទ គ្មានការរៀបការ មិនតម្រូវឱ្យមានកូន គឺជាការបន្តនៃបទដ្ឋានយេនឌ័រនៅប្រទេសជប៉ុន’ [២០១៣] 108 Asia Pacific Law and Policy Journal 109-110; សារព័ត៌មាន Associate Press៖ តុលាការកំពូលប្រទេសជប៉ុន រក្សាលក្ខខណ្ឌតម្រូវឱ្យមានការវះកាត់ប្តូរភេទអ្នកប្តូរយេនឌ័រ (*NBC News*, 25 January 2019) < Japan's Supreme Court upholds transgender sterilization requirement (nbcnews.com)>; Equality (Gay Japan News) & RC-NET, ‘ជប៉ុន៖ ស្ថានភាពស្តីពីសិទ្ធិមនុស្ស និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ /ការបង្ហាញទំនោរយេនឌ័រ៖ របាយការណ៍អ្នកពាក់ព័ន្ធ ខែមីនា ឆ្នាំ២០១៧’ (ឆ្នាំ២០១៧)។

### *ករណីសិក្សា៖ ការទទួលស្គាល់យេនឌ័រស្របតាមផ្លូវច្បាប់នៅប្រទេសនេប៉ាល់*[27]

ការទទួលស្គាល់យេនឌ័រស្របតាមផ្លូវច្បាប់ក្នុងប្រទេសនេប៉ាល់ អនុញ្ញាតឱ្យមានការទទួលស្គាល់អត្តសញ្ញាណយេនឌ័រតាមការកំណត់ដោយខ្លួនឯង ប៉ុន្តែច្បាប់នេះបានឈានទៅមុខមួយជំហានទៀត ក្នុងការទទួលស្គាល់យេនឌ័រទីបីក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត លិខិតឆ្លងដែន ហើយបច្ចុប្បន្ននេះទម្រង់ព័ត៌មានអន្តោប្រវេសន៍ក៏មានជម្រើសសម្រាប់យេនឌ័រទីបីផងដែរ។ ក្នុងឆ្នាំ២០០៧ តុលាការកំពូលនៃប្រទេសនេប៉ាល់ បានចេញសេចក្តីបង្គាប់ទៅរដ្ឋាភិបាលដើម្បីឱ្យមានការទទួលស្គាល់យេនឌ័រទីបីដោយស្របច្បាប់បញ្ជីឈ្មោះអ្នកបោះឆ្នោត លិខិតឆ្លងដែន និងទម្រង់ព័ត៌មានអន្តោប្រវេសន៍បច្ចុប្បន្នមានជម្រើសសម្រាប់យេនឌ័រទីបី។ ក្នុងឆ្នាំ២០១១ ប្រទេសនេប៉ាល់បានក្លាយទៅជាប្រទេសទីមួយក្នុងពិភពលោកដែលបានដាក់បញ្ចូលភេទទីបីក្នុងជំរឿនរបស់រដ្ឋាភិបាល។ ក្រោយមកសិទ្ធិត្រូវបានកំណត់ក្នុងរដ្ឋធម្មនុញ្ញនេប៉ាល់ ធានាសិទ្ធិរបស់បុគ្គលក្នុងការជ្រើសរើសយកអត្តសញ្ញាណយេនឌ័រតាមការកំណត់ដោយខ្លួនឯង។

តែទោះយ៉ាងណាក្តី ការអនុវត្តច្បាប់ទាំងនោះត្រូវបានគេរាយការណ៍ថានៅយឺតយ៉ាវ។ រដ្ឋាភិបាលចំណាយពេល ៦ ឆ្នាំ ក្នុងការចេញអត្តសញ្ញាណប័ណ្ណដំបូងដែលកំណត់ប្រភេទនៃភេទទីបី។ ទោះបីជាមានការកំណត់ប្រភេទនៃយេនឌ័រទីបីក៏ដោយ ក៏ច្បាប់នេះនៅមានភាពមិនច្បាស់លាស់ក្នុងការធ្វើចំណាត់ថ្នាក់លើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ ព្រោះច្បាប់នេះលើកឡើង និងផ្តោតសំខាន់លើប្រភេទនៃយេនឌ័រទី៣ ថា "ផ្សេងទៀត" ដែលជាការរើសអើងលើបុគ្គលអ្នកស្រឡាញ់ភេទដូចគ្នា។

[27] កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ យូ.អិន.ឌី.ភី «អ្នកស្រឡាញ់ភេទដូចគ្នាប្រចាំតំបន់អាស៊ី៖ របាយការណ៍ប្រចាំប្រទេសនេប៉ាល់» (ឆ្នាំ២០១៤) ទំព័រ ២៥-២៩ <Being LGBT in Asia Nepal Country Report.pdf (usaid.gov)>; Kyle Knight, «តើប្រទេសនេប៉ាល់ក្លាយជាប្រទេសការពារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នាជាសកលយ៉ាងដូចម្តេច?» (អង្គការឃ្លាំមើលសិទ្ធិមនុស្ស ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧) <https://www.hrw.org/news/2017/08/11/how-did-nepal-become-global-lgbt-rights-beacon>; J. Michael Ryan, "ច្បាប់ស្តីពីអត្តសញ្ញាណយេនឌ័រ៖ ស្ថានភាពស្របច្បាប់នៃការទទួលស្គាល់ភេទ/អត្តសញ្ញាណយេនឌ័រជាសកល" (ឆ្នាំ២០១៨) ៨ ទិនានុប្បវត្តិគោលនយោបាយអ្នកស្រឡាញ់ភេទដូចគ្នា ៨-១០<https://repositorio.ul.pt/bitstream/10451/37621/1/ICS_JMRyan_Gender.pdf>; Ankit Khadgi, "ប្រទេសនេប៉ាល់អាចនឹងមានការរីកចម្រើននៅពេលនិយាយអំពីសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា ប៉ុន្តែវានៅតែមានផ្លូវវែងឆ្ងាយទៀត" (*Katmandu Post*, ១៧ ឧសភា ២០២០) <https://kathmandupost.com/national/2020/05/17/nepal-might-have-made-progress-when-it-comes-to-queer-rights-but-it-still-has-a-long-way-to-go>; Rukshana Newa, «ភាពស្មុគស្មាញនៃការទទួលស្គាល់យេនឌ័រស្របច្បាប់នៅក្នុងប្រទេសនេប៉ាល់» (អាស៊ីប៉ាស៊ីហ្វិកថ្ងៃទី ១-៥ មករា ២០២០) <https://yvc-asiapacific.org/2020/01/15/the-intricacy-of-legal-gender-recognition-in-nepal/>; Gopal Sharma, "រដ្ឋសភាប៊ូតាន់ បាននិរាករណ៍ច្បាប់ប្រឆាំងនឹងការស្រឡាញ់ភេទដូចគ្នា ដើម្បីផ្តល់ភាពរីករាយដល់សកម្មជន" (រ៉យទ័រ៖ ១០ ធ្នូ ២០២០) < Bhutan parliament decriminalizes homosexuality, to delight of activists | Reuters>.




*Source: ILGA World, 'World Map of Sexual Orientation Laws' (2020) <https://ilga.org/downloads/ENG_ILGA_World_map_sexual_orientation_laws_dec2020.pdf>.*

# មេរៀនទី ៥៖ ក្របខ័ណ្ឌច្បាប់នៅប្រទេសកម្ពុជា

## ៥.១ ក្របខ័ណ្ឌច្បាប់ជាតិ

នៅប្រទេសកម្ពុជា ពុំមានច្បាប់ចែងពីកិច្ចការពារជាក់លាក់ចំពោះអ្នកស្រឡាញ់ភេទដូចគ្នាទេ។ ប៉ុន្តែមានប្រភពច្បាប់ជាតិសំខាន់ៗចំនួនពីរដែលគាំទ្រសិទ្ធិនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិផ្នែកសុខភាពបន្តពូជ និងសុខភាពផ្លូវភេទគឺ៖

- *រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និង*
- *ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា*

**ពាក្យគន្លឹះសំខាន់ៗសម្រាប់មេរៀនទី ៥**

- **ឪពុកម្តាយបង្កើត៖** ឪពុកម្តាយដែលបានផ្តល់កំណើតកូន ឬបង្កកំណើតកូន។
- **ឧក្រិដ្ឋកម្មស្អប់ខ្ពើម៖** បទល្មើសដែលតាមធម្មតាពាក់ព័ន្ធនឹងអំពើហិង្សាដែលបណ្តាលឱ្យមានការធ្វើបុរេនិច្ឆ័យផ្អែកទៅលើចរិតលក្ខណៈរបស់បុគ្គលដូចជានិន្នាការភេទ និងអត្ត-សញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ ជាតិសាសន៍ ឬសាសនា។
- **ការរើសអើងតាមផ្លូវច្បាប់៖** ពុំមានច្បាប់ចែងពីការផ្តល់សម-ភាព។
- **ការទទួលស្គាល់យេនឌ័រតាមផ្លូវច្បាប់៖** ដំណើរការនៃការប្តូរព័ត៌មានយេនឌ័រនៅលើឯកសារផ្លូវច្បាប់ដើម្បីទទួលស្គាល់អត្តសញ្ញាណយេនឌ័ររបស់បុគ្គលណាម្នាក់។
- **យេនឌ័រពីកំណើត៖** បុគ្គលដែលមានអត្តសញ្ញាណយេនឌ័រ និងការបង្ហាញទំនោរយេនឌ័រ ស្របទៅតាមភេទដែលគាត់មានពីកំណើត។
- **ការបង្ហាញចេញ៖** នៅពេលបុគ្គលដទៃដឹង/ស្គាល់អំពីចរិតលក្ខណៈរបស់អ្នកស្រឡាញ់ភេទដូចគ្នា ឬ និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទរបស់ពួកគេ។

**រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា («រដ្ឋធម្មនុញ្ញ»)**

ទោះបីជារដ្ឋធម្មនុញ្ញមិនបានបញ្ជាក់ជាក់លាក់ទាក់ទងនឹងបុគ្គលអ្នកស្រឡាញ់ភេទដូចគ្នាក្តី ក៏ក្រោមមាត្រា ៣១ ធានាសិទ្ធិស្មើភាពគ្នាចំពោះប្រជាពលរដ្ឋកម្ពុជាទាំងអស់ «*ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ*»។ ក្រុមតស៊ូមតិដើម្បីសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នាបានបកស្រាយឃ្លា «*ស្ថានភាពឯទៀត*» ថាមានការរាប់បញ្ចូលនិន្នាការភេទ និងអត្តសញ្ញាយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទដែលស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ ម្យ៉ាងទៀត មាត្រា ៣១ ផ្តល់ធម្មនុញ្ញភាពចំពោះសន្ធិសញ្ញាអន្តរ-ជាតិនានាដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័នរួចហើយ នេះមានន័យថា រាជរដ្ឋាភិបាលកម្ពុជាមានកាតព្វកិច្ចអន្តរជាតិក្នុងការការពារសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នាស្របតាម*សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* និងសន្ធិសញ្ញាពាក់ព័ន្ធដទៃទៀត។

***ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា («ក្រមរដ្ឋប្បវេណី»)***

មុនពេលអនុម័តក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ច្បាប់ជាតិហាមឃាត់ការរៀបអាពាហ៍ពិពាហ៍ភេទដូចគ្នា។ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩ បានហាមឃាត់ការរៀបអាពាហ៍ពិពាហ៍រវាង «បុគ្គលដែលមានភេទដូចគ្នា» ប៉ុន្តែច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ បាននិរាករណ៍បទប្បញ្ញត្តិនេះដែលជាការវិវឌ្ឍវិជ្ជមានសម្រាប់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ដោយឈប់កំណត់ទោសទណ្ឌទៅលើការរៀបអាពាហ៍ពិពាហ៍រវាងបុគ្គលដែលមានភេទដូចគ្នាតទៅទៀត។ ទោះជាយ៉ាងណា ក្រមរដ្ឋប្បវេណីនៅតែមានបទប្បញ្ញត្តិមួយចំនួនរារាំងសមភាពសម្រាប់បុគ្គលអ្នកស្រឡាញ់ភេទដូចគ្នា និងគូស្រករស្រឡាញ់ភេទដូចគ្នាដដែល។

## ៥.២ និន្នាការផ្លូវច្បាប់នៅប្រទេសកម្ពុជា

ក្របខ័ណ្ឌច្បាប់នៅប្រទេសកម្ពុជាខកខានក្នុងការទទួលស្គាល់សិទ្ធិរបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា និងមានពាក្យពេចន៍រារាំងដល់ការអនុវត្តសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នា ព្រមទាំងរើសអើងលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទដទៃទៀតផង។ អ្នកស្រឡាញ់ភេទដូចគ្នាជាជនជាតិខ្មែរប្រឈមនឹងការរើសអើងផ្លូវច្បាប់ក្នុងទម្រង់ខុសៗគ្នា។




### ៥.២.១ អវត្តមានកិច្ចការពារចំពោះការរើសអើង និងអំពើហិង្សា

ច្បាប់កម្ពុជាមិនមានចែងជាក់លាក់ពីកិច្ចការពារចំពោះការរើសអើងលើអ្នកស្រឡាញ់ភេទដូចគ្នាទេ ហើយថែមទាំងមិនបានចែងពីការដាក់ទោសទណ្ឌទៅលើបុគ្គលដែលប្រព្រឹត្តឧក្រិដ្ឋកម្មស្អប់ខ្ពើមចំពោះអ្នកស្រឡាញ់ភេទដូចគ្នាផងដែរ។ ភាពចន្លោះប្រហោងក្នុងច្បាប់នេះធ្វើឱ្យសហ-គមន៍អ្នកស្រឡាញ់ភេទដូចគ្នាងាយនឹងទទួលរងគ្រោះពីការរើសអើង ហើយជាចំណែកមួយនាំឱ្យពួកគេកាន់តែជួបនឹងភាពលំបាកថែមទៀតផង។



- **ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា** («ក្រមព្រហ្មទណ្ឌ») មិនបានកំណត់ច្បាស់ពីការរើសអើងដោយផ្អែកលើមូលដ្ឋាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ ឬឧក្រិដ្ឋកម្មស្អប់ខ្ពើមណាមួយលើអ្នកស្រឡាញ់ភេទដូចគ្នាឡើយ[28] ។

[28] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ ២០០៩) មាត្រា ២៦៥។

### *ករណីសិក្សា៖ រឿងរបស់ស្រីលឹម*[29]

ស្រីលឹម គឺជាអ្នកប្តូរយេនឌ័រជាស្ត្រីធ្លាប់ទទួលរងការរើសអើងពីនគរបាល។ នាង និងមិត្តភក្តិមួយក្រុម (យេនឌ័រពីកំណើត និងអ្នកប្តូរយេនឌ័រជាស្ត្រី) ដែលជាអ្នកប្រកបរបរផ្លូវភេទបានឈរនៅក្បែរមាត់ស្ទឹងជាទីដែលពួកគេត្រូវបាននគរបាលឃាត់ខ្លួន។ នគរបាលពុំអនុញ្ញាតឱ្យពួកគេឈរនៅទីនោះ និងបានប្រាប់ឱ្យពួកគេចាកចេញពីតំបន់នោះ។ នគរបាលបានបង្ខំឱ្យអ្នកផ្សេងទៀតចាកចេញ លើកលែងតែអ្នកប្តូរយេនឌ័រជាស្ត្រី ដែលត្រូវបាននគរបាលបង្ខំឱ្យចុះទៅក្នុងទឹកស្ទឹង ឬពុំដូច្នោះទេត្រូវបង់ប្រាក់ ៣០ ដុល្លារ ។ នេះពុំមែនជាករណីលើកទីមួយទេ ហើយបានកើតឡើងជាច្រើនដងលើអ្នកប្តូរយេនឌ័រជាស្ត្រីផ្សេងទៀត។ ស្រីលឹម បានលើកឡើងពីអារម្មណ៍គ្មានសុវត្ថិភាព និងចង់ឱ្យនគរបាលគោរពសិទ្ធិក្នុងការបង្ហាញទំនោរយេនឌ័រដោយសេរីរបស់ពួកគេ។

- **ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ** («ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ») មិនរាប់បញ្ចូលជាក់លាក់ដល់អ្នកស្រឡាញ់ភេទដូចគ្នា ដោយសារនិយមន័យនៃពាក្យអំពើហិង្សាក្នុងគ្រួសារមានលក្ខណៈចង្អៀត។ មាត្រា ២ កំណត់និយមន័យនៃអំពើហិង្សាក្នុងគ្រួសារថា ជាអំពើហិង្សាអាចកើតមានលើ (១) ប្តី ឬ ប្រពន្ធ (២ ) កូនក្នុងបន្ទុក និង (៣) ជនទាំងឡាយរស់នៅក្រោមដំបូលផ្ទះ និងក្នុងបន្ទុកគ្រួសារ[30] ។ ដូច្នេះច្បាប់នេះមិនបានពង្រីកវិសាលភាពឱ្យមានវិធានការការពារជនរងគ្រោះនៃអំពើហិង្សាដែលស្ថិតនៅក្រៅទំនាក់ទំនងជាប្តីប្រពន្ធនោះទេ ដោយមិនបានរាប់បញ្ចូលដៃគូអ្នកស្រឡាញ់ភេទដូចគ្នា។
- **មាត្រា ១២ នៃច្បាប់ស្តីពីការងារកម្ពុជា** មានវិសាលភាពគ្រប់គ្រងលើទំនាក់ទំនងរវាងកម្មករនិយោជិត និងនិយោជក បានចែងបទប្បញ្ញត្តិមួយចំនួនអំពីការមិនរើសអើងនៅកន្លែងការងារដោយផ្អែកលើមូលដ្ឋាន «*ជាតិសាសន៍ ពណ៌សម្បុរ ភេទ ជំនឿ សាសនា គំនិតនយោបាយ ជាតិ កំណើត ដើមកំណើតសង្គម ការចូលជាសមាជិកសហជីពកម្មករនិយោជិត ឬការធ្វើសកម្មភាពក្នុងសហជីព*»[31]។ មាត្រា ១២ នេះ ពុំបានទទួលស្គាល់និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទឱ្យបានច្បាស់លាស់ថាជាមូលដ្ឋានសម្រាប់ការមិនរើសអើងនោះឡើយ។ ដោយហេតុនេះ ច្បាប់ការងារមិនបានការពារអ្នកស្រឡាញ់ភេទដូចគ្នាពីការរើសអើងនៅកន្លែងការងារឡើយ ហើយពួកគេអាចប្រឈមនឹងការបដិសេធក្នុងការផ្តល់ការងារ ឬ



[29] ម.ស.ម.ក «ការរើសអើងលើអ្នកប្តូរភេទជាស្ត្រីនៅតាមទីប្រជុំជនក្នុងព្រះរាជាណាចក្រកម្ពុជា» (ខែកញ្ញា ឆ្នាំ២០១៦) <https://cchrcambodia.org/index_old.php?url=project_page/project_page.php&p=report_detail.php&reid=115&id=3> p. 23.
[30] ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងការការពារជនរងគ្រោះ (ឆ្នាំ២០០៥), មាត្រា ២។ <https://sithi.org/temp.php?url=law_detail.php&id=155>.
[31] ច្បាប់ស្តីពីការងារ (ឆ្នាំ១៩៩៧), មាត្រា ១២ http://sithi.org/admin/upload/law/Labor%20Law%201997.%20ENG.pdf.

បដិសេធក្នុងការដំឡើងតំណែង និងការទទួលបានអត្ថប្រយោជន៍ផ្សេងៗ ដោយសារតែនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទរបស់ពួកគេ។

- **មាត្រា ៦ នៃច្បាប់ស្តីពីសហជីព** ចែងនូវបទប្បញ្ញត្តិអំពីការមិនរើសអើងចំពោះការចូលជាសមាជិកភាពសហជីព ថា «*កម្មករ និយោជិត ឬនិយោជកទាំងអស់ដោយមិនប្រកាន់ពីពូជសាសន៍ ពណ៌សម្បុរ ភេទ ជំនឿ សាសនា ទស្សនៈនយោបាយ សញ្ជាតិ ដើមកំណើតសង្គម ឬស្ថានភាពសុខភាព មានសិទ្ធិចូលជាសមាជិកសហជីពឬសមាគមនិយោជកដោយសេរីទៅតាមជម្រើសរបស់ខ្លួន*»[32] ។ ដោយសារថា មាត្រា ៦ ពុំបានបញ្ជាក់ជាក់លាក់អំពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ ថាជាក្រុមបុគ្គលដែលត្រូវទទួលបានការការពារតាមផ្លូវច្បាប់ ដូចនេះហើយអ្នកស្រឡាញ់ភេទដូចគ្នាអាចត្រូវបានបដិសេធក្នុងការចូលជាសមាជិកភាពសហជីពផ្អែកលើលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទរបស់ពួកគេ។
- **ច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍** បដិសេធអ្នកស្រឡាញ់ភេទដូចគ្នាដែលមានអាយុក្រោម ១៨ ឆ្នាំ ក្នុងការទទួលបានការធ្វើតេស្តរកជំងឺអេដស៍/មេរោគអេដស៍។ មាត្រា ១៩ ចែងថាការធ្វើតេស្តរកមេរោគអេដស៍/ជំងឺអេដស៍ ត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត និងត្រូវមានការយល់ព្រមជាមុនពីសាមីជនផ្ទាល់។ ចំពោះសាមីជនជាអនីតិជនតម្រូវឱ្យមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអាណាព្យាបាលស្របច្បាប់[33]។ លក្ខខណ្ឌក្នុងការទទួលបានការធ្វើតេស្តរកមេរោគអេដស៍សម្រាប់អ្នកស្រឡាញ់ភេទដូចគ្នាអាយុក្រោម ១៨ ឆ្នាំ គឺជាឧបសគ្គសម្រាប់អ្នកដែលមិន «បង្ហាញ» ឱ្យឪពុកម្តាយរបស់ពួកគេបានដឹង ដែលនេះ គឺជាការរារាំងពួកគេក្នុងការទទួលបានការសង្គ្រោះជីវិត និងការថែទាំសុខភាពប្រកបដោយគុណភាពត្រឹមត្រូវ។

### ៥.២.២ ការរើសអើងតាមផ្លូវច្បាប់៖ អវត្តមានការទទួលស្គាល់អត្តសញ្ញាណយេនឌ័រតាមផ្លូវច្បាប់តាមការកំណត់ដោយខ្លួនឯង



ច្បាប់ជាតិរបស់ប្រទេសកម្ពុជាខកខានក្នុងការទទួលស្គាល់យេនឌ័រតាមផ្លូវច្បាប់សម្រាប់ប្រជាពលរដ្ឋខ្មែរជាអ្នកប្តូរយេនឌ័រ។ ប្រទេសកម្ពុជាគ្មានច្បាប់មួយណាដែលគាំទ្រឱ្យមានការទទួលស្គាល់សិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នាតាមផ្លូវច្បាប់តាមការកំណត់ដោយសាមីខ្លួនឡើយ។ ផ្ទុយមកវិញក៏មិនមានបទប្បញ្ញត្តិជាក់លាក់ដែលហាមឃាត់ការទទួលស្គាល់យេនឌ័រតាមផ្លូវច្បាប់ផងដែរ។ ដោយហេតុនេះ ការទទួលស្គាល់យេនឌ័រតាមផ្លូវច្បាប់សម្រាប់ប្រជាពលរដ្ឋអ្នកស្រឡាញ់ភេទដូចគ្នា គឺអាស្រ័យលើឆន្ទានុសិទ្ធិរបស់អាជ្ញាធរមូលដ្ឋាន។

---

[32] ច្បាប់ស្តីពីសហជីព (ឆ្នាំ២០១៦), មាត្រា ៦ <http://www.sithi.org/admin/upload/la< w/trade_union_law_eng.pdf>.

[33] ច្បាប់ស្តីពីការការពារនិងគ្រប់គ្រងមេរោគអេដស៍/ជំងឺអេដស៍ (ឆ្នាំ២០០២), មាត្រា ១៩ < https://www.ilo.org/wcmsp5/groups/public/---ed_protect/---protrav/---ilo_aids/documents/legaldocument/wcms_113128.pdf>

ការទទួលស្គាល់យេនឌ័រតាមផ្លូវច្បាប់ធ្វើឱ្យបុគ្គលស្គាល់ច្បាស់ថាខ្លួនឯងជានរណា ព្រោះអនុញ្ញាតឱ្យបុគ្គលម្នាក់ៗមានឯកសារសម្គាល់អត្តសញ្ញាណផ្លូវការដែលបង្ហាញពីអត្តសញ្ញាណយេនឌ័ររបស់ខ្លួន។ ឯកសារនេះមានសារៈសំខាន់ណាស់សម្រាប់អ្នកប្តូរយេនឌ័រ ព្រោះធ្វើឱ្យពួកគេទទួលបានសិទ្ធិជាច្រើនផ្សេងទៀត រួមទាំងសិទ្ធិរៀបអាពាហ៍ពិពាហ៍ និងសិទ្ធិសុំកូនមកចិញ្ចឹម។ ឯកសារសម្គាល់អត្តសញ្ញាណអនុញ្ញាតឱ្យដៃគូអ្នកស្រឡាញ់ភេទដូចគ្នាដែលមានអត្តសញ្ញាណជាអ្នកប្តូរភេទមានលទ្ធភាពរៀបអាពាហ៍ពិពាហ៍ ព្រមទាំងមានសិទ្ធិសុំកូនដោយបំពេញតាមលក្ខខណ្ឌផ្លូវច្បាប់ក្នុងឋានៈជា «ប្តី» និង «ប្រពន្ធ»។

## ៥.២.៣ ការរើសអើងតាមផ្លូវច្បាប់៖ អវត្តមានសមភាពអាពាហ៍ពិពាហ៍នៅក្នុងច្បាប់កម្ពុជា



ច្បាប់ប្រទេសកម្ពុជា ខកខានក្នុងការផ្តល់សិទ្ធិរៀបអាពាហ៍ពិពាហ៍ចំពោះបុគ្គលដែលមានភេទដូចគ្នា។ អាពាហ៍ពិពាហ៍ត្រូវបានគេផ្តល់តម្លៃយ៉ាងខ្លាំងនៅក្នុងប្រទេសកម្ពុជា ដោយមានប្រជាពលរដ្ឋប្រមាណត្រឹមតែ ៥ ភាគរយប៉ុណ្ណោះ ដែលបន្តភាពនៅលីវរបស់ខ្លួនពេញមួយជីវិត[34]។ ការហាមឃាត់អ្នកស្រឡាញ់ភេទដូចគ្នាក្នុងការរៀបអាពាហ៍ពិពាហ៍មានន័យថា ជាការផាត់ពួកគេចេញពីគោលការណ៍មូលដ្ឋានមួយក្នុងចំណោមគោលការណ៍មូលដ្ឋាននានានៃសង្គមកម្ពុជា។

- មាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញបានកំណត់ការរៀបអាពាហ៍ពិពាហ៍រវាង *«ប្តីមួយ»* និង *«ប្រពន្ធមួយ»* ដោយមិនបានរាប់បញ្ចូលការរៀបអាពាហ៍ពិពាហ៍របស់អ្នកស្រឡាញ់ភេទដូចគ្នាទេ។
- ក្រមរដ្ឋប្បវេណីមិនបានចែងជាក់លាក់ពីភាពខុសច្បាប់នៃការរៀបអាពាហ៍ពិពាហ៍សម្រាប់អ្នកមានភេទដូចគ្នាឡើយ ប៉ុន្តែយ៉ាងណាក្តី ក្រមនេះក៏ពុំមានបទប្បញ្ញត្តិជាក់លាក់ណាមួយសម្រួលឱ្យមានការរៀបអាពាហ៍ពិពាហ៍ភេទដូចគ្នាដែរ។ ក្រមរដ្ឋប្បវេណីនៅតែបង្ហាញនូវវឌ្ឍនភាពជាវិជ្ជមាន ព្រោះក្រមនេះឈប់បន្តសុពលភាពលើមាត្រាមួយចំនួនក្នុង *ច្បាប់ស្តីពីការរៀបអាពាហ៍ពិពាហ៍ និងគ្រួសារ* ក្នុងនោះក៏មានមាត្រា ៦ ផងដែរ ដែលបានហាមឃាត់ជាក់លាក់ទៅលើការរៀបអាពាហ៍ពិពាហ៍រវាងអ្នកមានភេទដូចគ្នា។

**ករណីសិក្សា៖ រិទ្ធី និងលីន [35]**

«ក្នុងឆ្នាំ១៩៧៦ ខ្ញុំបានស្រឡាញ់ដៃគូរបស់ខ្ញុំ ហើយបានដឹងអំពីទំនោរផ្លូវភេទខ្លួនឯងជាលើកដំបូង។ ចាប់ពីឆ្នាំ១៩៧៩ មក យើងបានរស់នៅជាមួយគ្នា និងធ្វើការជាមួយគ្នា។ យើងស្រឡាញ់គ្នា និងមើលថែគ្នាទៅវិញទៅមកពេលយើងឈឺ។

យើងមានសៀវភៅគ្រួសារ ប៉ុន្តែនៅក្នុងសៀវភៅនេះមិនបានបញ្ជាក់ថាពួកយើងជាប្តីប្រពន្ធទេ គឺចុះឈ្មោះពួកយើងជាបងប្អូនបង្កើតទៅវិញដែលខ្ញុំមានឋានៈជាមេគ្រួសារ។ ប៉ុន្តែនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ខ្ញុំដើរតួជាប្តី ហើយដៃគូរបស់ខ្ញុំដើរតួជាប្រពន្ធ។ អាជ្ញាធរនិយាយថា ទោះបីជាពេលនេះ ពួកយើងទទួលបាន

---

[34] អត្ថបទស្តីពី «បញ្ហាច្បាប់ និងយេនឌ័រនៃអាពាហ៍ពិពាហ៍និងការលែងលះក្នុងប្រទេសកម្ពុជា» ព្រឹត្តិបត្រស្តីពីច្បាប់ និងគោលនយោបាយរបស់ប្រទេសកម្ពុជា សំណៅ ៣៖២ (ឆ្នាំ២០០៤) សរសេរដោយ Dorine Van De Keur

[35] ម.ស.ម.ក «គ្រួសារឥន្ទធនូនៅកម្ពុជា» (ខែវិច្ឆិកា ឆ្នាំ២០១៧) <https://cchrcambodia.org/admin/media/report/report/english/2017-11-22-CCHR-Report-Cambodia-Rainbow-Families_ENG.pdf> p. 13.

ឯកសារផ្លូវច្បាប់ហើយក្តី តែពួកយើងអាចរៀបចំពិធីអាពាហ៍ពិពាហ៍របស់យើងបានតែក្នុងទ្រង់ទ្រាយពិធីជប់លៀងធម្មតាប៉ុណ្ណោះ ពុំអាចធ្វើជាកម្មវិធីមង្គលការផ្លូវការបានឡើយ។

ខ្ញុំខកចិត្តដោយសារមិនអាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបាន។ ខ្ញុំក៏ជាមនុស្សដែរ ហេតុអ្វីគេមិនអនុញ្ញាតឱ្យខ្ញុំរៀបការដូចមនុស្សផ្សេងទៀត?»

## ៥.២.៤ ការបដិសេធលើសិទ្ធិសុំកូនពេញលេញ



នៅប្រទេសកម្ពុជាសិទ្ធិសុំកូនពេញលេញមិនត្រូវបានផ្តល់ជូនដល់ដៃគូអ្នកស្រឡាញ់ភេទដូចគ្នាទេ។ ក្រមរដ្ឋប្បវេណីបានលើកឡើងអំពីការសុំកូនមានពីរប្រភេទគឺសុំកូនពេញលេញ និងសុំកូនធម្មតា[36]។

**ការសុំកូនពេញលេញ**

បង្កើតទំនាក់ទំនងផ្លូវច្បាប់រវាងកុមារ និងឪពុកម្តាយចិញ្ចឹមរបស់កុមារនោះ ដែលទំនាក់ទំនងផ្លូវច្បាប់នេះមានអនុភាពស្មើនឹងទំនាក់ទំនងផ្លូវច្បាប់រវាងកុមារ និងឪពុកម្តាយបង្កើតដែរ។

មានតែគូស្រករដែលបានរៀបអាពាហ៍ពិពាហ៍រួចហើយប៉ុណ្ណោះ ទើបមានសិទ្ធិសុំកូនពេញលេញបានដែលនេះជាការផាត់ចេញគូស្រករអ្នកស្រឡាញ់ភេទដូចគ្នាដែលមិនអាចរៀបអាពាហ៍ពិពាហ៍បាន និងអ្នកដែលនៅលីវ។

**ការសុំកូនធម្មតា**

ការសុំកូនធម្មតា ពុំអាចផ្តាច់ទំនាក់ទំនងផ្លូវច្បាប់រវាងកុមារនិងឪពុកម្តាយបង្កើតទាំងស្រុងបានឡើយ។

ការសុំកូនធម្មតា មិនបានបង្កើតឋានន្តរក្រមសិទ្ធិ រវាងឪពុកម្តាយចិញ្ចឹមនិងឪពុកម្តាយបង្កើតឡើយ ហើយចំណុចនេះបង្កើតបានភាពមិនច្បាស់លាស់ផ្នែកច្បាប់ និងភាពងាយរងគ្រោះសម្រាប់ឪពុកម្តាយចិញ្ចឹម។

អ្នកនៅលីវ បុគ្គលដែលមិនទាន់រៀបការ អាចសុំកូនបានដែលប្រការនេះអនុញ្ញាតឱ្យគូស្រករស្រឡាញ់ភេទដូចគ្នាអាចសុំកូនបាន ប៉ុន្តែជាឪពុកម្តាយចិញ្ចឹម ពុំទទួលបានការការពារតាមផ្លូវច្បាប់ឡើយ។

យោងតាមក្រមរដ្ឋប្បវេណី គូស្រករអ្នកស្រឡាញ់ភេទដូចគ្នាត្រូវបានផាត់ចេញពីការទទួលបានសិទ្ធិសុំកូនពេញលេញ ដោយហេតុថាមានតែគូស្រករដែលរៀបអាពាហ៍ពិពាហ៍រួចហើយប៉ុណ្ណោះទើបមានសិទ្ធិសុំកូនបាន។ ហេតុដូចនេះ គូស្រករអ្នកស្រឡាញ់ភេទដូចគ្នាមួយចំនួនបានជ្រើសយកការសុំកូនធម្មតា ដែលដៃគូណាម្នាក់ក្នុងចំណោមគូស្រករអ្នកស្រឡាញ់ភេទដូចគ្នាអាចសុំកូនបាន ដែលប្រការនេះនាំឱ្យពុំទទួលបានការការពារតាមផ្លូវច្បាប់ផ្សេងៗក្នុងករណីមានការស្លាប់ឪពុក ឬម្តាយចិញ្ចឹម ជាការបញ្ចប់ទំនាក់ទំនងផ្លូវច្បាប់ ឬព្រឹត្តិការណ៍ផ្សេងៗដែលមិនអាចដឹងមុន។ លើសពីនេះ ការសុំកូនធម្មតាអាចត្រូវបានរំលាយតាមពាក្យបណ្តឹងរបស់ភាគីនៃកិច្ចព្រមព្រៀង ហើយឪពុកម្តាយបង្កើតនៅតែមានសិទ្ធិលើកុមារនោះដដែល។ ការលំបាកទាំងនេះក្លាយជាកត្តារាំងដែលបន្ទប់បង្អាក់គូស្រករអ្នកស្រឡាញ់ភេទដូចគ្នាមិនឱ្យសុំកូន និងបដិសេធសិទ្ធិបង្កើតគ្រួសារផងដែរ។

[36] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា (ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧) គន្ថីទី៧ ជំពូកទី៤ មាត្រា ១០១៤-១០១៥ និង១០២០។

**ករណីសិក្សា៖ ផែល ញ៉ក់ និង ហេង នី [37]**

ញ៉ក់ និងនី ជាគូស្នេហ៍អ្នកស្រឡាញ់ភេទដូចគ្នា នីជាអ្នកប្តូរយេនឌ័រជាបុរស។ ជារឿយៗពួកគេប្រឈមមុខនឹងការរើសអើង និងការមិនទទួលយកនៅក្នុងសហគមន៍របស់ពួកគេ ដោយសារតែទំនាក់ទំនងរបស់ពួកគេ។ ញ៉ក និងនី បានសុបិនចង់ធ្វើការសុំកូន។ នៅពេលសម្ភាសន៍ ញ៉ក់បាននិយាយថា“ នៅពេលដែលខ្ញុំបានឃើញគ្រួសារផ្សេងទៀតមានកូនខ្ញុំមានអារម្មណ៍ថាដូចខ្វះខាតអ្វីម្យ៉ាង”។ នាងបានសុំកូនពីរនាក់ដែលឥឡូវមានអាយុ ២៤ និង ២ ឆ្នាំដែលនាងស្រឡាញ់ “ ដូចជាពួកគេជាកូនបង្កើតរបស់ខ្ញុំ”។ នៅលើលិខិតសុំកូន ញ៉ក់ និងនីត្រូវបានចុះបញ្ជីជាឪពុកម្តាយ។ នេះអាចទៅរួចពីព្រោះអាជ្ញាធរមូលដ្ឋានបានអនុញ្ញាតឱ្យនីចុះបញ្ជីអត្ត-សញ្ញាណយេនឌ័ររបស់គាត់នៅលើអត្តសញ្ញាណប័ណ្ណរបស់គាត់ជា “ប្រុស” ហើយអ្នកទាំងពីរមានសៀវភៅគ្រួសារដែលចុះបញ្ជីពួកគេជាប្តីប្រពន្ធទោះបីជាពួកគេមិនដែលរៀបការជាផ្លូវការក៏ដោយ។ គ្រួសាររបស់ញ៉ក់ និងនី បានចាប់ផ្តើមទទួលយកទំនាក់ទំនងរបស់ពួកគេកាន់តែច្រើនជាងមុន បន្ទាប់ពីពួកគេបានយកកូនមកចិញ្ចឹម។

## ៥.៣ អាជ្ញាធរមូលដ្ឋាន និងមន្ត្រីនគរបាល៖ ការបកស្រាយផ្នែកច្បាប់ និងគោលនយោបាយខុសៗគ្នា



មានច្បាប់មួយចំនួនទៀតនៅប្រទេសកម្ពុជា ត្រូវបានអនុវត្តមានលក្ខណៈរើសអើងទៅលើសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា។ វិសាលភាព និងគោលបំណងនៃច្បាប់ទាំងនេះគឺដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធផ្សេងៗ ប៉ុន្តែដោយសារតែបទប្បញ្ញត្តិមួយចំនួនមានខ្លឹមសារមិនជាក់លាក់ បង្កឱ្យមានអំពើពុករលួយនៅមូលដ្ឋាន និងមានផ្នត់គំនិតអវិជ្ជមានទៅលើអ្នកស្រឡាញ់ភេទដូចគ្នា ហើយបទប្បញ្ញត្តិទាំងនោះត្រូវបានអាជ្ញាធរប្រើប្រាស់ដើម្បីទប់ស្កាត់សកម្មភាពរបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា។

- **ច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើអាជីវកម្មលើមនុស្ស ( «ច្បាប់ប្រឆាំងនឹងអំពើពង្រត់» )៖** ក្រុមគ្រួសារប្តឹងដល់អាជ្ញាធរមូលដ្ឋានឱ្យបំបែកបំបាក់កូនដែលស្រឡាញ់ភេទដូចគ្នាពីដៃគូរបស់ពួកគេដោយបង្ខំ ក្រោមច្បាប់ប្រឆាំងនឹងអំពើពង្រត់។ ឧទាហរណ៍ ក្រុមគ្រួសារប្តឹង និងចោទប្រកាន់ដៃគូម្ខាងទៀតពីបទចាប់ពង្រត់កូនរបស់ខ្លួន។ បន្ទាប់មកអាជ្ញាធរនឹងធ្វើការស៊ើបអង្កេតក្នុងករណីនេះ និងអាចឈានដល់ការបំបែកបំបាក់ពីដៃគូអ្នកស្រឡាញ់ភេទដូចគ្នាបាន[38] ។
- **ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ៖** តាមការស្រាវជ្រាវដែលធ្វើឡើងក្នុងឆ្នាំ២០០៩ បានបង្ហាញថា ការអនុវត្តច្បាប់នេះបាននាំឱ្យមានការចាប់ខ្លួនបុរសស្រឡាញ់បុរស និង

---

[37] Leonie Kijewski & Kong Meta, “ទោះបីជាមានឧបសគ្គផ្នែកច្បាប់ក៏ដោយក៏គូស្វាមីភរិយាអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាកំពុងត្រូវបានទទួលស្គាល់ និងផ្លាស់ប្តូរផ្នត់គំនិតជាវិជ្ជមានក្នុងសង្គម” (ភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨) <https://www.phnompenhpost.com/national-post-depth/despite-legal-hurdles-cambodias-lgbt-couples-are-adopting-and-changing-minds>.

[38] របាយការណ៍សម្រាប់ប្រទេសកម្ពុជារបស់ UNDP «ភាពជាអ្នកស្រឡាញ់ភេទដូចគ្នានៅអាស៊ី» (ឆ្នាំ២០១៤) ទំព័រទី ៣៤ <https://www.asia-pacific.undp.org/content/rbap/en/home/library/democratic_governance/hiv_aids/being-lgbt-in-asia--cambodia-country-report.html> p.30-31.

អ្នកប្តូរយេនឌ័រដែលធ្វើការនៅកន្លែងកំសាន្តជាច្រើននាក់ មានការកើនឡើងមួយជាបីនៅចន្លោះឆ្នាំ ២០០៧ និង២០០៨[39]។

- **គោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព៖** គោលនយោបាយនេះផ្តោតសំខាន់លើសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ហើយជារឿយៗត្រូវបានអាជ្ញាធរអនុវត្តដើម្បីផ្តល់យុត្តិកម្មចំពោះការចាប់ខ្លួន និងការឃាយីលើអ្នកស្រឡាញ់ភេទដូចគ្នា។ ខណៈដែលគោលនយោបាយនេះផ្តល់តួនាទីពិសេសដល់អាជ្ញាធរមូលដ្ឋានក្នុងការលុបបំបាត់រាល់ទម្រង់នៃបទល្មើសនៅតាមភូមិដូចជាគ្រឿងញៀន ពេស្យាចារ ការជួញដូរមនុស្ស ទោះយ៉ាងណាក្តីអាជ្ញាធរបានអនុវត្តគោលនយោបាយនេះតាមអំពើចិត្តជាញឹកញាប់ចំពោះសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា[40]។
- **ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន៖** ច្បាប់នេះ រួមជាមួយគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាពត្រូវបានអនុវត្តតាមអំពើចិត្តដើម្បីដៅមុខសញ្ញាទៅលើអ្នកស្រឡាញ់ភេទដូចគ្នាដែលប្រកបរបរផ្លូវភេទផងដែរ។ កង្វះការយល់ដឹងពីការអនុវត្តច្បាប់បានធ្វើឱ្យអ្នកប្តូរយេនឌ័រដែលប្រកបរបរផ្លូវភេទរងការចាប់ខ្លួនទាក់ទងនឹងគ្រឿងញៀន ហើយត្រូវបានបង្ខំឱ្យបង់ប្រាក់ ឬវត្ថុមានតម្លៃដល់នគរបាលជាថ្នូរនឹងការទទួលបានការដោះលែងពីពន្ធនាគារ[41]។



[39] Ibid.
[40] Ibid.
[41] Ibid.

## ៥.៤ គោលនយោបាយ និងកម្មវិធីនានាដែលមានគោលបំណងបង្កើនការលើកកម្ពស់សិទ្ធិអ្នកស្រលាញ់ភេទដូចគ្នានៅកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងពាក់ព័ន្ធបានធ្វើសកម្មភាពមួយចំនួនដើម្បីលើកកម្ពស់សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេស និងជួយប្រជាពលរដ្ឋកម្ពុជាឱ្យបានយល់ដឹងពីបញ្ហាពាក់ព័ន្ធនឹងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ។

*នារីរតនៈទី៤ ៖ ផែនការយុទ្ធសាស្ត្រដើម្បីសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី (ឆ្នាំ២០១៤-២០១៨)*[42]

ទោះបីជាគោលនយោបាយនារីរតនៈទី៤ មិនមានការលើកឡើងជាក់លាក់អំពីអ្នកស្រឡាញ់ភេទដូចគ្នាក្តី ប៉ុន្តែគោលនយោបាយនេះបានទទួលស្គាល់នូវតម្រូវការរបស់ពួកគេក្នុងសមាសភាពមួយចំនួន។ សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ត្រូវបានលើកឡើងក្នុងគោលការណ៍សំខាន់ៗក្នុងផែនការយុទ្ធសាស្ត្រចំនួន ២ គឺ៖

- ការបង្កើត និងអនុវត្តន៍កម្មវិធីលើកកម្ពស់ការយល់ដឹង ព្រមទាំងសិទ្ធិទទួលបានការអប់រំសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា ស្ត្រី និងក្មេងស្រី
- ផ្តួចផ្តើមការពិភាក្សាថ្នាក់ជាតិជាមួយភាគីពាក់ព័ន្ធ រួមមានអ្នកស្រឡាញ់ភេទដូចគ្នា ដើម្បីធ្វើការរៀបចំយុទ្ធសាស្ត្រក្នុងការលើកកម្ពស់សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា និងបញ្ឈប់ការរើសអើងលើសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅតាមសាលារៀន នៅកន្លែងធ្វើការ ក្នុងសហគមន៍ និងក្នុងគ្រួសារ។
- គោលនយោបាយនារីរតនៈទី៥ (២០១៩-២០២៣) បានអនុម័តនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០២០។

*ការបង្រៀនអំពីសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នានៅតាមសាលារៀន*[43]

ក្នុងឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសថានឹងបង្រៀនអំពីសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នានៅតាមសាលារៀនចាប់ពីថ្នាក់ទី៧ ឡើងទៅ ដោយគិតមកត្រឹមឆ្នាំ២០២០ មានការពិភាក្សាអំពីមេរៀនផ្នែកនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទដែលនឹងត្រូវបញ្ចូលទៅក្នុងមេរៀនអប់រំអំពីផ្លូវភេទ។ មានការលើកឡើងថា មានគ្រូបង្រៀនចំនួន ៣១០០ នាក់ ទទួលបានការបណ្តុះបណ្តាលអំពីការបង្រៀនលើមុខវិជ្ជាថ្មីនេះ។

[42] នារីរតនៈទី ៤ ផែនការយុទ្ធសាស្ត្រ ៥ឆ្នាំ ដើម្បីសមភាពយេនឌ័រនិងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី (ឆ្នាំ២០១៤-២០១៨) <https://www.kh.undp.org/content/cambodia/en/home/library/democratic_governance/cambodian-gender-strategic-plan---neary-rattanak-4.html>.

[43] Matt Bloomberg, "កម្ពុជាត្រូវបង្រៀនបញ្ហារបស់អ្នកស្រឡាញ់ភេទដូចគ្នា នៅតាមសាលារៀនដើម្បីដោះស្រាយបញ្ហានៃការរើសអើង" (*Reuters*, ថ្ងៃទី ១០ ខែធ្នូ ឆ្នាំ២០១៩) <https://www.reuters.com/article/us-cambodia-lgbt-education/cambodia-to-teach-lgbt-issues-in-schools-to-tackle-discrimination-idUSKBN1YE1RK>.

## ៥.៥ អនុសាសន៍នៃដំណើរការពិនិត្យជាសកលតាមកាលកំណត់ជុំទី៣ របស់កម្ពុជា[44]

នៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៩ របាយការណ៍លទ្ធផលនៃដំណើរការពិនិត្យជាសកលតាមកាលកំណត់ ("យូភីអ") ជុំទី៣ របស់ប្រទេសកម្ពុជាត្រូវបានអនុម័ត ដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស។ របាយការណ៍លទ្ធផលនេះមានអនុសាសន៍ចំនួន៩ ទាក់ទងនឹងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ។ រាជរដ្ឋាភិបាលកម្ពុជា បានទទួលយកអនុសាសន៍ទាំង ៩ នោះហើយបានប្តេជ្ញាចិត្តក្នុងការអនុម័តច្បាប់ស្តីពីការប្រឆាំងនឹងការរើសអើង ច្បាប់ស្តីពីសមភាពអាពាហ៍ពិពាហ៍ និងច្បាប់ស្តីពីការទទួលស្គាល់យេនឌ័រ។

**យូ.ភី.អ**

- យន្តការនៃក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ
- ការពិនិត្យឡើងវិញលើកំណត់ត្រាសិទ្ធិមនុស្សរបស់រដ្ឋសមាជិកនៃអង្គការសហប្រជាជាតិរៀងរាល់ប្រាំឆ្នាំម្តង។
- នៅចុងបញ្ចប់នៃដំណើរការពិនិត្យជាសកលតាមកាលកំណត់ រដ្ឋដែលកំពុងស្ថិតក្រោមការពិនិត្យទទួលបានរបាយការណ៍លទ្ធផលដែលមានភ្ជាប់មកនូវអនុសាសន៍នានាដើម្បីកែលម្អស្ថានភាពសិទ្ធិមនុស្សឱ្យបានប្រសើរ។
- បន្ទាប់មក (រដ្ឋអាចទទួលយកអនុសាសន៍) ការប្តេជ្ញាចិត្តក្នុងការអនុវត្ត (ឬកត់សម្គាល់) មិនប្តេជ្ញាចិត្តក្នុងការអនុវត្តអនុសាសន៍ទាំងនោះ។

| លេខ | អនុសាសន៍ | រដ្ឋដែលផ្តល់អនុសាសន៍ | រដ្ឋាភិបាលឆ្លើយតប |
|---|---|---|---|
| ១១០.៤៥ | បង្កើតច្បាប់ប្រឆាំងការរើសអើងដែលធានានិងហាមឃាត់យ៉ាងជាក់លាក់នូវរាល់ប្រភេទនៃការរើសអើង ដោយសារនិន្នាការភេទអត្តសញ្ញាណយេនឌ័រនិងលក្ខណៈភេទ។ | អ៊ិស្លង់ | ទទួល |
| ១១០.៤៦ | ដាក់ចេញនូវច្បាប់ទទួលស្គាល់យេនឌ័រ | អ៊ិស្លង់ | ទទួល |
| ១១០.៤៧ | វិសោធនកម្មរដ្ឋធម្មនុញ្ញ ដើម្បីធានាអោយមានសមភាពគូស្រករភេទដូចគ្នា | អ៊ិស្លង់ | ទទួល |
| ១១០.៥០ | ពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិល ដើម្បីអនុម័តច្បាប់ និងគោលនយោបាយដែលគ្រប់ជ្រុងជ្រោយប្រឆាំងនឹងការរើសអើង និងអំពើហិង្សាដោយសារនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ និងធានាការអនុវត្តច្បាប់ និងគោលនយោបាយទាំងនេះនៅក្នុងស្ថាប័នសាធារណៈទាំងអស់ជាពិសេស ក្នុងវិស័យអប់រំ សុខាភិបាល និងការងារ។ | ម៉ិចស៊ិក | ទទួល |
| ១១០.៥១ | ធ្វើវិសោធនកម្មមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញដើម្បីបើកឱ្យមានភាពស្មើគ្នានៃអាពាហ៍ពិពាហ៍ស្របច្បាប់ក្នុងគោលបំណងដើម្បីទទួលបានការប្រតិបត្តិយ៉ាងពេញលេញ និងស្មើភាពគ្នាចំពោះបុរសស្រឡាញ់បុរស ស្ត្រីស្រឡាញ់ស្ត្រី អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ និងអន្តរភេទ នៅគ្រប់ផ្នែកផ្សេងៗទៀត។ | ហូឡង់ | ទទួល |
| ១១០.៥២ | បង្កើតច្បាប់ថ្មីមួយ ដែលធានានូវសមភាព និងហាមឃាត់យ៉ាងជាក់លាក់នូវការរើសអើងចំពោះក្រុមអ្នកស្រឡាញ់ភេទដូចគ្នា។ | ស៊ុយអ៊ែត | ទទួល |
| ១១០.៥៣ | អនុម័តវិធានការប្រកបដោយប្រសិទ្ធភាពក្នុងការប្រយុទ្ធប្រឆាំងនិងផ្តន្ទាទោសចំពោះការរើសអើងនិងអំពើហិង្សាដែលបានជំរុញដោយនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ។ | អ៊ុយរូហ្គាយ | ទទួល |
| ១១០.៥៤ | ត្រឹមដំណាច់ឆ្នាំ២០២៣ ធ្វើការបង្កើតច្បាប់ប្រឆាំងការរើសអើង ដែលធានានូវសមភាព និងការហាមឃាត់យ៉ាងជាក់លាក់រាល់ការរើសអើងគ្រប់ប្រភេទ រួមមាន៖ ដោយសារមូលដ្ឋាននៃសាសនា និន្នាការភេទអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ ឬលក្ខណៈភេទ។ | អូស្ត្រាលី | ទទួល |
| ១១០.៥៥ | វិសោធនកម្មមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញដែលអនុញ្ញាតឱ្យគូស្រករភេទដូចគ្នារៀបការបាន។ | កាណាដា | ទទួល |

*ប្រភពព័ត៌មាន៖ ព្រឹត្តិបត្រព័ត៌មាននៃ ម.ស.ម.ក. រយៈពេលមួយឆ្នាំបន្ទាប់ពីលទ្ធផលនៃការពិនិត្យជាសកលតាមកាលកំណត់ (យូ.ភី.អ) ជុំទី៣ របស់ប្រទេសកម្ពុជា*

ប៉ុន្តែអនុសាសន៍ទាំងនេះមិនទាន់មានការអនុវត្តនៅឡើយ ថ្វីបើរដ្ឋាភិបាលកម្ពុជាបានបង្ហាញនូវចេតនាខ្លះក្នុងការអនុម័តច្បាប់ប្រឆាំងនឹងការរើសអើង នេះបើតាមការថ្លែងរបស់ឯកឧត្តម ***កែវ រ៉េមី*** ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា នៅថ្ងៃទិវាសប្តាហ៍មោទកភាពឆ្នាំ២០២០ ថា៖

[44] សលាកបត្រព័ត៌មានរបស់ ម.ស.ម.ក 'One Year On Since Cambodia's Third UPR Review Outcome' (ខែកក្កដា ឆ្នាំ២០២០) <https://cchrcambodia.org/admin/media/newsletter/newsletter/english/SOGIE_Third%20UPR%20Review%20Outcome_ENG.pdf>.

*«សហគមន៍ និងក្រុមគ្រួសារដែលមានកូន ក្មួយ ឬចៅ ហើយបើសិនជាគាត់ជាអ្នកស្រឡាញ់ភេទដូចគ្នា បង្ហាញនូវអត្តសញ្ញាណយេនឌ័រមាននិន្នាការភេទ ស្រឡាញ់ភេទដូចគ្នា សូមឱ្យបងប្អូនទទួលស្គាល់ការពិត និង ចៀសវាងប្រើហិង្សាលើរូបរាងកាយ ហិង្សាតាមរយៈពាក្យសំដីប្រមាថ តិះដៀល ឬបណ្តេញកូនចៅចេញពីផ្ទះ និងហិង្សាតាមរយៈនៃការគាបសង្កត់ផ្លូវចិត្តជាដើម សូមផ្តល់នូវសិទ្ធិសេរីភាព និងទទួលស្គាល់ពួកគេ។ កាល ណាបើយើងធ្វើជាពលរដ្ឋល្អឱ្យសហគមន៍ និងសង្គមទទួលស្គាល់ថា យើងមិនមែនជាមនុស្សដែលធ្វើឱ្យគេភ័យ ខ្លាច ឱ្យគេយល់ថាការស្រឡាញ់ភេទដូចគ្នា គឺជាធម្មជាតិ។ ខ្ញុំជឿជាក់ថា រាជរដ្ឋាភិបាល ជាពិសេសស្ថាប័ននីតិ បញ្ញត្តិនឹងរៀបចំច្បាប់គាំទ្រក្មួយៗជាមិនខាន»* ។

ស្របពេលដែលមានសេចក្តីថ្លែងគាំទ្រដល់អ្នកស្រឡាញ់ភេទដូចគ្នាពីសំណាក់មន្ត្រីរដ្ឋាភិបាល ត្រូវបាន សាទរ ប្រការដែលចាំបាច់នោះគឺត្រូវបញ្ចូលប្រសាសន៍ និងការប្តេជ្ញាចិត្តទាំងនេះទៅក្នុងវិធានការច្បាប់ និង គោលនយោបាយជាក់លាក់។

# មេរៀនទី ៦៖ ទស្សនៈរបស់ពលរដ្ឋលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ

## ៦.១ បុរេនិច្ឆ័យ និងផ្នត់គំនិតរើសអើង

បទដ្ឋានវប្បធម៌ដែលកំណត់ឱ្យបុរសត្រូវមានឥរិយាបថយ៉ាងនេះ និងស្រ្តីត្រូវមានឥរិយាបថយ៉ាងនោះដែលបានចាក់ឫសគល់យ៉ាងជ្រៅជាច្រើនសតវត្សរ៍មកហើយនោះ នៅតែបន្តមានឥទ្ធិពលខ្លាំងលើផ្នត់គំនិត និងបទដ្ឋានយេនឌ័រនៅក្នុងសង្គមកម្ពុជា ។ ផ្នត់គំនិតយេនឌ័រនេះក៏នៅតែបន្តកើតមាននៅក្នុងសង្គម និងជំរុញឱ្យមានបុរេនិច្ឆ័យបែបអវិជ្ជមានលើអ្នកស្រឡាញ់ភេទដូចគ្នាផងដែរ។

ការស្ទង់មតិមួយដែលបានធ្វើឡើងដោយសហគមន៍ឥន្ទធនូកម្ពុជា[45] ក្នុងឆ្នាំ២០១៥ បានរកឃើញថា៖

- ៦៥ ភាគរយនៃអ្នកស្រឡាញ់ភេទផ្ទុយគ្នាជឿថា ការក្លាយជាអ្នកស្រឡាញ់ភេទដូចគ្នាគឺប្រឆាំងនឹងវប្បធម៌ និងប្រពៃណីខ្មែរ
- ៧៥ ភាគរយនៃអ្នកស្រឡាញ់ភេទផ្ទុយគ្នាជឿថាការរៀបអាពាហ៍ពិពាហ៍ភេទដូចគ្នា គឺប្រឆាំងនឹងវប្បធម៌ និងប្រពៃណីទំនៀមទម្លាប់ខ្មែរ ហើយ
- ៥៩ ភាគរយនៃអ្នកស្រឡាញ់ភេទផ្ទុយគ្នាជឿថាការរៀបអាពាហ៍ពិពាហ៍ភេទដូចគ្នា គឺប្រឆាំងនឹងធម្មជាតិ។

ទោះជាយ៉ាងណាក៏ដោយ ការទទួលស្គាល់ និងការរួបរួមគ្នា នៃសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាកំពុងកើនឡើងដោយមានការយល់ដឹងកាន់តែ

**ពាក្យគន្លឹះសំខាន់ៗសម្រាប់មេរៀនទី ៦**

- **ចេញមុខជាចំហ៖** អ្នកស្រឡាញ់ភេទដូចគ្នាដែលហ៊ានបង្ហាញ/ប្រាប់ដល់មិត្តភក្តិ ឬឪពុកម្តាយអំពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទរបស់ខ្លួន។
- **ការរើសអើង៖** ការប្រព្រឹត្ត ដោយផ្តាំផ្គង និងអយុត្តិធម៌ផ្សេងៗចំពោះនរណាម្នាក់ដោយផ្អែកលើឋានៈ/ចរិតលក្ខណៈណាមួយដែលពួកគេមាន។
- **អ្នកប្តូរយេនឌ័រ(អ្នកប្តូរភេទ)៖** បុគ្គលដែលមានអត្តសញ្ញាណយេនឌ័រ និង/ឬការបង្ហាញទំនោរយេនឌ័រខុសពីភេទកំណើតរបស់ពួកគេ។
- **អ្នកស្រឡាញ់ភេទដូចគ្នា៖** បុគ្គលដែលមានអារម្មណ៍/មនោសញ្ចេតនា ឬមានចំណង់ផ្លូវភេទចំពោះបុគ្គលដែលមានភេទដូចគ្នា ឬអ្នកមានយេនឌ័រដូចខ្លួន។
- **អ្នកស្រឡាញ់ភេទផ្ទុយគ្នា៖** បុគ្គលដែលមានអារម្មណ៍/មនោសញ្ចេតនា ឬ មានចំណង់ផ្លូវភេទចំពោះបុគ្គលដែលមានភេទផ្ទុយគ្នា ឬអ្នកមានយេនឌ័រមិនដូចខ្លួន។
- **អាពាហ៍ពិពាហ៍ភេទដូចគ្នា៖** ការរៀបអាពាហ៍ពិពាហ៍រវាងមនុស្សភេទដូចគ្នា។
- **គូស្នេហ៍ភេទដូចគ្នា៖** ដៃគូពីរនាក់ដែលមានភេទដូចគ្នា ឬ ដៃគូដែលមានម្នាក់ ឬទាំងពីរនាក់ដែលមានយេនឌ័រកំណត់មិនច្បាស់លាស់ ថាតើជាបុរស ឬជាស្ត្រី ឬក៏ជាអ្នកប្តូរយេនឌ័រ។
- **ការផាត់ចេញពីសង្គម៖** នៅពេលដែលបុគ្គលម្នាក់ត្រូវបានគេបដិសេធក្នុងការទទួលបានធនធាននានា សិទ្ធិ និងលទ្ធភាពក្នុងការចូលរួមក្នុងសកម្មភាពធម្មតាដូចប្រជាពលរដ្ឋទូទៅផ្សេងទៀតនៅក្នុងសង្គម។
- **សៀវភៅគ្រួសារ៖** សៀវភៅដែលចេញដោយរដ្ឋាភិ-បាលសម្រាប់កត់ត្រាអំពីទំនាក់ទំនងនៅក្នុងគ្រួសារ។

[45] សហគមន៍ឥន្ទធនូកម្ពុជា និងធីអ៊ិនអេស (TNS) «របាយការណ៍ស្រាវជ្រាវស្តីពីទស្សនៈយល់ឃើញអាកប្បកិរិយា និងឥរិយាបថចំពោះអ្នកស្រឡាញ់ភេទដូចគ្នា» (ខែធ្នូ ឆ្នាំ២០១៥) <https://www.rockcambodia.org/wp-content/uploads/2020/07/TNS-Research-Report-on-Opinions-Attitudes-and-Behavior-toward-the-LGBT-Population-in-Cambodia.pdf>.

ទូលំទូលាយជាបណ្ដើរៗអំពីបញ្ហាអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងសហគមន៍ ព្រមទាំងការទទួលស្គាល់ និងការរាប់បញ្ចូលអ្នកស្រឡាញ់ភេទដូចគ្នាមានការកើនឡើងនៅទូទាំងប្រទេសកម្ពុជា។

## ៦.២ បទដ្ឋានវប្បធម៌ និងឥរិយាបថរើសអើងលើអ្នកស្រឡាញ់ភេទដូចគ្នា

### ៦.២.១ សាសនា ទស្សនៈព្រះពុទ្ធសាសនាលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ

*កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) «អ្នកស្រឡាញ់ភេទដូចគ្នានៅអាស៊ីៈ របាយការណ៍ប្រចាំប្រទេសកម្ពុជា» (ឆ្នាំ២០១៤)*[46]

*ម.ស.ម.ក «ការបើកចំហនៅព្រះរាជាណាចក្រកម្ពុជា៖ ពលរដ្ឋខ្មែរដែលស្រឡាញ់ភេទដូចគ្នា» (ឆ្នាំ២០១០)*[47]

ព្រះពុទ្ធសាសនា ដែលមានប្រជាពលរដ្ឋកម្ពុជាប្រមាណ ៩៦ ភាគរយគោរពប្រតិបត្តិតាម។ ព្រះពុទ្ធសាសនាមិនបានបែងចែកពីភាពខុសគ្នារវាងការស្រឡាញ់ភេទដូចគ្នា និងការស្រឡាញ់ភេទផ្ទុយគ្នានោះទេ។ ពេលខ្លះការស្រឡាញ់ភេទដូចគ្នា គឺប្រៀបបីដូចជា «ផលនៃកម្ម» ដូច្នេះហើយបានជាព្រះពុទ្ធសាសនាមានទស្សនៈអប់រំឱ្យមនុស្សយល់ថានោះ គឺជារឿងធម្មតាបើ «ជីវិតបែបណា ទុកឱ្យជីវិតបែបនោះចុះ» ឬ គោលការណ៍ «មិនសួរ មិនប្រាប់» ទាក់ទងទៅនឹងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ។

- **អរិយមគ្គអង្គប្រាំបី ឬមាគ៌ាឆ្ពោះទៅរកការត្រាស់ដឹង៖** ជំហាននៃអរិយមគ្គអង្គប្រាំបីមានលើកឡើងទាក់ទងនឹងសកម្មភាពផ្លូវភេទដែរ ប៉ុន្តែមិនមានបទប្បញ្ញត្តិជាក់លាក់ណាមួយហាមឃាត់ការស្រឡាញ់ភេទដូចគ្នាឡើយ ក្រៅតែពីពុទ្ធឱវាទទូន្មាន *«ឱ្យវៀរចាកការសេពមេថុន ឬការប្រព្រឹត្តខុសក្នុងកាម»*[48]។
- **អាពាហ៍ពិពាហ៍៖** គ្មានការមាក់ងាយណាមួយទៅលើអ្នកគ្មានកូន ឬចំពោះអ្នកដែលមិនបានរៀបអាពាហ៍ពិពាហ៍ឡើយនៅក្នុងព្រះពុទ្ធសាសនា ហើយតម្លៃក៏មិនស្ថិតនៅលើការរៀបអាពាហ៍ពិពាហ៍ ឬការបង្កើតកូននោះដែរ។ ប្រការដែលសំខាន់នោះថាតើការរស់នៅនាំមកនូវសេចក្ដីស្រឡាញ់ និងការគោរពដែរ ឬយ៉ាងណា។ ទោះយ៉ាងណាក៏ដោយ ទំនៀមទម្លាប់វប្បធម៌កម្ពុជា និងសម្ពាធផ្នែកសង្គមមានឥទ្ធិពលជាងការអប់រំទូន្មាននៅក្នុងព្រះពុទ្ធសាសនា។

---

[46] កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) «អ្នកស្រឡាញ់ភេទដូចគ្នានៅអាស៊ីៈ របាយការណ៍ប្រចាំប្រទេសកម្ពុជា» (ឆ្នាំ២០១៤) <https://www.asia-pacific.undp.org/content/rbap/en/home/library/democratic_governance/hiv_aids/being-lgbt-in-asia--cambodia-country-report.html>.

[47] *ម.ស.ម.ក «ការបើកចំហនៅព្រះរាជាណាចក្រកម្ពុជាៈ ពលរដ្ឋខ្មែរដែលស្រឡាញ់ភេទដូចគ្នា» (ឆ្នាំ២០១០)* <http://sogi.sithi.org/admin/upload/media/118-egkykni1336367358.pdf>

[48] សម្រាប់ព័ត៌មានបន្ថែមសូមមើល Walpola Rahula, «តើព្រះពុទ្ធបង្រៀនអ្វីខ្លះ» (ឆ្នាំ១៩៥៩) <http://www.ahandfulofleaves.org/documents/What%20the%20Buddha%20Taught_Rahula.pdf> p.47.

### ៦.២.២ ការផាត់ចេញពីសង្គម និងការរើសអើង



*កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) «អ្នកស្រឡាញ់ភេទដូចគ្នានៅអាស៊ីៈ របាយការណ៍ប្រចាំប្រទេសកម្ពុជា» (ឆ្នាំ២០១៤)*[49]

អ្នកស្រឡាញ់ភេទដូចគ្នាប្រឈមនឹងទម្រង់នៃការរើសអើងជាច្រើន ដែលជាធម្មតាចាប់តាំងពីកុមារភាពមកម្ល៉េះ ដែលនេះជាលទ្ធផលនៃការផ្តល់តម្លៃនៃវប្បធម៌ដែលបានចាក់ឫសគល់យ៉ាងជ្រៅ។ ការយល់ឃើញអវិជ្ជមានជាទូទៅលើសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា និងកង្វះការយល់ដឹងអំពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទរបស់ប្រជាពលរដ្ឋនៅក្នុងសង្គមកម្ពុជាបាននាំឱ្យកើតមានការរើសអើងមួយចំនួនទៅលើសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាមួយចំនួនដូចខាងក្រោមៈ

- ភាពអាម៉ាស់ៈ៦៣ ភាគរយ នៃបុរសបានឆ្លើយតបនឹងការស្ទង់មតិបានយល់ស្របថា «***ខ្ញុំមានភាពអាម៉ាស់ណាស់ដែលមានកូនប្រុសជាអ្នកស្រឡាញ់ភេទដូចគ្នា***»
- **ការវាយប្រហារ និងការរំលោភបំពានលើអ្នកស្រឡាញ់ភេទដូចគ្នាៈ** ៥៦ ភាគរយនៃអ្នកឆ្លើយតបចំពោះការស្ទង់មតិក្នុងរបាយការណ៍នៃការផាត់ចេញពីសង្គមក្នុងឆ្នាំ២០១៣ បានលើកឡើង **អំពីបទពិសោធដែលធ្លាប់ទទួលរងអំពើហិង្សាពីសមាជិកគ្រួសារ និងសហគមន៍** ដោយសារតែនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទរបស់ពួកគេ។
- **ការផ្សព្វផ្សាយអវិជ្ជមានរបស់ប្រព័ន្ធផ្សព្វផ្សាយៈ** ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានមួយចំនួនប្រឌិតព័ត៌មានប្រើប្រាស់ពាក្យពេចន៍រើសអើង និងជាទូទៅប្រើសំនួនវោហារបញ្ចេញបញ្ចូលគ្មានវិជ្ជាជីវៈពិពណ៌នាលើអ្នកស្រឡាញ់ភេទដូចគ្នា។ ការប្រើប្រាស់ពាក្យពេចន៍របស់ប្រព័ន្ធផ្សព្វផ្សាយនៅក្នុងស្រុកមួយចំនួនមានបញ្ហាជាច្រើនតាមរយៈការផ្សាយអវិជ្ជមានរបស់ពួកគេទាក់ទងនឹងអ្នកស្រឡាញ់ភេទដូចគ្នា។
- **រងការចោទប្រកាន់ពីបទល្មើសដោយពុំត្រឹមត្រូវៈ** អ្នកប្តូរយេនឌ័រជាស្ត្រីនៅក្នុងខេត្តសៀមរាបធ្លាប់ត្រូវបានរារាំងការចូលទៅក្នុងតំបន់ទេសចរណ៍សំខាន់ៗ ដោយសារតែ**ការសន្មតខុសថាពួកគេជាចោរ** ហើយអ្នកខ្លះត្រូវបានចាប់ខ្លួនដោយពុំត្រឹមត្រូវទៀតផង។
- **ការកេងប្រវ័ញ្ចៈ** អ្នកស្រឡាញ់ភេទដូចគ្នាមួយចំនួនបានរាយការណ៍ថាខ្លួនត្រូវបានគេប្រើឱ្យធ្វើជាមេខ្យល់ជួញដូរក្នុងសកម្មភាពឧក្រិដ្ឋ និងត្រូវបានមន្ត្រីពុករលួយកេងប្រវ័ញ្ចផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ។

---

[49] កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) «អ្នកស្រឡាញ់ភេទដូចគ្នានៅអាស៊ីៈ របាយការណ៍ប្រចាំប្រទេសកម្ពុជា» (ឆ្នាំ២០១៤) <https://www.asia-pacific.undp.org/content/rbap/en/home/library/democratic_governance/hiv_aids/being-lgbt-in-asia--cambodia-country-report.html>.

### ៦.២.៣ ផលប៉ះពាល់នៃការរើសអើងលើអ្នកស្រឡាញ់ភេទដូចគ្នា

*របាយការណ៍ស្រាវជ្រាវរបស់អង្គការសហគមន៍ឥន្ទធនូកម្ពុជានិងក្រុមហ៊ុនកន្តា (Kantar TNS) ប្រចាំកម្ពុជា «គំនិត ឥរិយាបថ និងអាកប្បកិរិយាចំពោះអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា» (ឆ្នាំ២០១៥)* [50]

ការផាត់ចេញពីសង្គម និងការរើសអើងមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើគំនិតផ្ទាល់ខ្លួនរបស់អ្នកស្រឡាញ់ភេទដូចគ្នា និងលទ្ធភាពរបស់ពួកគេក្នុងការរស់នៅទៅតាមជីវភាពរបស់ខ្លួន។

- ២៩ ភាគរយនៃអ្នកស្រឡាញ់ភេទដូចគ្នាមិន «ចេញមុខជាចំហ» ហើយជីវិតរបស់ពួកគេរស់នៅក្នុងភាពភ័យខ្លាច និងខ្មាសអៀន
- ៧៧ ភាគរយនៃអ្នកស្រឡាញ់ភេទដូចគ្នាបាន «ចេញមុខជាចំហ» តែជាមួយមិត្តភក្តិជិតស្និទ្ធរបស់ពួកគេប៉ុណ្ណោះ
- ៥៤ ភាគរយ «ចេញមុខចំហ» ចំពោះសមាជិកគ្រួសារតែរយៈពេលខ្លី
- ២១ ភាគរយនៃអ្នកស្រឡាញ់ភេទដូចគ្នា ចង់ចេញមុខជាចំហដោយគ្មានការលាក់លៀម
- ត្រឹមតែ១៩ ភាគរយ នៃអ្នកស្រឡាញ់ភេទដូចគ្នាប៉ុណ្ណោះ ដែលទទួលស្គាល់ខ្លួនឯង
- ៨២ ភាគរយនៃក្រុមអ្នកស្រឡាញ់ភេទដូចគ្នា ចាត់ទុកការរើសអើងទាក់ទងនឹងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទថាជាបញ្ហាចម្បងដែលពួកគេបានជួបប្រទះ
- ៤២ ភាគរយនៃអ្នកស្រឡាញ់ភេទដូចគ្នា មានអារម្មណ៍ខ្មាសអៀនដោយសារតែនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទរបស់ពួកគេ
- ២៥ ភាគរយនៃអ្នកស្រឡាញ់ភេទដូចគ្នាមានអារម្មណ៍ថាអាណិតខ្លួនឯង និង
- ៥០ ភាគរយ នៃអ្នកស្រឡាញ់ភេទដូចគ្នាទំនងជាច្រើនជាងមនុស្សដែលស្រឡាញ់ភេទផ្ទុយគ្នា (៤០ ភាគរយ) បញ្ជាក់ថាអ្នកស្រឡាញ់ភេទដូចគ្នាមិនមែនជាមនុស្សធម្មតា ឬតាមធម្មជាតិទេ។

ការផាត់ចេញពីសង្គម និងការរើសអើងដែលមានផលប៉ះពាល់យ៉ាងខ្លាំងផងដែរទៅលើសុខុមាលភាពផ្លូវចិត្តរបស់អ្នកស្រឡាញ់ភេទដូចគ្នាដូចជា ៖

- ត្រឹមតែ ១៥ ភាគរយនៃអ្នកស្រឡាញ់ភេទដូចគ្នាមានអារម្មណ៍ថាសប្បាយរីករាយ
- ៤៧ ភាគរយនៃអ្នកស្រឡាញ់ភេទដូចគ្នាជួបប្រទះនឹងការរំខានដំណេក
- ២៧ ភាគរយនៃអ្នកស្រឡាញ់ភេទដូចគ្នាជួបប្រទះនឹងបញ្ហាក្នុងការបរិភោគ
- ៣០ ភាគរយនៃអ្នកស្រឡាញ់ភេទដូចគ្នាធ្លាប់មានគំនិតអវិជ្ជមានច្រើនលើសលុប
- ២២ ភាគរយនៃអ្នកស្រឡាញ់ភេទដូចគ្នាមានអារម្មណ៍ថាអស់សង្ឃឹម

---

[50] សហគមន៍ឥន្ទធនូកម្ពុជា និងធីអ៊ិនអេស (TNS) «របាយការណ៍ស្រាវជ្រាវស្តីពីទស្សនៈយល់ឃើញអាកប្បកិរិយា និងឥរិយាបថចំពោះអ្នកស្រឡាញ់ភេទដូចគ្នា» (ខែធ្នូ ឆ្នាំ២០១៥) <https://www.rockcambodia.org/wp-content/uploads/2020/07/TNS-Research-Report-on-Opinions-Attitudes-and-Behavior-toward-the-LGBT-Population-in-Cambodia.pdf>.

- ២៥ ភាគរយនៃអ្នកស្រឡាញ់ភេទដូចគ្នាបង្ហាញអាកប្បកិរិយាមិនញញើត ក្នុងនោះ ២៤ ភាគរយសេពគ្រឿងស្រវឹងច្រើនជាងមធ្យមជាប្រចាំ
- ៣៧ ភាគរយនៃអ្នកស្រឡាញ់ភេទដូចគ្នាធ្លាប់មានស្មារតីមិននឹងធឹង និង
- ១៩ ភាគរយនៃអ្នកស្រឡាញ់ភេទដូចគ្នារាយការណ៍អំពីបទពិសោធដែលទទួលបានសុភមង្គលក្នុងជីវិតមានកម្រិត។

## ៦.២.៤ ឧបសគ្គក្នុងការទទួលបានសិទ្ធិរៀបអាពាហ៍ពិពាហ៍

*ម.ស.ម.ក «គ្រួសារឥន្ទធនូកម្ពុជា» (ឆ្នាំ២០១៧)*[51]

នៅក្នុងប្រទេសកម្ពុជាគ្រួសារ គឺជាមូលដ្ឋានគ្រឹះនៃជីវិត ប៉ុន្តែលទ្ធភាពរបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាក្នុងការអនុវត្តសិទ្ធិនេះ គឺពិបាកដោយសារតែបទដ្ឋានយេនឌ័រ និងការរំពឹងទុក ដោយសាររចនាសម្ព័ន្ធគ្រួសារមិនច្បាស់លាស់ ពោល គឺបុរស និងស្ត្រីត្រូវតែរៀបការ និងមានកូន។ ឧបសគ្គទាំងផ្នែកផ្លូវច្បាប់ និងសង្គមបានរារាំងអ្នកស្រឡាញ់ភេទដូចគ្នាក្នុងការទទួលបានសិទ្ធិបង្កើតគ្រួសារ។ សិទ្ធិទទួលបានគ្រួសាររួមមាន សិទ្ធិស្មើគ្នាក្នុងអាពាហ៍ពិពាហ៍ សិទ្ធិសុំកូនចិញ្ចឹម និងការទទួលស្គាល់យេនឌ័រស្របច្បាប់។ សិទ្ធិទាំងអស់នេះត្រូវបានបដិសេធទាំងស្រុង ឬដោយផ្នែកខ្លះចំពោះអ្នកស្រឡាញ់ភេទដូចគ្នា។

### *អាពាហ៍ពិពាហ៍៖*

អាពាហ៍ពិពាហ៍រវាងមនុស្សពីរនាក់ដែលមានភេទដូចគ្នា («អាពាហ៍ពិពាហ៍ភេទដូចគ្នា») មិនត្រូវបានទទួលស្គាល់នៅក្នុងច្បាប់កម្ពុជាឡើយ។ ដូច្នេះគូស្រករឥន្ទធនូ (គូស្រករភេទដូចគ្នា) ជាច្រើនរួមរស់នៅជាមួយគ្នា និងរៀបចំពិធីអាពាហ៍ពិពាហ៍ក្រៅផ្លូវការដើម្បីការរួមសង្វាសរបស់ពួកគេ។

- ៨៩,៧២ ភាគរយនៃអ្នកស្រឡាញ់ភេទដូចគ្នាបានលើកឡើងថា អាពាហ៍ពិពាហ៍មានសារៈសំខាន់សម្រាប់ពួកគេ
- ៣២,៣២ ភាគរយចាត់ទុកអាពាហ៍ពិពាហ៍ជាមូលដ្ឋានគ្រឹះស្របតាមប្រពៃណី និងទំនៀមទម្លាប់ខ្មែរ
- ៥២,៣៤ ភាគរយ នៃគូស្រករឥន្ទធនូដែលរស់នៅជាមួយគ្នាជឿថាទំនាក់ទំនងរបស់ពួកគេត្រូវបានទទួលស្គាល់ដោយស្របច្បាប់

នេះនៅតែមានការបង្ហាញឱ្យឃើញអំពីអវត្តមាននៃបទប្បញ្ញត្តិស្តីពីសមភាពអាពាហ៍ពិពាហ៍ដែលជាទម្រង់នៃការផាត់ចេញពីវប្បធម៌សង្គម និងធ្វើឱ្យគូស្រករឥន្ទធនូឃ្លាតឆ្ងាយចេញពីសហគមន៍របស់ពួកគេ និង

- ៨៧,៨៥ ភាគរយនៃគូស្រករឥន្ទធនូដែលរស់នៅជាមួយគ្នាជឿថា ការរើសអើងដែលពួកគេប្រឈមនឹងត្រូវកាត់បន្ថយ ប្រសិនបើច្បាប់អនុញ្ញាតឱ្យពួកគេរៀបអាពាហ៍ពិពាហ៍ជាមួយដៃគូពួកគេ។

[51] ម.ស.ម.ក «គ្រួសារឥន្ទធនូកម្ពុជា» (ឆ្នាំ២០១៧) <https://cchrcambodia.org/admin/media/report/report/english/2017-11-22-CCHR-Report-Cambodia-Rainbow-Families_ENG.pdf>.

### *ការសុំកូន៖*



ការបដិសេធគូស្រករឥន្ទធនូ (គូស្រករភេទដូចគ្នា) ក្នុងការរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ បានធ្វើឱ្យពួកគេបាត់បង់នូវអត្ថប្រយោជន៍មួយចំនួន បើប្រៀបធៀបនឹងអាពាហ៍ពិពាហ៍របស់អ្នកស្រឡាញ់ភេទផ្ទុយគ្នាទទួលបានដូចជាសិទ្ធិក្នុងការសុំកូនជាដើម។ ក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាអនុញ្ញាតចំពោះគូស្រករដែលរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ប៉ុណ្ណោះ ទើបមានសិទ្ធិក្នុងការសុំកូន។ ទោះជាយ៉ាងណាក៏ដោយ គូស្រករស្រឡាញ់ភេទដូចគ្នាប្រមាណ ៣២,៧១ ភាគរយ មានកូនក្នុងបន្ទុកដើម្បីមើលថែ ដែលនេះមានន័យថាយ៉ាងហោចណាស់ក្នុងដៃគូមួយមានកូនចិញ្ចឹមម្នាក់។ ៦៧,៦៤ ភាគរយ គឺជាការសុំកូនចិញ្ចឹមធម្មតា ឬក្នុងទម្រង់នៃកិច្ចព្រមព្រៀងក្រៅផ្លូវការ។ ៤០ ភាគរយ នៃគូស្រករឥន្ទធនូបានយកសមាជិកគ្រួសារដូចជាក្មួយស្រី ឬក្មួយប្រុសមកចិញ្ចឹម។

- ៨៧,៨៥ ភាគរយនៃគូស្រករភេទដូចគ្នាបានបញ្ជាក់ថា ការមានកូនគឺមានសារៈសំខាន់ណាស់ចំពោះពួកគេ
- ៦៩,៧០ ភាគរយនៃគូស្រករភេទដូចគ្នាជឿថាពួកគេនឹងប្រឈមនឹងការរើសអើងតិចតួចប្រសិនបើពួកគេត្រូវបានអនុញ្ញាតឱ្យសុំកូនពេញលេញ
- ៤៥,៧១ ភាគរយនៃគូស្រករភេទដូចគ្នាដែលមានកូនចិញ្ចឹមបានទទួលសៀវភៅគ្រួសារ និង
- ៨៨,៨៨ ភាគរយនៃមន្ត្រីអាជ្ញាធរមូលដ្ឋានដែលបានសម្ភាសន៍បានលើកឡើងថា នឹងគាំទ្រចំពោះគូស្រករស្រឡាញ់ភេទដូចគ្នាដែលយកក្មេងមកចិញ្ចឹម។

### *ករណីសិក្សា៖ ធីតា និង ពៅ*

ធីតា និងពៅ បានសុំកូនចំនួន ៣ នាក់មកចិញ្ចឹម គឺកូនស្រីម្នាក់មានអាយុ ១ ឆ្នាំ កន្លះ កូនប្រុសម្នាក់អាយុ ៣ខែ និងកូនស្រីម្នាក់ទៀតអាយុ ១ខែ។ មេឃុំបានចេញលិខិតទទួលស្គាល់កូនចិញ្ចឹមរបស់ពួកគាត់ ប៉ុន្តែពុំបានចេញសៀវភៅគ្រួសារជូនទេ ដោយសារតែសំបុត្រកំណើតរបស់ពួកគាត់ទាំងពីរបញ្ជាក់ថាពួកគាត់ជាស្ត្រី។ ពេលមួយ មេឃុំធ្លាប់ផ្តល់សៀវភៅគ្រួសារជូនពួកគាត់ដែរ ប៉ុន្តែបានយកត្រឡប់ទៅវិញ ព្រោះមន្ត្រីឃុំប្រឡំចេញជូនពួកគាត់ និងបារម្ភថាជារឿងខុសច្បាប់។ ការមានសៀវភៅគ្រួសារ គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់ធីតា និងពៅ ពីព្រោះជួយពន្លឿនការទទួលស្គាល់ជាដៃគូ និងជាគ្រួសារមួយ ហើយពួកគាត់ជឿជាក់ថា ការទទួលបានសៀវភៅគ្រួសារអាចធ្វើឱ្យជីវិតរបស់ពួកគាត់កាន់តែមានសុភមង្គល និងមានភាពងាយស្រួលជាងមុន។ ពួកគាត់បានលើកឡើងពីការប្រឈមនឹងការរើសអើងនៅក្នុងឃុំរបស់ពួកគាត់ មុនពេលពួកគាត់សុំកូន ប៉ុន្តែចាប់តាំងពីពួកគាត់មានកូនចិញ្ចឹម ហើយមានកម្រិតជីវភាពរស់នៅសមរម្យមក ប្រជាពលរដ្ឋក្នុងសហគមន៍បានកោតសរសើរចំពោះពួកគាត់។

### ៦.២.៥ ការបដិសេធពីគ្រួសារ

កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ «អ្នកស្រឡាញ់ភេទដូចគ្នាប្រចាំតំបន់អាស៊ីៈ របាយការណ៍ប្រចាំប្រទេសកម្ពុជា» (ឆ្នាំ២០១៤)[52]

*របាយការណ៍ស្រាវជ្រាវរបស់អង្គការសហគមន៍ឥន្ទធនូកម្ពុជា និងក្រុមហ៊ុនកន្តា (Kantar TNS) ប្រចាំកម្ពុជា «គំនិតឥរិយាបថ និងអាកប្បកិរិយាចំពោះអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា» (ឆ្នាំ២០១៥)*

*ម.ស.ម.ក «ការរើសអើងលើអ្នកប្តូរយេនឌ័រជាស្ត្រីនៅតាមទីប្រជុំជនក្នុងព្រះរាជាណាចក្រកម្ពុជា» (ឆ្នាំ២០១៦)*[53]

*Will Jackson, 'ការបង្ខំឱ្យទទួលការ "ព្យាបាល" គឺបង្ហាញថាសមភាពហាក់ដូចជានៅឆ្ងាយសម្រាប់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា (ភ្នំពេញប៉ុស្តិ៍ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៤[54])*

ការទទួលស្គាល់ពីសំណាក់គ្រួសារនៅតែជាឧបសគ្គធំបំផុតមួយសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នាដែលត្រូវជម្នះ។ អ្នកស្រឡាញ់ភេទដូចគ្នាជាច្រើនបានរាយការណ៍ពីការមិនទទួលស្គាល់និន្នាការភេទ និងអត្ត-សញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទរបស់ពួកគេពីសំណាក់ក្រុមគ្រួសារ ហើយមានការប្រព្រឹត្តិខុសៗគ្នា ឬការបដិសេធដាច់អហង្ការ។ គ្រួសារខ្លះជឿថាការក្លាយជាអ្នកស្រឡាញ់ភេទដូចគ្នានាំមកនូវភាពអាម៉ាស់ និងធ្វើឱ្យអាប់ឱនកិត្តិយសគ្រួសារ។ ឪពុកម្តាយខ្លះទៀតជឿថាការក្លាយជាអ្នកស្រឡាញ់ភេទដូចគ្នា គឺជាជំងឺផ្លូវចិត្ត ហើយព្យាយាមនាំកូនពួកគេទៅរកពេទ្យខាងសរសៃប្រសាទ ឬគ្រូមន្តអាគមន៍ដើម្បីទទួល «ការព្យាបាល» និងដើម្បី «កម្ចាត់វិញ្ញាណអាក្រក់» ដែលសណ្ឋិតក្នុងខ្លួនកូនរបស់ពួកគាត់។ អ្នកស្រឡាញ់ភេទដូចគ្នាមួយចំនួនបានរាយការណ៍ពីបទពិសោធដែលធ្លាប់រងការជេរប្រមាថ ស្តីបន្ទោស ឬការដេកហូតទ្រព្យសម្បត្តិផ្ទាល់ខ្លួនពីសំណាក់ក្រុមគ្រួសាររបស់ខ្លួន ដោយមូលហេតុទាក់ទងនឹងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ។ គ្រួសារមួយចំនួនព្រមទាំងបានគំរាមកំហែងបំបែកបំបាក់ពួកគេ និងស្នើឱ្យអាជ្ញាធរបំបែកគូស្រករភេទដូចគ្នាចេញពីគ្នាទៀតផង។ ការបដិសេធរបស់គ្រួសារអាចមានផលប៉ះពាល់យ៉ាងខ្លាំងលើអ្នកស្រឡាញ់ភេទដូចគ្នា។

- ១៧ ភាគរយនៃឪពុកម្តាយដែលមានកូនជាអ្នកស្រឡាញ់ភេទដូចគ្នាបាននិយាយថាពួកគេនឹងបង្ខំកូនរបស់ពួកគេឱ្យជួបជាមួយមនុស្សដែលមានភេទផ្ទុយគ្នា និងបង្ខំឱ្យកូនរៀបការ
- ៥៣,៤៩ ភាគរយនៃអ្នកប្តូរយេនឌ័រជាស្ត្រីនៅតាមទីប្រជុំជន បាននិយាយថាសមាជិកគ្រួសារបានព្យាយាមបង្ខំពួកគេឱ្យរៀបការជាមួយអ្នកមានភេទផ្ទុយគ្នា

[52] កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ «អ្នកស្រឡាញ់ភេទដូចគ្នាប្រចាំតំបន់អាស៊ីៈ របាយការណ៍ប្រចាំប្រទេសកម្ពុជា» (ឆ្នាំ២០១៤) <https://www.asia-pacific.undp.org/content/rbap/en/home/library/democratic_governance/hiv_aids/being-lgbt-in-asia--cambodia-country-report.html>.

[53] ម.ស.ម.ក «ការរើសអើងលើអ្នកប្តូរយេនឌ័រជាស្ត្រីនៅតាមទីប្រជុំជនក្នុងព្រះរាជាណាចក្រកម្ពុជា» (ឆ្នាំ២០១៦) <https://cchrcambodia.org/index_old.php?url=project_page/project_page.php&p=report_detail.php&reid=115&id=3>.

[54] Will Jackson, 'ការបង្ខំឱ្យទទួលការ "ព្យាបាល" គឺបង្ហាញថាសមភាពហាក់ដូចជានៅឆ្ងាយសម្រាប់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា (ភ្នំពេញប៉ុស្តិ៍ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៤) < https://www.phnompenhpost.com/7days/equality-far-cambodia%E2%80%99s-lgbt-community-forced-undergo-%E2%80%98curing%E2%80%99>.

- ៤៨,៨៥ ភាគរយនៃអ្នកស្រឡាញ់ភេទដូចគ្នាបានរៀបរាប់ថាពួកគេត្រូវតែចាកចេញពីផ្ទះដោយសារនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទរបស់ពួកគេ ហើយ
- ១៥,២៧ ភាគរយធ្លាប់ត្រូវបានបណ្ដេញចេញពីផ្ទះទៀតផង។



*ករណីសិក្សា៖ មាស សុផានុត*

មាស សុផានុត មានភេទពីកំណើតជាស្ត្រី ប៉ុន្តែគាត់កំណត់អត្តសញ្ញាណខ្លួនឯងជាបុរស ហើយចាប់ផ្ដើមស្លៀកពាក់ជាបុរសពេលនៅរៀនវិទ្យាល័យ។ ម្ដាយរបស់សុផានុត បានព្យាយាមបង្ខំគាត់ឱ្យឈប់ស្លៀកសម្លៀកបំពាក់បុរសទៀត ពីព្រោះម្ដាយគាត់មានអារម្មណ៍មិនល្អដែលសុផានុតមើលទៅខុសពីអ្នកដទៃ ហើយថែមទាំងនាំនូវភាពអាម៉ាស់ដល់គ្រួសារ។ ម្ដាយរបស់សុផានុត បានដកទូរស័ព្ទ ផ្ដាច់ទំនាក់ទំនងគាត់ចេញពីមិត្តភក្តិ បង្ខំគាត់អោយនៅតែក្នុងផ្ទះ និងយកគាត់ទៅអោយគ្រូខ្មែរដើម្បី "ព្យាបាល" គាត់តាមបែបប្រពៃណី។ សុផានុត បានរៀបរាប់ថា បន្ទាប់ពីគាត់បានជួបហេតុការណ៍បែបនេះហើយ គាត់មានអារម្មណ៍ភ័យខ្លាចនឹងឪពុកម្ដាយរបស់គាត់ និងមានអារម្មណ៍ថាពួកគាត់ទាំងពីរមិនមែនជាគ្រួសាររបស់គាត់ទៀតទេ។

### ៦.២.៦ ការគំរាមកំហែង និងការបដិសេធនៅក្នុងសាលារៀន និងការអប់រំ

*ការសម្លុតអ្នកស្រឡាញ់ភេទដូចគ្នានៅតាមសាលារៀនក្នុងប្រទេសកម្ពុជា (ឆ្នាំ២០១៥)*[55]

[55] ម.ស.ម.ក. «ការសម្លុតអ្នកស្រឡាញ់ភេទដូចគ្នានៅតាមសាលារៀនក្នុងប្រទេសកម្ពុជា» (ឆ្នាំ២០១៥) <https://cchrcambodia.org/admin/media/report/report/english/2015_12_17_CCHR_REPORT_LGBT_Bullying_in_Cam_School_(ENG).pdf>.

*កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ «អ្នកស្រឡាញ់ភេទដូចគ្នានៅអាស៊ីៈ របាយការណ៍ប្រចាំប្រទេសកម្ពុជា» (ឆ្នាំ២០១៤)*[56]

អ្នកស្រឡាញ់ភេទដូចគ្នាភាគច្រើនធ្លាប់ទទួលរងការសម្លុត ការគំរាមកំហែងជារឿយៗតាំងពីកុមារភាពដែល អាចបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងររយៈពេលយូរទៅលើសុខភាពផ្លូវចិត្ត និងផ្លូវកាយរបស់ពួកគេ។



- ៦២,៧ ភាគរយនៃអ្នកស្រឡាញ់ភេទដូចគ្នាធ្លាប់ ទទួលរងការសម្លុតក្នុងអំឡុងពេលពួកគេសិក្សានៅសាលារៀន
- ក្នុងចំណោមអ្នកដែលបានរាយការណ៍អំពីការសម្លុតនៅសាលាមាន ៤២,០២ ភាគរយ បាននិយាយថាពួកគេធ្លាប់ត្រូវបានគេសម្លុត «ជាញឹកញាប់» ឬ «ជារៀងរាល់ថ្ងៃ»
- ៥៣,៨៥ ភាគរយ នៃអ្នកចូលរួមក្នុងការស្ទង់មតិបានលើកឡើងថា ពេលខ្លះពួកគេត្រូវបានគេសម្លុត
- ១៥,១២ ភាគរយ នៃអ្នកចូលរួមក្នុងការស្ទង់មតិបានលើកឡើងថា «មិនធ្លាប់» ឬ «កម្រ» ត្រូវបានគេសម្លុត និង
- ៩៣,៥៩ ភាគរយ ក្នុងចំណោមអ្នកចូលរួមក្នុងការស្ទង់មតិទាំងអស់យល់ថា ទោះការសម្លុតខ្លះៗ ឬទាំងស្រុងក្តី នោះគឺដោយសារតែនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទរបស់ពួកគេ។

មានការសម្លុត ឬការគំរាមកំហែងក្នុងទម្រង់ជាច្រើនលើសិស្សដែលស្រឡាញ់ភេទដូចគ្នា ដែលត្រូវបានកត់ត្រាទុក រួមមានតាមរយៈពាក្យសម្តីលើរូបរាងកាយ និងផ្លូវភេទ។

- ៨៤,៤៦ ភាគរយនៃអ្នកស្រឡាញ់ភេទដូចគ្នាដែលធ្លាប់រងការសម្លុតបានលើកឡើងថាពួកគេត្រូវបានគេសម្លុតដោយការប្រើប្រាស់ពាក្យសម្តី




[56] កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ «អ្នកស្រឡាញ់ភេទដូចគ្នាប្រចាំតំបន់អាស៊ីៈ របាយការណ៍ប្រចាំប្រទេសកម្ពុជា» (ឆ្នាំ២០១៤) <https://www.asia-pacific.undp.org/content/rbap/en/home/library/democratic_governance/hiv_aids/being-lgbt-in-asia--cambodia-country-report.html>.

- ៣៩,៧៤ ភាគរយ បានបញ្ជាក់ថាពួកគេត្រូវបានគេសម្លុតលើរូបរាងកាយ រួមមាន ការរុញច្រាន ការវាយតប់ ការស្តោះទឹកមាត់ដាក់ ការប្រើប្រាស់អំពើហិង្សា ការចាក់សោរក្នុងបន្ទប់ទឹក និងការលួចទ្រព្យសម្បត្តិជាដើម
- ៣៣,៣៣ ភាគរយត្រូវបានគេសម្លុត ដូចជា ជនរងគ្រោះត្រូវបានគេបង្ខំឱ្យទាញខោ ឬសំពត់ចុះក្រោម ការធ្វើត្រាប់តាម ឬការបំពានផ្លូវភេទដាក់ស្តែង និងការប៉ះពាល់ដោយបំពាន
- ៤៦,១៥ ភាគរយបានលើកឡើងថាពួកគេទទួលនូវការបដិសេធពីសង្គម
- ៩២,៣១ ភាគរយបានលើកឡើងថាមានការសម្លុតតាមរយៈពាក្យសម្តីជាញឹកញាប់ ម្តងកាល ឬជារៀងរាល់ថ្ងៃ
- ៧៣,០៨ ភាគរយនៃអ្នកស្រឡាញ់ភេទដូចគ្នាដែលត្រូវគេសម្លុតបានរៀបរាប់ថាពួកគេបានជួបប្រទះការសម្លុតនៅសាលារៀនជាញឹកញាប់ ម្តងម្កាល ឬជារៀងរាល់ថ្ងៃ និង
- ៤៨,៧២ ភាគរយ បានរៀបរាប់ពីបទពិសោធដែលពួកគេបានទទួលរងការសម្លុត ការបៀតបៀនផ្លូវភេទជាញឹកញាប់ ម្តងកាល ឬជារៀងរាល់ថ្ងៃ។

បទបញ្ជាផ្ទៃក្នុងសាលាអំពីឯកសណ្ឋានរបស់សិស្សមិនអាចបត់បែនបានឡើយ ព្រោះគោលការណ៍សាលាមិនអនុញ្ញាតឱ្យសិស្សបង្ហាញពីអត្តសញ្ញាណយេនឌ័ររបស់ពួកគេដោយសេរីឡើយពោលគឺ ក្មេងប្រុសត្រូវតែស្លៀកខោ ហើយក្មេងស្រីត្រូវស្លៀកសំពត់ ហើយ

- ២៦,៨៩ ភាគរយនៃសិស្សដែលជាអ្នកស្រឡាញ់ភេទដូចគ្នាបានលើកឡើងថា គ្រូតម្រូវឱ្យស្លៀកពាក់ឯកសណ្ឋានរបស់សាលាដែលធ្វើឱ្យពួកគេមានអារម្មណ៍មិនស្រណុកក្នុងចិត្ត។ តួលេខនេះបានកើនឡើងដល់ ៤០,៤៨ ភាគរយចំពោះអ្នកចូលរួមស្ទង់មតិ ដែលមានអត្តសញ្ញាណជាអ្នកប្តូរយេនឌ័រ។

មានរបាយការណ៍ជាច្រើនស្តីអំពីកុមារ ឬក្មេងជំទង់ដែលស្លៀកពាក់ ឬមានអាកប្បកិរិយាខុសពីភេទរបស់ពួកគេ ត្រូវបានតម្រូវឱ្យឈរក្នុងថ្នាក់ក្នុងរយៈពេលកំណត់ណាមួយ ដោយមិនអនុញ្ញាតឱ្យអង្គុយឡើយ។ សាលារៀនមិនបានផ្តល់កន្លែងសុវត្ថិភាពដល់អ្នកស្រឡាញ់ភេទដូចគ្នាឡើយ ហើយថែមទាំងអាចជាកន្លែងរួមចំណែកយ៉ាងសកម្មក្នុងការសម្លុតអ្នកស្រឡាញ់ភេទដូចគ្នាទៀតផង។ ដូចនេះហើយ អត្រាសរុបនៃការបោះបង់ការសិក្សារបស់អ្នកស្រឡាញ់ភេទដូចគ្នាមានកម្រិតខ្ពស់ជាងចំនួនសិស្សទូទៅ ដែលជាលក្ខខណ្ឌរារាំងអ្នកស្រឡាញ់ភេទដូចគ្នាក្នុងការទទួលបានឱកាសការងារល្អ។

- ត្រឹមតែ ៦ ភាគរយនៃអ្នកប្តូរយេនឌ័រជាស្ត្រីប៉ុណ្ណោះ ដែលបានទទួលការសិក្សាខ្ពស់ជាងអនុវិទ្យាល័យ
- ៣០ ភាគរយនៃអ្នកប្តូរយេនឌ័រជាស្ត្រី បានរាយការណ៍ថាគ្រួសារបានព្យាយាមបញ្ឈប់ពួកគេមិនឱ្យទៅសាលា ឬធ្វើការងារ និង
- ៨ ភាគរយនៃបុរសស្រឡាញ់បុរស បានរាយការណ៍ដូចគ្នាដែរ។

***ករណីសិក្សា៖***

អ្នកប្តូរយេនឌ័រជាបុរសអាយុ ១៩ឆ្នាំម្នាក់ ធ្លាប់ទទួលរងការសម្លុតខ្លាំងពីគ្រូបង្រៀនរបស់ខ្លួន។ គាត់បាននិយាយថា៖ *«ខ្ញុំពិតជាខកចិត្តយ៉ាងខ្លាំងជាមួយនឹងគ្រូបង្រៀននៅសាលារបស់ខ្ញុំ។ ជាទូទៅ សិស្សប្រុស និងស្រី មិនទទួលបានការដាក់វិន័យពីគ្រូឡើយ ប៉ុន្តែខ្ញុំបានទទួលការដាក់វិន័យបើទោះបីជាខ្ញុំបានធ្វើល្អ ឬក៏ខ្ញុំជាសិស្សពូកែក្នុងថ្នាក់ក៏ដោយ។ គ្រូរបស់ខ្ញុំនិយាយខ្លាំងៗ ឬស្តីបន្ទោសដាក់ខ្ញុំជារឿយៗ។ ខ្ញុំមិនមានអារម្មណ៍សប្បាយចិត្តទេ នៅពេលដែលខ្ញុំជាអ្នកប្តូរយេនឌ័រជាបុរសនៅក្នុងសាលារបស់ខ្ញុំ។ ខ្ញុំមិនសូវទទួលបានការរើសអើងពីមិត្តខ្ញុំច្រើននោះទេ ប៉ុន្តែគ្រូរបស់ខ្ញុំជាអ្នកសម្លុតគំរាមកំហែងខ្ញុំ»*។

## ៦.២.៧ ការរើសអើងនៅកន្លែងការងារ និងផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច

*ម.ស.ម.ក «សិទ្ធិមិនត្រូវបានរើសអើងដោយផ្អែកលើមូលដ្ឋាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទក្នុងវិស័យការងារនៅប្រទេសកម្ពុជា» (ឆ្នាំ២០១៩)*[57]

*ម.ស.ម.ក «ការរើសអើងលើអ្នកប្តូរភេទជាស្ត្រីនៅតាមទីប្រជុំជនក្នុងព្រះរាជាណាចក្រកម្ពុជា» (ឆ្នាំ២០១៦)*[58]

*កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) «អ្នកស្រឡាញ់ភេទដូចគ្នានៅអាស៊ី៖ របាយការណ៍ប្រចាំប្រទេសកម្ពុជា» (ឆ្នាំ២០១៤)*[59]

*UNAIDS, ក្រសួងសុខាភិបាល «ការស្ទង់មតិលើជីវសាស្ត្រ និងអាកប្បកិរិយាចម្រុះក្នុងចំណោមអ្នកប្តូរភេទជាស្ត្រីនៅប្រទេសកម្ពុជា» (ឆ្នាំ ២០១៦)*[60]

*របាយការណ៍ស្រាវជ្រាវរបស់អង្គការសហគមន៍ឥន្ទធនូកម្ពុជា និងក្រុមហ៊ុនកន្តា (Kantar TNS) ប្រចាំកម្ពុជា «គំនិត ឥរិយាបថ និងអាកប្បកិរិយាចំពោះអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា» (ឆ្នាំ២០១៥)*[61]

អ្នកស្រឡាញ់ភេទដូចគ្នានៅប្រទេសកម្ពុជាជាច្រើន មានអារម្មណ៍ពុំស្រណុកក្នុងចិត្តក្នុងការបើកចំហអំពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទរបស់ពួកគេនៅកន្លែងធ្វើការ ហើយមានការលើកឡើងអំពីការរើសអើង និងការបដិសេធផ្សេងៗ រួមមាន ភាពលំបាកក្នុងការទទួលបានការងារ ដោយសារតែនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទនេះផងដែរ។ ហេតុដូច្នេះហើយបានជាអ្នកស្រឡាញ់ភេទដូចគ្នា នៅតែជួបឧបសគ្គក្នុងការទទួលបានឱកាសការងារ និងនៅតែប្រឈមនឹងអត្រាគ្មានការងារធ្វើកម្រិតខ្ពស់។

---

[57] ម.ស.ម.ក. «សិទ្ធិមិនត្រូវបានរើសអើងដោយផ្អែកលើមូលដ្ឋាន និងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រនិងការបង្ហាញនូវទំនោរយេនឌ័រ និងលក្ខណៈភេទ ក្នុងវិស័យការងារនៅប្រទេសកម្ពុជា» (ខែធ្នូ ឆ្នាំ២០១៩) <https://cchrcambodia.org/index_old.php?url=project_page/project_page.php&p=report_detail.php&reid=139&id=3>.

[58] ម.ស.ម.ក «ការរើសអើងលើអ្នកប្តូរភេទជាស្ត្រីនៅតាមទីប្រជុំជនក្នុងព្រះរាជាណាចក្រកម្ពុជា» (ខែកញ្ញា ឆ្នាំ២០១៦) <https://cchrcambodia.org/index_old.php?url=project_page/project_page.php&p=report_detail.php&reid=115&id=3>;

[59] កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ «អ្នកស្រឡាញ់ភេទដូចគ្នាប្រចាំតំបន់អាស៊ី៖ របាយការណ៍ប្រចាំប្រទេសកម្ពុជា» (ឆ្នាំ២០១៤) <https://www.asia-pacific.undp.org/content/rbap/en/home/library/democratic_governance/hiv_aids/being-lgbt-in-asia--cambodia-country-report.html>.

[60] UNAIDS, ក្រសួងសុខាភិបាល «ការស្ទង់មតិលើជីវសាស្ត្រនិងអាកប្បកិរិយាចម្រុះក្នុងចំណោមអ្នកប្តូរភេទជាស្ត្រីនៅប្រទេសកម្ពុជា» (ខែមិថុនា ឆ្នាំ២០១៦) ទំព័រទី ២១ <https://www.nchads.org/Publication/SSS/IBBS%20Report_V08Low.pdf>.

[61] របាយការណ៍ស្រាវជ្រាវរបស់អង្គការសហគមន៍ឥន្ទធនូកម្ពុជានិងក្រុមហ៊ុនកន្តា (Kantar TNS) ប្រចាំកម្ពុជា «គំនិត ឥរិយាបថ និងអាកប្បកិរិយាចំពោះអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា» (ឆ្នាំ២០១៥) <https://www.rockcambodia.org/wp-content/uploads/2020/07/TNS-Research-Report-on-Opinions-Attitudes-and-Behavior-toward-the-LGBT-Population-in-Cambodia.pdf>.

*ឧបសគ្គដំបូងក្នុងការទទួលបានការងារៈ*



- ៩២ ភាគរយនៃអ្នកស្រឡាញ់ភេទដូចគ្នាជឿថាឱកាសការងារសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នាក្នុងប្រទេសកម្ពុជា គឺមិនមានភាពស្មើគ្នា បើធៀបទៅនឹងពលរដ្ឋដទៃទៀត
- ២១ ភាគរយនៃអ្នកស្រឡាញ់ភេទដូចគ្នាត្រូវបានគេបដិសេធពីការងារដោយសារតែនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទរបស់ពួកគេ
- ៦៥ ភាគរយនៃអ្នកស្រឡាញ់ភេទដូចគ្នាដែលត្រូវបានគេបដិសេធពីការងារដោយសារតែ និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទរបស់ពួកគេបានលើកឡើងថា ពួកគេត្រូវបានបដិសេធពីការងារជាច្រើនដង ហើយ
- ២៥ ភាគរយនៃអ្នកស្រឡាញ់ភេទដូចគ្នាបានរាយការណ៍ថា ពួកគេបានលាក់បាំងនូវនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទរបស់ខ្លួនក្នុងពេលកំពុងធ្វើកិច្ចសម្ភាសការងារ។

តាមការអង្កេត ឧបសគ្គទាំងនេះកើតទៅលើអ្នកប្តូរយេនឌ័រ និងអ្នកដែលមានយេនឌ័រស្របជាមួយភេទពីកំណើត ហើយក្នុងកម្រិតកាន់តែខ្ពស់ជាងនោះ គឺអ្នកប្តូរយេនឌ័រៈ

- ៤២,១ ភាគរយនៃអ្នកប្តូរយេនឌ័រជាស្ត្រីបានរាយការណ៍អំពីការជួបប្រទះនូវបញ្ហាជាច្រើនក្នុងការរកការងារធ្វើ
- ៣៤,៣៥ ភាគរយនៃអ្នកប្តូរយេនឌ័រជាស្ត្រីបានរាយការណ៍ពីការបដិសេធពីការងារជាច្រើនដងដោយសារតែនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេឌ័រ និងលក្ខណៈភេទរបស់ពួកគាត់ និង
- ២៦,៦២ ភាគរយនៃអ្នកប្តូរយេនឌ័រជាស្ត្រីបាននិយាយថា ពួកគេត្រូវបានបណ្តេញចេញពីការងារដោយសារតែនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទរបស់ខ្លួន។

*ការបៀតបៀននៅកន្លែងធ្វើការៈ* អ្នកស្រឡាញ់ភេទដូចគ្នាប្រឈមនឹងទម្រង់នៃការបៀតបៀនធ្ងន់ធ្ងរផ្សេងៗរឿយៗនៅកន្លែងធ្វើការ។




*ប្រភេទនៃការបៀតបៀនដែលអ្នកស្រឡាញ់ភេទដូចគ្នា ធ្លាប់ជួបប្រទះនៅកន្លែងធ្វើការដោយសារតែនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ ៖*

- ៣៦ ភាគរយនៃអ្នកស្រឡាញ់ភេទដូចគ្នាបានលើកឡើងអំពីការជួបប្រទះនឹងការបៀតបៀន ឬការសម្លុតនៅកន្លែងធ្វើការដែលពួកគេជឿថាបង្កមកពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទរបស់ពួកគេ
- ការរំលោភបំពានដោយការប្រើប្រាស់នូវពាក្យសម្ដី ដូចជាការហៅឈ្មោះ និងការលេងសើចក៏ជាទម្រង់នៃការបៀតបៀនខ្លាំងផងដែរហើយ
- ៦២ ភាគរយនៃអ្នកស្រឡាញ់ភេទដូចគ្នា ធ្លាប់បានជួបប្រទះការបៀតបៀននៅកន្លែងធ្វើការរបស់ពួកគេដោយមិនបានរាយការណ៍ ឬដាក់ពាក្យបណ្ដឹងអំពីករណីដែលបានកើតឡើងទាំងអស់នោះទេ ពីព្រោះពួកគេមានអារម្មណ៍មិនមានសុវត្ថិភាពក្នុងការរាយការណ៍អំពីការបៀតបៀនដែលបានកើតឡើងនោះ។

***ផលប៉ះពាល់សុខភាព សង្គម និងសេដ្ឋកិច្ចកើតចេញពីការរើសអើងនៅកន្លែងការងារ៖*** ការរើសអើងនិងការបៀតបៀននៅកន្លែងការងារមានផលប៉ះពាល់យ៉ាងខ្លាំងលើអ្នកស្រឡាញ់ភេទដូចគ្នា។ នេះអាចប៉ះពាល់យ៉ាងខ្លាំងទៅលើសុខភាពផ្លូវចិត្តផងដែរ ដោយ ៥៤ ភាគរយនៃអ្នកស្រឡាញ់ភេទដូចគ្នាបានលើកឡើងថា ធ្លាប់មានបញ្ហាផ្នែកសតិអារម្មណ៍ក្នុងនោះរួមទាំងការបាក់ទឹកចិត្តផងដែរ។ ឧបសគ្គក្នុងការទទួលបានការងារសម្រាប់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា អាចបង្កឱ្យមានផលប៉ះពាល់នៅក្នុងសង្គម និងអាចធ្វើឱ្យមានការបដិសេធពីសង្គមផងដែរ ដោយ ៩៤ ភាគរយនៃអ្នកស្រឡាញ់ភេទដូចគ្នាបានលើកឡើងថា ការមានការងារ គឺពិតជាសំខាន់ខ្លាំងណាស់ដើម្បីឱ្យក្រុមគ្រួសារ និងសហគមន៍ទទួលស្គាល់ពួកគេ។ ផលប៉ះពាល់សេដ្ឋកិច្ចដោយសារឥទ្ធិពលនៃការរើសអើងនៅកន្លែងធ្វើការ ដោយសារនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ គឺជាការបារម្ភខ្លាំងមួយសម្រាប់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា។ ការរើសអើងផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ អាចរារាំងពួកគេក្នុងការទទួលបានការងារ និងនាំឱ្យអ្នកស្រឡាញ់ភេទដូចគ្នាបាត់បង់ការងារ ហើយថែមទាំងបាត់បង់ប្រភពចំណូលរបស់ពួកគេទៀតផង។ អ្នកស្រឡាញ់ភេទដូចគ្នាត្រូវបង្ខំចិត្តលាឈប់ពីការងារនៅពេលដែលពួកគេជួបប្រទះនឹងការបៀតបៀននៅកន្លែងធ្វើការ។ម្យ៉ាងវិញទៀត ការបាត់បង់ចំណូល និងការកើនឡើងនូវភាពក្រីក្រអាចរារាំងដល់ទស្សនៈវិស័យការងារនាពេលអនាគត ហើយការបាត់បង់ការងារនេះបណ្ដាលឱ្យមានផលប៉ះពាល់ដល់សេដ្ឋកិច្ចរយៈពេលវែង។ ការងារ ៦ ប្រភេទសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នាគឺ (១) កសិករ (២) ការគ្រប់គ្រងធុរកិច្ច /មុខរបរផ្ទាល់ខ្លួន (៣) និស្សិត (៤) កម្មករកាត់ដេរ (៥) វិស័យសេវាកម្ម និង (៦) កម្មករ

កសិកម្ម។ ទាំងនេះ គឺជាវិស័យការងារទន់ខ្សោយ ដែលរារាំងអ្នកស្រឡាញ់ភេទដូចគ្នាមិនឱ្យគេចផុតពីរង្វង់នៃភាពក្រីក្រ។



### *ករណីសិក្សា៖ ផល ជាអ្នកប្តូរយេនឌ័រជាបុរស*

ផល គឺជាអ្នកប្តូរយេនឌ័រជាបុរស និងធ្វើការក្នុងឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់។ គាត់បានបង្ហាញអត្តសញ្ញាណរបស់ខ្លួននៅកន្លែងធ្វើការ ប៉ុន្តែមិនបង្ហាញអត្តសញ្ញាណរបស់ខ្លួនឱ្យប្រធានក្រុមហ៊ុនបានដឹងទេ ដោយសារគាត់ភ័យខ្លាចថា គាត់នឹងត្រូវជួបការរើសអើង ឬក៏អាចនឹងត្រូវបណ្តេញចេញពីការងារ ប្រសិនបើមេខ្លួនបានដឹង។ បញ្ហានេះបានបង្កឱ្យប៉ះពាល់ទៅដល់សុខភាពផ្លូវចិត្ត ដោយគាត់មានអារម្មណ៍មិនសូវស្រួលក្នុងចិត្តក្នុងការទៅធ្វើការជារៀងរាល់ថ្ងៃ ហើយត្រូវលាក់បាំងពីមេរបស់ខ្លួន។ កាលពីមុន ផល ធ្លាប់ធ្វើការនៅរោងចក្រកាត់ដេរនៅក្នុងខេត្តនៅជិតស្រុកកំណើត ក្នុងពេលនោះគាត់ទុកសក់វែង ដោយគាត់ខ្លាចថា បើមិនទុកសក់វែងទេ គាត់នឹងពុំត្រូវបានគេទទួលយក។ ការណ៍ដែលទុកសក់វែងដើម្បីទទួលបានការងារបានធ្វើឱ្យគាត់មានអារម្មណ៍មិនស្រួលក្នុងចិត្តយ៉ាងខ្លាំង។ **ផល** ក៏ធ្លាប់ត្រូវគេបដិសេធពេលដាក់ពាក្យសុំការងារធ្វើក្នុងរោងចក្រកាត់ដេរផងដែរ ដោយសារតែនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទរបស់គាត់។

## ៦.២.៨ សិទ្ធិសុខភាព

*UNAIDS, «ប្រទេសកម្ពុជា» (ឆ្នាំ២០២០)*[62]

*កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ «អ្នកស្រឡាញ់ភេទដូចគ្នានៅអាស៊ី៖ របាយការណ៍ប្រចាំប្រទេសកម្ពុជា» (ឆ្នាំ២០១៤)*[63]

*របាយការណ៍ស្រាវជ្រាវរបស់អង្គការសហគមន៍ឥន្ទធនូកម្ពុជា និងក្រុមហ៊ុនកន្តា (Kantar TNS) ប្រចាំកម្ពុជា «គំនិត ឥរិយាបថ និងអាកប្បកិរិយាចំពោះប្រជាពលរដ្ឋអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា» (ឆ្នាំ២០១៥)*[64]

អ្នកស្រឡាញ់ភេទដូចគ្នា ពុំទទួលបានការថែទាំ និងសេវាកម្មវេជ្ជសាស្ត្រគ្រប់គ្រាន់ត្រឹមត្រូវនៅក្នុងប្រទេសកម្ពុជា។ បុគ្គលិកផ្នែកថែទាំសុខភាពនៅប្រទេសកម្ពុជាពុំទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវទៅលើបញ្ហាសុខភាពជាក់លាក់សម្រាប់ឆ្លើយតបទៅនឹងតម្រូវការរបស់បុគ្គលស្រឡាញ់ភេទដូចគ្នានោះទេ ក្នុងនោះដូចជាមិនមានលទ្ធភាពក្នុងការផ្តល់សេវាមើលថែទាំឱ្យបានគ្រប់គ្រាន់ដល់ពួកគេជាដើម។ លើសពីនេះទៀត អ្នកស្រឡាញ់ភេទដូចគ្នាមិនបានទៅជួបគ្រូពេទ្យទៀងទាត់ឡើយ ព្រោះតែពួកគេបារម្ភពីការរើសអើង និងការទទួលព្យាបាលមិនស្មើភាពគ្នារបស់គ្រូពេទ្យ។ កង្វះខាតនៃជម្រើសក្នុងការផ្តល់ការថែទាំសុខភាពឱ្យបានល្អដល់អ្នកស្រឡាញ់ភេទដូចគ្នានេះ បានធ្វើឱ្យពួកគេប្រឈមការឈឺចាប់នឹងជំងឺដែលអាចព្យាបាលបាន។

***មេរោគអេដស៍៖*** អ្នកស្រឡាញ់ភេទដូចគ្នា ជាពិសេសបុរសរួមភេទជាមួយបុរសដូចគ្នា និងអ្នកប្តូរយេនឌ័រជាស្ត្រី គឺជាក្រុមដែលងាយប្រឈមនឹងការឆ្លងមេរោគអេដស៍នេះបំផុត ដោយអត្រានៃការផ្ទុកមេរោគអេដស៍ខ្ពស់ផងដែរ។ លើសពីនេះទៀត ក្រុមយុវវ័យដែលជាអ្នកស្រឡាញ់ភេទដូចគ្នាអាយុក្រោម ១៨ ឆ្នាំ តែងតែបដិសេធក្នុងការធ្វើតេស្តរកមេរោគអេដស៍ ទោះបីជាច្បាប់ និងគោលនយោបាយមួយចំនួនបានចែងរួចហើយក៏ដោយ ដែលធ្វើឱ្យអ្នកប៉ះពាល់ដល់សុខភាពរបស់បុគ្គលក្នុងរយៈពេលយូរ។

***សុខភាពផ្លូវចិត្ត៖*** អ្នកស្រឡាញ់ភេទដូចគ្នាប្រឈមហានិភ័យផ្នែកបញ្ហាសុខភាពផ្លូវចិត្តកម្រិតខ្ពស់ ដោយ ២២ភាគរយនៃអ្នកបានចូលរួមក្នុងការស្ទង់មតិបានលើកឡើងថា ពួកគេមានអារម្មណ៍ខ្មាសអៀនចំពោះខ្លួនឯង។ នេះរាប់បញ្ចូលទាំងសេវាកម្មផ្នែកសុខភាពផ្លូវចិត្តសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នាក្នុងប្រទេសកម្ពុជាមានកម្រិតផងដែរ។

***ការថែទាំសុខភាពសម្រាប់អ្នកប្តូរយេនឌ័រ៖*** អ្នកជំនាញផ្នែកវេជ្ជសាស្ត្រតិចតួចប៉ុណ្ណោះដែលមានការយល់ដឹង ឬធ្លាប់មានបទពិសោធផ្តល់ការថែទាំសុខភាពបានត្រឹមត្រូវដល់អ្នកប្តូរយេនឌ័រ ហើយការវះកាត់ប្តូរភេទទាំងស្រុង គឺមិនមាននៅក្នុងប្រទេសកម្ពុជាទេ។ នៅពេលអ្នកប្តូរភេទទទួលការវះកាត់ច្រើនដង ជារឿយៗពួកគេ

---

[62] UNAIDS, «ប្រទេសកម្ពុជា» (ឆ្នាំ២០២០) <https://www.unaids.org/en/regionscountries/countries/cambodia>.

[63] *កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ «អ្នកស្រឡាញ់ភេទដូចគ្នានៅអាស៊ី៖ របាយការណ៍ប្រចាំប្រទេសកម្ពុជា»(ឆ្នាំ២០១៤)*'ទំព័រ.៤៩ <https://www.asia-pacific.undp.org/content/rbap/en/home/library/democratic_governance/hiv_aids/being-lgbt-in-asia--cambodia-country-report.html>.

[64] របាយការណ៍ស្រាវជ្រាវរបស់អង្គការសហគមន៍ឥន្ទធនូកម្ពុជានិងក្រុមហ៊ុនកន្តា (Kantar TNS) ប្រចាំកម្ពុជា «គំនិត ឥរិយាបថ និងអាកប្បកិរិយាចំពោះអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា» (ឆ្នាំ២០១៥) <https://www.rockcambodia.org/wp-content/uploads/2020/07/TNS-Research-Report-on-Opinions-Attitudes-and-Behavior-toward-the-LGBT-Population-in-Cambodia.pdf>.

រងការលំបាកលើបញ្ហាសុខភាព។ លើសពីនេះទៀត អ្នកប្តូរភេទជាច្រើនបានជ្រើសរើសមិនទៅទទួលការថែទាំរបស់គ្រូពេទ្យឡើយ ព្រោះតែពួកគេបារម្ភខ្លាចគេគិតថាខ្លួនជាអ្នករកស៊ីផ្លូវភេទ ឬការទទួលទោសព្រហ្មទណ្ឌ ឬការប្រព្រឹត្តអំពើផ្សេងៗ[65]។

- ៧ ភាគរយនៃអ្នកប្តូរយេនឌ័របានជួបប្រទះនឹងការរើសអើងពីអ្នកជំនាញផ្នែកថែទាំសុខភាព
- អ្នកប្តូរយេនឌ័រជាបុរសដែលមិនបានឆ្លងកាត់ការវះកាត់ប្តូរភេទ ស្ត្រីដែលស្រឡាញ់ទាំងពីរភេទ ស្ត្រីស្រឡាញ់ស្ត្រី គឺភាគច្រើនអាចនឹងក្លាយទៅជាជនរងគ្រោះនៃអំពើហិង្សាផ្នែកផ្លូវភេទ ឬការបង្ខំឱ្យរៀបការជាដើម។ ពួកគេព្រមទាំងខ្វះលទ្ធភាពក្នុងការទទួលបានព័ត៌មានត្រឹមត្រូវ និងគ្រប់គ្រាន់អំពីបញ្ហាសុខភាពបន្តពូជ ក្នុងនោះមានដូចជាការរំលូតកូនដោយសុវត្ថិភាពជាដើម
- អ្នកប្តូរយេនឌ័រនៅក្នុងប្រទេសកម្ពុជា ប្រឈមនឹងឧបសគ្គក្នុងការទទួលបានសេវាកម្មថែទាំសុខភាព រួមទាំងការព្យាបាលដោយអ័រម៉ូនជាដើម ហើយជាធម្មតាពួកគេបានធ្វើដំណើរទៅប្រទេសដទៃទៀតដើម្បីធ្វើការវះកាត់ ឬធ្វើការព្យាបាលដោយខ្លួនឯង ហើយ
- អ្នកប្តូរយេនឌ័រមួយចំនួនបានទទួលរងការឈឺចាប់យ៉ាងខ្លាំង ហើយពេលខ្លះអាចរហូតដល់បាត់បង់ជីវិតទៀតផងដោយសារការប្រើប្រាស់ឱសថព្យាបាលដោយមិនមានការត្រួតពិនិត្យត្រឹមត្រូវ និងមិនយល់ច្បាស់លាស់ពីរបៀបព្យាបាលដោយខ្លួនឯងក្នុងអន្តរកាលនៃការប្តូរភេទ។




[65] Eduardo S. Molano, "សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាតស៊ូដើម្បីអត្តសញ្ញាណ" (*Nikkei Asia*, ២៦ មីនា ២០១៧) <https://asia.nikkei.com/Location/Southeast-Asia/Myanmar-Cambodia-Laos/Cambodia-s-LGBT-community-struggles-for-identity>.

## ៦.៣ ការបន្ទុះនឹងបទដ្ឋានរើសអើង និងផ្នត់គំនិតរើសអើង

ការរើសអើងលើសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា បានកើតឡើងខ្លាំងនៅក្នុង៖

(១) គ្រួសារ

(២) សហគមន៍

(៣) កន្លែងការងារ និង

(៤) ក្នុងវិស័យសុខាភិបាល។

ដោយបានជ្រាបពីពេលវេលា ទីកន្លែង និងបញ្ហាដែលអ្នកស្រឡាញ់ភេទដូចគ្នាប្រឈមនឹងឥរិយាបថរើសអើង ដូច្នេះហើយ រដ្ឋាភិបាល និងភាគីពាក់ព័ន្ធនានាអាចជួយចូលរួមដោះស្រាយបញ្ហានានាដែលបង្កឱ្យមានការរើសអើងដ៏រាលដាលជាលក្ខណៈប្រព័ន្ធនេះតាមរយៈការចូលរួមក្នុងសកម្មភាពមួយចំនួនដូចខាងក្រោម៖

១. អប់រំសហគមន៍តាមរយៈសាលារៀន ឬរៀបចំឱ្យមានសិក្ខាសាលាដើម្បីលុបបំបាត់ការយល់ឃើញបែបអគតិណាមួយទៅលើអ្នកស្រឡាញ់ភេទដូចគ្នា

២. បង្កើតសហគមន៍មួយប្រកបដោយបរិយាកាសសុវត្ថិភាពសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នាដើម្បីពួកគេអាចទទួលបានភាពកក់ក្ដៅ ទទួលយកនូវអ្វីដែលខ្លួនកំពុងមាន ជាពិសេសនោះនៅពេលពួកគេត្រូវបានគ្រួសារពុំទទួលស្គាល់ជាដើម

៣. បញ្ឈប់ការប្រើពាក្យសម្ដីលែបខាយ ឡកឡឺយ និងការឌឺដងផ្សេងៗទៅលើអ្នកស្រឡាញ់ភេទដូចគ្នាក្នុងផ្លូវអវិជ្ជមាននៅលើបណ្ដាញសង្គម និង

៤. គោរពសិទ្ធិក្នុងការបញ្ចេញគំនិត/ការបង្ហាញនានារបស់អ្នកស្រឡាញ់ភេទដូចគ្នា។

**ករណីសិក្សា៖ អ្នកស្រី ឡុន ដែលទទួលបានការទទួលស្គាល់ពីគ្រួសារ**

អ្នកស្រី ឡុន ជាសកម្មជនការពារសិទ្ធិដីធ្លី មានកូនម្នាក់ជាអ្នកប្លូរយេនឌ័រជាស្ត្រី។ អ្នកស្រី ឡុន និងប្ដី របស់អ្នកស្រី បានបង្ហាញពីអារម្មណ៍មិនពេញចិត្តជាខ្លាំង និងបានខឹងសម្បាទៅលើអត្តសញ្ញាណយេនឌ័ររបស់កូន។ អ្នកស្រី ឡុន បានចូលរួមកម្មវិធីជំរំសកម្មជនដែលបានរៀបចំឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ក្នុងអំឡុងពេលនោះក៏មានបញ្ចាំងភាពយន្តឯកសារដែលសម្ដែងអំពីជីវិតរបស់អ្នកស្រឡាញ់ភេទដូចគ្នាក្នុងប្រទេសកម្ពុជាផងដែរ។ ក្នុងអំឡុងពេលកម្មវិធីនោះ អ្នកស្រីប្រាប់អំពីរឿងជីវិតផ្ទាល់ខ្លួនទៅកាន់ក្រុមថា អ្នកស្រីមានកូនជាអ្នកប្លូរយេនឌ័រជាស្ត្រីម្នាក់។ បន្ទាប់ពីបានទស្សនាការសម្ដែង និងការទទួលបានមតិវិជ្ជមានជាច្រើនពីអ្នកចូលរួមដទៃទៀត អ្នកស្រីបានបង្ហាញថា អ្នកស្រីមានអារម្មណ៍មិនតានតឹងដូចមុនលើកូនរបស់អ្នកស្រី ហើយបានប្ដេជ្ញាចិត្តធ្វើជាអ្នកគាំទ្រដល់ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា។

# មេរៀនទី ៧៖ ទ្រឹស្តីភាពប្រសព្វ

## ៧.១ តើអត្តសញ្ញាណជាអ្វី?

បុគ្គលម្នាក់ៗមានអត្តសញ្ញាណជាច្រើនក្នុងការកំណត់ និងសម្គាល់នូវចរិតលក្ខណៈរបស់ខ្លួន។ អត្តសញ្ញាណទាំងនោះរួមមានកត្តាសង្គម នយោបាយ និងសេដ្ឋកិច្ច។ ឧទាហរណ៍៖ ពូជសាសន៍ ជនជាតិ សាសនា សញ្ជាតិ ស្ថានភាពសេដ្ឋកិច្ចសង្គម/ឋានៈ សមត្ថភាព និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ។




*ប្រភព៖ ទីភ្នាក់ងារអភិវឌ្ឍន៍ស្ត្រីអន្តរជាតិ“ តើភាពប្រសព្វនៃភាពជាស្ត្រីនិយមមានន័យយ៉ាងដូចម្តេច?” (អាយ.ដាបបាយូ.ឌី.អេ(IWDA) ថ្ងៃទី១១ ឧសភា ២០១៨)*

អត្តសញ្ញាណមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធអាស្រ័យទៅនឹងអំណាចដែលត្រូវបានរៀបចំ និងដំណើរការនៅក្នុងសង្គមនោះ។ នៅក្នុងសង្គមនីមួយៗ អត្តសញ្ញាណខ្លះត្រូវបានមើលឃើញថាមានលក្ខណៈលើសពី“ធម្មតា” ឬជាអត្តសញ្ញាណដែលសង្គមចង់បាន។ អត្តសញ្ញាណទាំងនោះត្រូវបានសង្គម ផ្តល់នូវអំណាច និងបុព្វសិទ្ធិពិសេស។ ខណៈពេលដែលអត្តសញ្ញាណមួយចំនួនផ្សេងទៀត ឃើញថាសង្គមពុំសូវចង់បាន ឬទទួលបានការផ្តល់តម្លៃ និងអំណាចតិចតួច។ អត្តសញ្ញាណអាចផ្តល់បុព្វសិទ្ធិ ឬបង្កើនបញ្ហាប្រឈមដែលបុគ្គលម្នាក់ៗនៅក្នុងសង្គមអាចនឹងជួបប្រទះ។

### ពាក្យគន្លឹះសំខាន់ៗសម្រាប់មេរៀនទី ៧

- **អត្តសញ្ញាណ៖** ចរិតលក្ខណៈ ឬបុគ្គលិកលក្ខណៈរបស់បុគ្គល
- **ឋានៈ៖** មនុស្សមួយក្រុមនៅក្នុងសង្គមដែលមានសេដ្ឋកិច្ច និងតួនាទីស្រដៀងគ្នា។
- **អ្នកស្រឡាញ់ភេទដូចគ្នា៖** ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ អន្តរភេទ និងអ្នកដែលមិនកំណត់ ឬមិនទាន់កំណត់អត្តសញ្ញាណយេនឌ័ររបស់ខ្លួន។
- **ពិការភាព៖** ស្ថានភាពរាងកាយ ឬផ្លូវចិត្តដែលកំហិតលើសកម្មភាពប្រចាំថ្ងៃ ឬសតិស្មារតីរបស់បុគ្គលណាម្នាក់។
- **កាយសម្បទារឹងមាំ៖** មិនមានពិការភាព។
- **អត្តសញ្ញាណទន់ខ្សោយ៖** អត្តសញ្ញាណដែលធ្លាប់រងការរើសអើង និងការផាត់ចេញដោយសារតែឥទ្ធិពលមិនស្មើគ្នាផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌នៅក្នុងសង្គមជាក់ស្តែង។
- **ភាពប្រសព្វ៖** រង្វាស់ទិដ្ឋភាពផ្សេងៗប្រើដើម្បីយល់ដឹងអំពីរចនាសម្ពន្ធអំណាចក្នុងសង្គមដែលមានឥទ្ធិពល និងទំនាក់ទំនងជាមួយអត្តសញ្ញាណផ្សេងៗរបស់បុគ្គលម្នាក់ៗនិងបទពិសោធនៃការរើសអើង ឬបុព្វសិទ្ធិពិសេសរបស់បុគ្គលទាំងនោះ។
- **យេនឌ័រដែលស្របនឹងភេទកំណើត៖** ជនដែលមានអត្តសញ្ញាណយេនឌ័រ និងការបង្ហាញទំនោរយេនឌ័រស្របតាមភេទពីកំណើតរបស់ខ្លួន។

តើអត្តសញ្ញាណរបស់អ្នកមានអ្វីខ្លះ? ចូរពិចារណាលើចំណុចណាមួយដូចខាងក្រោមដែលជាអត្តសញ្ញាណរបស់អ្នក៖

- សញ្ជាតិខ្មែរ
- ជនជាតិដើមភាគតិច
- ពុទ្ធសាសនិក
- ឥស្លាម
- ក្មេង
- ចាស់

- បុរស
- ស្ត្រី
- អ្នកមានពិការភាព
- ជនក្រីក្រ
- អ្នកមាន
- អ្នកស្រឡាញ់ភេទដូចគ្នា

អ្នកស្រឡាញ់ភេទដូចគ្នាគ្រាន់តែជាទិដ្ឋភាពមួយនៃអត្តសញ្ញាណរបស់បុគ្គលម្នាក់ៗប៉ុណ្ណោះ។



## ៧.២ តើអ្វីទៅជាទ្រឹស្តីភាពប្រសព្វ?

អត្តសញ្ញាណខ្លះអាចធ្វើឱ្យបុគ្គលម្នាក់ប្រឈមនូវការរើសអើង រួមមានដូចជា ពូជសាសន៍ សាសនា ពិការភាព និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទជាដើម។ យើងអាចកំណត់ចំណុចទាំងនេះថា "អត្តសញ្ញាណទន់ខ្សោយ"។ សង្គមនីមួយៗ មានការកំណត់ភាពទន់ខ្សោយចំពោះអត្តសញ្ញាណណាមួយ ខណៈពេលដែលសង្គមមួយផ្សេងទៀត អត្តសញ្ញាណដដែលនោះ ទទួលបានសំឡេងគាំទ្រច្រើននិងត្រូវបានផ្តល់បុព្វសិទ្ធិទៀតផង។ លក្ខណៈប្រសព្វ គឺជាការពិនិត្យមើលទៅលើបទពិសោធជាក់លាក់ និងលក្ខណៈពិសេសណាមួយរបស់បុគ្គលណាម្នាក់ដែលស្ថិតនៅចំណុចប្រសព្វនៃអត្តសញ្ញាណទន់ខ្សោយ ក៏ដូចជាការទទួលស្គាល់បទពិសោធនៅចំណុចប្រសព្វនៃអត្តសញ្ញាណទន់ខ្សោយ និងអត្តសញ្ញាណដែលទទួលបានបុព្វសិទ្ធិ។

នេះជាចំណុចប្រសព្វនៃ
សាសនា និងជនមានពិការភាព




អត្តសញ្ញាណផ្សេងៗគ្នារបស់បុគ្គល និងក្រុមនៃសង្គម នយោបាយ និងសេដ្ឋកិច្ច រួមបញ្ចូលគ្នា បង្កើតបាននូវបទពិសោធនៃការរើសអើង និងវិសមភាព។

នេះជាចំណុចប្រសព្វនៃ
ជាតិសាសន៍ និង
លក្ខណៈភេទ

## ៧.៣ សារៈសំខាន់នៃទ្រឹស្តីភាពប្រសព្វសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា

និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទជាប្រភេទនៃអត្តសញ្ញាណរបស់អ្នកស្រឡាញ់ភេទដូចគ្នា ហើយពួកគេម្នាក់ៗក៏មានអត្តសញ្ញាណជាច្រើនផ្សេងទៀតបន្ថែមលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទរបស់ខ្លួនផងដែរ។ ដូច្នេះ អ្នកស្រឡាញ់ភេទដូចគ្នាមិនគួរត្រូវបានកំណត់ដោយផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទរបស់ពួកគេនោះទេ។

**មិនមែនគ្រប់អ្នកស្រឡាញ់ភេទដូចគ្នាទាំងអស់សុទ្ធតែមានបទពិសោធដូចគ្នានោះទេ**

បទពិសោធរបស់អ្នកស្រឡាញ់ភេទដូចគ្នាតែម្នាក់ មិនអាចតាងឱ្យបទពិសោធរបស់អ្នកស្រឡាញ់ភេទដូចគ្នាទាំងអស់នោះទេ។ អ្នកគប្បីពិនិត្យរាល់ចំណុចប្រសព្វនៃអត្តសញ្ញាណទាំងអស់ដើម្បីស្វែងយល់ និងដោះស្រាយការរើសអើងដែលអ្នកស្រឡាញ់ភេទដូចគ្នាបានជួបប្រទះ។ សមាជិកនៃសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាមួយចំនួនអាចមានអត្តសញ្ញាណទន់ខ្សោយជាច្រើនក្រៅពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទរបស់ពួកគេ ក៏ដូចជាបុព្វសិទ្ធិនៃអត្តសញ្ញាណ។ ដូច្នេះយើងមិនអាចនិយាយថារាល់បទពិសោធរបស់បុគ្គលដែលបង្ហាញនូវនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទទាំងអស់ដូចគ្នានោះទេ។

ប្រៀបធៀបពីភាពខុសគ្នាទៅលើចំណុចប្រសព្វនៃអត្តសញ្ញាណរបស់ **គន្ធា** និង**ស្រីពៅ៖**

គន្ធា



- យេនឌ័រពីកំណើតជាស្ត្រី
- ស្ត្រីស្រឡាញ់ស្ត្រី
- ជនមានពិការភាព

ស្រីពៅ



- អ្នកប្តូរយេនឌ័រជាស្ត្រី
- កាយសម្បទារឹងមាំ
- ជនជាតិភាគតិច

ប្រភព៖ *OpenClipart*

### ហេតុអ្វីទ្រឹស្តីភាពប្រសព្វមានសារៈសំខាន់ចំពោះបញ្ហារបស់អ្នកស្រឡាញ់ភេទដូចគ្នា?

- តាមប្រវត្តិសាស្ត្រ បញ្ហារបស់ស្ត្រីស្រឡាញ់ស្ត្រី និងស្ត្រីស្រឡាញ់ទាំងពីរភេទ មិនត្រូវបានយកចិត្តទុកដាក់ និងទទួលបានការផ្តល់តម្លៃដូចគ្នាទៅនឹងបញ្ហាបុរសស្រឡាញ់បុរសនោះទេ។
- បញ្ហារបស់ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស និងស្ត្រីដែលស្រឡាញ់ទាំងពីរភេទ តែងតែមានអាទិភាពជាងបញ្ហារបស់អ្នកប្តូរយេនឌ័រ។
- ចលនាទទួលស្គាល់នូវបញ្ហារបស់អ្នកប្តូរយេនឌ័រជាស្ត្រី នាំមុខលើបញ្ហារបស់អ្នកប្តូរយេនឌ័រជាបុរស។
- អ្នកស្រឡាញ់ភេទដូចគ្នាដែលមានវ័យក្មេង ឬក្រីក្រតែងតែជួបប្រទះនូវបញ្ហាផ្សេងៗច្រើនជាងអ្នកស្រឡាញ់ភេទដូចគ្នាដែលមានស្ថានភាពសេដ្ឋកិច្ចល្អប្រសើរ។
- អ្នកស្រឡាញ់ភេទដូចគ្នាដែលជាជនជាតិភាគតិច ក៏នឹងជួបប្រទះនូវបញ្ហាផ្សេងៗជាច្រើនផងដែរ។

### តើអ្នកអាចធ្វើអ្វីខ្លះដើម្បីបញ្ចូលទស្សនវិស័យភាពប្រសព្វនៅក្នុងការងារផ្ទាល់ខ្លួនរបស់អ្នក?

ការដាក់បញ្ចូលបុគ្គលដែលមានអត្តសញ្ញាណច្រើនតាមរយៈការងាររបស់អ្នកទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន គឺថ្លឹងថ្លែងតាមទស្សនៈប្រសព្វ ត្រូវពិចារណាឱ្យបានច្បាស់លាស់ជានិច្ចក្នុងការដាក់បញ្ចូល

អត្តសញ្ញាណទន់ខ្សោយផ្សេងៗ រួមទាំងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទនៅពេលអនុវត្តការងាររបស់អ្នក។ សូមសួរខ្លួនអ្នកថា តើមនុស្សដែលមានអត្តសញ្ញាណខុសគ្នាអាចរងផលប៉ះពាល់ខុសគ្នាពីការងាររបស់អ្នកបែបណាខ្លះ? ចូលរួមជាមួយសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាដើម្បីស្ដាប់ពីបទពិសោធ និងទស្សនវិស័យរបស់ពួកគាត់លើប្រធានបទដែលទាក់ទងនឹងការងាររបស់អ្នក។ ចំណុចសំខាន់បំផុតនោះ ត្រូវបញ្ចូលបុគ្គលមកពីក្រុមដែលសិទ្ធិរបស់ពួកគេកំពុងត្រូវបានដោះស្រាយក្នុងការងាររបស់អ្នក។

**សូមអានបន្ថែមទៀតដើម្បីជួយអ្នកក្នុងការអនុវត្តទស្សនវិស័យនៃភាពប្រសព្វ**

- អង្គការយុវជនអ្នកស្រឡាញ់ភេទដូចគ្នា និងនិស្សិតអន្តរជាតិ The International LGBTQ Youth and Student Organisation, 'ប្រអប់ឧបករណ៍ភាពប្រសព្វ' (ឆ្នាំ២០១៤) <https://www.iglyo.com/wp-content/uploads/2015/09/Inter-Toolkit.pdf>.
- ករណីសម្រាប់ទ្រឹស្តីភាពប្រសព្វ៖ ការគាំទ្រយុវជនដែលស្រឡាញ់ភេទដូចគ្នាកំឡុងពេលនៃការរីករាលដាលជំងឺកូវីដ១៩ (ឆ្នាំ២០២០) <https://www.unicefusa.org/stories/case-intersectionality-supporting-lgbtq-youth-amidst-covid-19/37418>
- ការវិភាគទ្រឹស្តីភាពប្រសព្វនៃពិការភាព និងភាពចម្រុះនៃនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទនៅក្នុងបរិបទមនុស្សធម៌ និងការអភិវឌ្ឍ (ឆ្នាំ២០២០) https://www.did4all.com.au/Resources/Out%20of%20the%20Margins_Full%20Report_June%202020_FINAL.pdf

# មេរៀនទី ៨៖ អំពើហិង្សាទាក់ទងនឹងផ្លូវភេទ និងយេនឌ័រ

## ៨.១ តើអំពើហិង្សាទាក់ទងនឹងផ្លូវភេទនិងយេនឌ័រជាអ្វី?

**ពាក្យគន្លឹះសំខាន់ៗសម្រាប់មេរៀនទី ៨**

- **យេនឌ័រ៖** គំនិតមួយក្នុងចំណោមគំនិតនានាដែលកំណត់ដោយសង្គមថាជាបុរស និងស្ត្រីដែលសំដៅលើតួនាទីផ្សេងៗអាកប្បកិរិយា សកម្មភាព និង លក្ខណៈសម្បត្តិនានាដែលសង្គមមួយចាត់ទុកថាស័ក្តិសមសម្រាប់ភាពជាបុរស និងស្ត្រី។
- **អំពើហិង្សាទាក់ទងនឹងផ្លូវភេទ និងយេនឌ័រ៖** ជាអំពើហិង្សាដែលកើតឡើងដោយផ្ទាល់ទៅលើបុគ្គលណាម្នាក់ព្រោះតែយេនឌ័ររបស់ខ្លួន។
- **វិសមភាពយេនឌ័រ៖** ការផ្តល់គុណតម្លៃខុសគ្នា ចំពោះមនុស្សដោយផ្អែកលើយេនឌ័រ។
- **ការផ្តល់តម្លៃលើភាពជាបុរសហួសហេតុ៖** ប្រពៃណីទំនៀមទម្លាប់ វប្បធម៌ និងបទដ្ឋានសង្គមដែលលើកតម្កើងបុរសហួសហេតុដែលអាចបង្កគ្រោះថ្នាក់ដល់បុរស ស្ត្រី និងសង្គមទាំងមូល។
- **អំពើហិង្សាក្នុងគ្រួសារ៖** ជាហិង្សាលើរូបរាងកាយកើតឡើងរវាងដៃគូដែលមានទំនាក់ទំនងជិតស្និទ្ធ។
- **យេនឌ័រស្របនឹងភេទកំណើត៖** ជាបុគ្គលដែលមានអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រស្របតាមភេទពីកំណើត។

អំពើហិង្សាទាក់ទងនឹងផ្លូវភេទ និងយេនឌ័រ គឺជាការប្រព្រឹត្តទង្វើណាមួយដែលបង្កគ្រោះថ្នាក់ផ្ទុយនឹងឆន្ទៈរបស់បុគ្គលណាម្នាក់ដោយសារតែភេទ អត្តសញ្ញាណយេនឌ័រ ឬ ការបង្ហាញទំនោរយេនឌ័ររបស់ពួកគេ។ អំពើហិង្សាទាក់ទងនឹងផ្លូវភេទនិងយេនឌ័រក៏សំដៅទៅលើអំពើហិង្សាទាក់ទងនឹងយេនឌ័រផងដែររួមមាន អំពើហិង្សាផ្លូវកាយ អំពើហិង្សាផ្លូវចិត្ត អំពើហិង្សាតាមពាក្យសម្តី និងអំពើហិង្សាផ្លូវសេដ្ឋកិច្ច។ គេនិយមប្រើពាក្យ «អំពើហិង្សាទាក់ទងនឹងផ្លូវភេទនិងយេនឌ័រ» ជាងពាក្យ «អំពើហិង្សាទាក់ទងនឹងយេនឌ័រ» ដែលពាក្យនេះបញ្ជាក់យ៉ាងច្បាស់ពីការរាប់បញ្ចូលនូវអំពើហិង្សាលើផ្លូវភេទដែលក្នុងនោះរួមមានទាំងការបៀតបៀនលើផ្លូវភេទ និងការរំលោភសេពសន្ថវៈផងដែរ។

ទោះបីជាស្ត្រី បុរសនិងបុគ្គលដែលមិនកំណត់អត្តសញ្ញាណធ្លាប់មានបទពិសោធទទួលរងអំពើហិង្សាទាក់ទងនឹងផ្លូវភេទនិងយេនឌ័រក្តី តែភាគច្រើនជនរងគ្រោះនៃអំពើហិង្សានេះ គឺជាស្ត្រី និងក្មេងស្រី។ នៅក្នុងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា អំពើហិង្សាទាក់ទងនឹងផ្លូវភេទនិងយេនឌ័រ មានឥទ្ធិពលខ្លាំងបំផុតលើស្ត្រីស្រឡាញ់ស្ត្រី អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រជាស្ត្រី និងក្មេងស្រី។

នៅក្នុងប្រទេសកម្ពុជា ការសិក្សាស្រាវជ្រាវបានបង្ហាញថាស្ត្រីស្រឡាញ់ស្ត្រី អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រជាស្ត្រីប្រឈមនឹងអំពើហិង្សាទាក់ទងនឹងផ្លូវភេទ និងយេនឌ័រ ក្នុងអត្រាដ៏ខ្ពស់បើធៀបទៅនឹងស្ត្រីដែលជាអ្នកស្រឡាញ់ភេទផ្ទុយគ្នា[៦៦] ទោះយ៉ាងនេះក្តីបញ្ហារបស់អ្នកស្រឡាញ់ភេទដូចគ្នាតែងត្រូវបានមើលរំលងនៅពេលដែលនិយាយសំដៅដល់អំពើហិង្សាទាក់ទងនឹងផ្លូវភេទ និងយេនឌ័រ។

[៦៦] ក្រសួងកិច្ចការនារី-ផែនការយុទ្ធសាស្ត្រយេនឌ័រកម្ពុជា-នារីរតនៈ ទី៤ (ខែធ្នូ ឆ្នាំ២០១៤) ទំព័រ ១១។

## ៨.២ មូលហេតុបង្កឱ្យមានអំពើហិង្សាទាក់ទងនឹងផ្លូវភេទ និងយេនឌ័រ

- មូលហេតុចម្បងបង្កឱ្យមានអំពើហិង្សាទាក់ទងនឹងផ្លូវភេទ និងយេនឌ័រនោះគឺវិសមភាពយេនឌ័រ។ អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងផ្លូវភេទ បានចាក់ឫសគល់មកពីអតុល្យភាពនៃអំណាចរវាងបុរស និងស្ត្រី ដែលជាកត្តាធ្វើឱ្យយេនឌ័រមួយមានឥទ្ធិពលជាងយេនឌ័រមួយផ្សេងទៀត។
- អំពើហិង្សាទាក់ទងនឹងផ្លូវភេទ និងយេនឌ័រកើតឡើងកាន់តែខ្លាំង ដោយសារតែការនិយមក្នុងការផ្តល់តម្លៃលើបុរសហួសហេតុតាមការយល់ឃើញបែបអវិជ្ជមានប្រកបដោយគ្រោះថ្នាក់មកលើបុរសដោយយោងទៅលើបទដ្ឋានវប្បធម៌ដែលមានលក្ខណៈលម្អៀងទៅរកបុរស។ ភាពគ្រោះថ្នាក់នៃបិតាធិបតេយ្យរួមមាន ការគាបសង្កត់ផ្លូវអារម្មណ៍ ការប្រើឥទ្ធិពល និងការប្រើអំពើហិង្សាដើម្បីប្រើអំណាចគាបសង្កត់ និងការត្រួតត្រា។
- ជំនឿខាងប្រពៃណី និងវប្បធម៌ ព្រមទាំងបទដ្ឋានសង្គមដែលតឹងរ៉ឹង និងភាពលម្អៀងយេនឌ័រនៅក្នុងស្ថាប័នផ្សេងៗ បង្កឱ្យមានវិសមភាពនេះ ដែលវិសមភាពទាំងនេះតែងត្រូវយកមកជាសម្អាងពីមូលហេតុស្របច្បាប់នៃអំពើហិង្សាទាក់ទងនឹងផ្លូវភេទ និងយេនឌ័រ។ ឧទាហរណ៍ មានទំនៀមទម្លាប់ និងវប្បធម៌ជាច្រើនបានបង្ខំឱ្យស្ត្រីនៅក្រោមបង្គាប់ឪពុក បងប្រុស និងប្តីរបស់ពួកគេជាដើម។

នៅក្នុងបរិបទប្រទេសកម្ពុជា របនាសម្ព័ន្ធបិតាធិបតេយ្យកើតមានជាទូទៅធម្មតាដែលនេះមានន័យថា ស្ត្រីត្រូវបានមើលឃើញថានៅតែមានតម្លៃទាបជាងបុរស ឬភាពរណបរបស់ស្ត្រីដែលបុរសប្រើប្រាស់អំណាចលុបលើ។ បទដ្ឋានសង្គមចាក់ឫសគល់យ៉ាងជ្រៅនេះបាននាំឱ្យស្ត្រីប្រឈមនឹងភាពលម្អៀងនៃយេនឌ័រក្នុងជីវភាពប្រចាំថ្ងៃ។ ទំនៀមទម្លាប់ប្រពៃណីជាពិសេសនៅក្នុងច្បាប់ស្រី ដែលជាបណ្តុំបទកាព្យអប់រំក្រមសីលធម៌សម្រាប់ស្ត្រីខ្មែរ ដែលលើកកម្ពស់គោលការណ៍គោរពប្រណិប័តន៍របស់ស្ត្រីឱ្យស្ថិតនៅក្រោមអំណាចរបស់បុរស ហើយគោលការណ៍នេះទៀតសោតត្រូវយកមកបង្រៀននៅតាមសាលារៀនរហូតដល់ឆ្នាំ២០០៧ ដែលនៅតែដើរតួនាទីយ៉ាងសំខាន់ក្នុងការរក្សាទុកបទដ្ឋានយេនឌ័រដ៏គ្រោះថ្នាក់នេះ[67]។ អង្គការសហប្រជាជាតិបានធ្វើការសិក្សាស្រាវជ្រាវថ្នាក់ជាតិមួយនៅក្នុងឆ្នាំ២០០៩ បានបង្ហាញថា៩២ ភាគរយនៃស្ត្រីកម្ពុជានិង៨២ ភាគរយនៃបុរសកម្ពុជាបានជឿជាក់ថាតួនាទីចម្បងរបស់ស្ត្រីគឺការមើលថែកូននិងផ្ទះសម្បែង[68]។ ស្រដៀងគ្នានេះដែរ ការបន្សល់ទុកនៃកេរដំណែលនៃភាពមិនស្មើគ្នារវាងភាពខ្លាំងរបស់បុរស និងភាពទន់ខ្សោយរបស់ស្ត្រីបានបញ្ជាក់យ៉ាងច្បាស់លាស់ក្នុងការ

---

[67] CEDAW/C/KHM/CO/6, "បូកសរុបលទ្ធផលការសង្កេតលើរបាយការណ៍តាមដំណាក់កាល ទី ៦ របស់កម្ពុជា" (ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៩) <https://tbinternet.ohchr.org/_layouts/15/treatybodyexternal/Download.aspx?symbolno=CEDAW/C/KHM/CO/6&Lang=En>.

[68] កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិនៅកម្ពុជា (UNDP) "ភាពជាដៃគូដើម្បីសមភាពយេនឌ័រដំណាក់កាលទី៤" (ខែកុម្ភៈ ឆ្នាំ ២០១៩) <https://www.kh.undp.org/content/cambodia/en/home/projects/partnership-for-gender-equity-phase-iii.html>.

សិក្សាស្រាវជ្រាវនៅក្នុងឆ្នាំ២០១៣ ដែលបានបង្ហាញថា៩៦ ភាគរយ នៃបុរសកម្ពុជា និង៩៩ ភាគរយនៃស្ត្រីកម្ពុជាបានគិតថាបុរសភាព គឺត្រូវរឹងមាំ និងស្វាហាប់[69] ។

## ៨.៣ ប្រភេទនៃអំពើហិង្សាទាក់ទងនឹងផ្លូវភេទ និងយេនឌ័រ

អំពើហិង្សាទាក់ទងនឹងផ្លូវភេទ និងយេនឌ័ររាប់បញ្ចូលនូវប្រភេទនៃអំពើហិង្សាជាច្រើនប្រភេទដូចជា៖ ហិង្សាផ្លូវកាយ ផ្លូវភេទ តាមពាក្យសម្តី ផ្លូវចិត្ត និងហិង្សាផ្លូវសេដ្ឋកិច្ចជាដើម។ ជាធម្មតាចំពោះទង្វើមួយមានអំពើហិង្សាច្រើនប្រភេទ ឬអំពើហិង្សាទាំងអស់កើតឡើងរួមផ្សំមកជាមួយ។

**ចំណុចស្នូលនៃអំពើហិង្សាទាក់ទងនឹងផ្លូវភេទ និងយេនឌ័រ**




*ប្រភព៖ ទីភ្នាក់ងារផ្តល់ជំនួយសង្គ្រោះ និងការងាររបស់អង្គការសហប្រជាជាតិសម្រាប់ជនភៀសខ្លួនប៉ាឡេស្ទីននៅជិតភាគខាងកើត“ បទពិសោធក្នុងកម្មវិធីអំពើហិង្សាទាក់ទងនឹងយេនឌ័រ”(ឆ្នាំ ២០១៥)*

ជាទូទៅអំពើហិង្សាទាក់ទងនឹងផ្លូវភេទ និងយេនឌ័រ រួមមានប្រភេទនៃអំពើហិង្សាខាងក្រោម ប៉ុន្តែនេះជាការលើកឡើងសង្ខេបប៉ុណ្ណោះ ហើយបទពិសោធរបស់បុគ្គលម្នាក់ៗពាក់ព័ន្ធនឹងអំពើហិង្សាទាក់ទងនឹងផ្លូវភេទ និងយេនឌ័រមានដោយឡែកពីគ្នាដូចជា៖

- **ការរំលោភសេពសន្ថវៈ** គឺជាការរួមភេទដោយគ្មានការព្រមព្រៀង ការបង្ខិតបង្ខំលើរូបរាងកាយ ឬការប្រើប្រាស់មធ្យោបាយបង្ខិតបង្ខំផ្សេងៗទៀត។
- **ការបៀតបៀនផ្លូវភេទ** គឺជាទម្រង់ផ្សេងៗនៃការបៀតបៀនផ្លូវភេទដោយគ្មានការព្រមព្រៀង។
- **អំពើហិង្សាលើរូបរាងកាយ** គឺជាទង្វើប៉ុនប៉ងបង្ក ឬជាទង្វើនាំឱ្យមានការឈឺចាប់ ការមិនសប្បាយចិត្ត និង/ឬរបួសលើរូបរាងកាយ។ ក្នុងទំនាក់ទំនងដៃគូស្និទ្ធស្នាល អំពើហិង្សាលើរូបរាងកាយគឺសំដៅទៅលើអំពើហិង្សាក្នុងគ្រួសារ។
- **អាពាហ៍ពិពាហ៍ដោយបង្ខំ** គឺជាពិធីរៀបអាពាហ៍ពិពាហ៍មួយ ឬច្រើនដែលរៀបចំឡើងផ្ទុយនឹងឆន្ទៈរបស់សាមីខ្លួន។ នេះរួមបញ្ចូលទាំងការរៀបអាពាហ៍ពិពាហ៍របស់អនីតិជនក្នុងករណីដែលអាយុរបស់អនីតិជនមិនទាន់អាចផ្តល់ការយល់ព្រមលើអាពាហ៍ពិពាហ៍នោះបាន។

[69] UNDP និង UN Women, “ហេតុអ្វីបានជាបុរសមួយចំនួនប្រើអំពើហិង្សាលើស្ត្រី ហើយតើយើងអាចជៀសវាងដោយរបៀបណា? ការរកឃើញបរិមាណពីការសិក្សាពហុប្រទេសរបស់អង្គការសហប្រជាជាតិស្តីពីបុរស និងអំពើហិង្សានៅអាស៊ី និងប៉ាស៊ីហ្វិក (ឆ្នាំ២០១៣) <https://asiapacific.unwomen.org/-/media/field%20office%20eseasia/docs/publications/2013/09/why-do-some%20men.pdf?la=en&vs=5140>.

- **ការបដិសេធលើធនធាន ឱកាស ឬសេវាកម្ម** គឺជាការរារាំងសិទ្ធិក្នុងការទទួលបានធនធានសេដ្ឋកិច្ច ឬ ឱកាសការងារ/ឱកាសរកប្រាក់ចំណូល ការអប់រំ សុខភាព ឬសេវាកម្មសង្គមផ្សេងៗទៀត។
- **ការរំលោភបំពានផ្លូវចិត្ត និងផ្លូវអារម្មណ៍** គឺជាការបង្ខិតបង្ខំលើផ្លូវចិត្ត ឬការបង្កការឈឺចាប់ ឬរបួសស្នាម ផ្លូវអារម្មណ៍។ នេះរាប់បញ្ចូលទាំងការគំរាមកំហែងក្នុងទម្រង់នៃអំពើហិង្សាផ្សេងៗទៀតរួមមាន ការបំភិតបំភ័យ បង្កភាពអាម៉ាស់ ការមាក់ងាយតាមពាក្យសម្តី និងការមិនយកចិត្តទុកដាក់។
- **ការជួញដូរមនុស្ស** គឺជាការប្រើប្រាស់កម្លាំង ការឆបោក ការបង្ខិតបង្ខំដើម្បីទទួលបានកម្លាំងពលកម្ម ឬ គោលបំណងដើម្បីកេងប្រវ័ញ្ចផ្លូវភេទរួមទាំងការធ្វើពេស្យាចារដោយបង្ខំ។



## ៨.៤ ជនល្មើសនៃអំពើហិង្សាទាក់ទងនឹងផ្លូវភេទ និងយេនឌ័រ

ជនល្មើសនៃអំពើហិង្សាទាក់ទងនឹងផ្លូវភេទ និងយេនឌ័រស្ថិតនៅក្នុងក្រុមបុគ្គលបីប្រភេទសំខាន់ៗគឺៈ

១. ដៃគូស្និទ្ធស្នាល

២. សមាជិកគ្រួសារដទៃទៀត

៣. ជនល្មើសក្រៅគ្រួសារ

*ជាទូទៅដៃគូស្និទ្ធស្នាល គឺជាជនល្មើសនៃអំពើហិង្សាទាក់ទងនឹងផ្លូវភេទ និងយេនឌ័រ ពីព្រោះអំពើហិង្សាប្រព្រឹត្តនៅផ្ទះជាកន្លែងឯកជន។ លទ្ធផលអំពើហិង្សាក្នុងគ្រួសារ គឺជាទម្រង់ទូទៅនៃអំពើហិង្សាទាក់ទងនឹងផ្លូវភេទ និងយេនឌ័រ។*

អំពើហិង្សាក្នុងគ្រួសារ អំពើហិង្សាទាក់ទងនឹងផ្លូវភេទ និងយេនឌ័រ ហើយភាពចន្លោះប្រហោងនៃច្បាប់ទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារ គឺនាំឱ្យមានបញ្ហាជាច្រើនសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា។ អ្នកស្រឡាញ់

ភេទដូចគ្នាត្រូវបានផាត់ចេញពីកិច្ចគាំពារនៃ *ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចគាំពារជនរង-គ្រោះ* ដោយច្បាប់នេះចែងថាអំពើហិង្សាក្នុងគ្រួសារ គឺសំដៅលើអំពើហិង្សាដែលកើតមាន និងអាចកើតមានទៅលើ «*ប្តី ឬប្រពន្ធ*» «*កូនក្នុងបន្ទុក*» «ជនទាំងឡាយរស់នៅក្រោមដំបូលផ្ទះ និងក្នុងបន្ទុកគ្រួសារ»[70]។ ច្បាប់នេះហាក់ដូចជារឹតត្បិតវិសាលភាពនៃដែនអនុវត្តរបស់ខ្លួនដែលមានន័យថាវិធានការនេះមិនមានអនុភាពអនុវត្តទៅលើដៃគូភេទដូចគ្នា ឬដៃគូអ្នកស្រឡាញ់ភេទផ្ទុយគ្នាដែលភាគីម្ខាងជាអ្នកប្តូរយេនឌ័រ។ ការទុកបុគ្គលអ្នកស្រឡាញ់ភេទដូចគ្នាដោយគ្មានការការពារស្របច្បាប់ប្រឆាំងនឹងអំពើហិង្សាទាក់ទងនឹងផ្លូវភេទ និងយេនឌ័រជាមូលហេតុមួយដែលធ្វើឱ្យពួកគេជួបប្រទះនឹងអំពើហិង្សានេះ។




ការស្ទង់មតិឆ្នាំ២០១៥ បានបង្ហាញថាយ៉ាងហោចណាស់មានស្ត្រីម្នាក់ក្នុងចំណោមស្ត្រី ៥ នាក់នៅកម្ពុជា (២០,៩%) បានជួបប្រទះអំពើហិង្សាលើរាងកាយ និង/ឬអំពើហិង្សាផ្លូវភេទដោយដៃគូស្និទ្ធស្នាលដែលជាអត្រាខ្ពស់បំផុតទី ២ នៅអាស៊ីអាគ្នេយ៍ បន្ទាប់ពីប្រទេសវៀតណាម[71] ។ ការស្ទង់មតិដដែលក៏បានបង្ហាញថាស្ត្រី ២០ ភាគរយបានរាយការណ៍ថាបទពិសោធរួមភេទលើកដំបូងរបស់ពួកគេត្រូវបានគេបង្ខំ ឬប្រើប្រាស់កម្លាំង[72]។

## ៨.៥ អំពើហិង្សាទាក់ទងនឹងផ្លូវភេទ និងយេនឌ័រសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា

អ្នកស្រឡាញ់ភេទដូចគ្នា គឺជាបុគ្គលងាយនឹងទទួលរងគ្រោះនៃអំពើហិង្សាទាក់ទងនឹងផ្លូវភេទ និងយេនឌ័រ ដោយសារតែផ្នត់គំនិតយល់ដឹងអំពីតួនាទីយេនឌ័រមានលក្ខណៈបុរាណ។ ដោយមើលឃើញថាការកើនឡើងនៃអ្នកស្រឡាញ់ភេទដូចគ្នា បានជំរុញឱ្យមានការទទួលស្គាល់កាន់តែប្រសើរឡើងនៅក្នុងសង្គមមួយចំនួនពាក់ព័ន្ធនឹងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ។ លើសពីនេះទៀត ការបង្កើតច្បាប់ដើម្បីស្វែងរកការលើកស្ទួយ និងការពារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នាកំពុងត្រូវបានគេតាក់តែងជាបណ្តើរៗ នៅជុំវិញពិភពលោក ប៉ុន្តែកម្ពុជាមិនទាន់អនុវត្តតាមបាននៅឡើយទេ។

កត្តាដែលធ្វើឱ្យអត្រានៃអំពើហិង្សាទាក់ទងនឹងផ្លូវភេទ និងយេនឌ័រកាន់តែធ្ងន់ធ្ងរ ដែលអ្នកស្រឡាញ់ភេទដូចគ្នាអាចជួបប្រទះរួមមាន៖

- ក្លាយជាស្ត្រី (យេនឌ័រស្របនឹងភេទកំណើត ឬអ្នកប្តូរយេនឌ័រជាស្ត្រី)

[70] ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះ (ឆ្នាំ២០០៥)។

[71] អង្គការសុខភាពពិភពលោក WHO និង UNWOMEN នៅកម្ពុជា “ការស្ទង់មតិជាតិស្តីពីសុខភាពនិងបទពិសោធន៍ជីវិតរបស់ស្ត្រី” (ឆ្នាំ ២០១៥) <https://asiapacific.unwomen.org/en/digital-library/publications/2015/11/national-survey-on-women-s-health-and-life-experiences-in-cambodia#view>.

[72] Ibid.

- ទាក់ទងនឹងជាតិសាសន៍ក្រុមភាគតិច
- មកពីសហគមន៍ជនជាតិដើមភាគតិច
- កង្វះស្ថិរភាពសេដ្ឋកិច្ច

សមាជិកខ្លះនៃសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា មានអត្តសញ្ញាណទន់ខ្សោយច្រើនប្រភេទលើសពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទរបស់ពួកគេនោះទៅទៀត ហើយជាកត្តាមួយដែលធ្វើឱ្យអត្រានៃអំពើហិង្សាទាក់ទងនឹងផ្លូវភេទ និងយេនឌ័រកើនឡើងកាន់តែខ្ពស់។ បទពិសោធអ្នកស្រឡាញ់ភេទដូចគ្នាតែម្នាក់មិនអាចតាងឱ្យបទពិសោធរបស់អ្នកស្រឡាញ់ភេទដូចគ្នាទាំងអស់នោះបានទេ។

អំពើហិង្សាក្នុងគ្រួសារ និងបទពិសោធអំពើហិង្សាលើផ្លូវភេទដែលអ្នកស្រឡាញ់ភេទដូចគ្នាបានជួបប្រទះមានអាត្រាខ្ពស់ជាងប្រជាពលរដ្ឋទូទៅ។ ការសិក្សាស្រាវជ្រាវក្នុងឆ្នាំ២០១៣ បានរកឃើញថា ៥៧ភាគរយនៃបុរសស្រឡាញ់បុរស និងស្ត្រីស្រឡាញ់ស្ត្រី និង ៦៦ភាគរយនៃអ្នកប្តូរយេនឌ័រជាស្ត្រីនៅក្នុងប្រទេសកម្ពុជាធ្លាប់ជួបប្រទះនឹងអំពើហិង្សាក្នុងគ្រួសារដែលប្រព្រឹត្តដោយសមាជិកក្នុងក្រុមគ្រួសារ និងដៃគូស្និទ្ធស្នាល[73]។ តាមរយៈការប្រៀបធៀបលើការស្ទង់មតិមួយដែលធ្វើឡើងក្នុងឆ្នាំ២០១៤ បង្ហាញថាមានតែ ១៦ ភាគរយនៃស្ត្រីដែលមានយេនឌ័រស្របនឹងភេទកំណើតប៉ុណ្ណោះដែលបានរាយការណ៍ថាធ្លាប់ជួបប្រទះនឹងអំពើហិង្សាលើរូបរាងកាយពីដៃគូស្និទ្ធស្នាលក្នុងមួយជីវិតរបស់ពួកគេ[74] ។




[73] Voice, ‘Exploring Cambodian Voices’ ( ឆ្នាំ២០១៨ ) <https://voice.global/assets/2018/08/Exploring-Cambodian-Voices.pdf> p. 12; Vicente S. Salas and Srun Sorn, "ការស្វែងយល់ពីការមិនរាប់បញ្ចូលក្នុងសង្គមរបស់ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកប្តូរយេនឌ័រ នៅក្នុងគ្រួសារនិងសហគមន៍ក្នុងតំបន់មួយចំនួននៃប្រទេសកម្ពុជា និងវិធីនៃការតស៊ូរបស់ពួកគេ" ( ឆ្នាំ២០១៣ )

[74] នាយកដ្ឋានការពារផ្នែកច្បាប់ ក្រសួងកិច្ចការនារី "តារាងទិន្នន័យកម្ពុជាស្តីពីអំពើហឹង្សាដៃគូជិតស្និទ្ធ" , <https://cambodia.unfpa.org/sites/default/files/pub-pdf/Leflet_IPV_English.pdf>. មិនមានចំនួនប្រជាសាស្ត្រនៅលើ SOGIESC នៃអ្នកឆ្លើយសំណួរស្ទង់មតិទេ ប៉ុន្តែត្រូវបានគេសន្មតថាទាំងអស់ឬភាគច្រើនគឺជាអ្នកស្រឡាញ់ភេទផ្ទុយគ្នា។

ទោះយ៉ាងណា អត្រានៃអំពើហិង្សាទាក់ទងនឹងផ្លូវភេទ និងយេនឌ័រលើអ្នកស្រឡាញ់ភេទដូចគ្នានៅតែបន្តកើតមានឡើង។ នៅក្នុងការសិក្សាឆ្នាំ២០១៩ អ្នកឆ្លើយតប ៨១ភាគរយជាស្ត្រីស្រឡាញ់ស្ត្រី អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរយេនឌ័របានរាយការណ៍ថាបានទទួលរងនូវអំពើហិង្សា/ការរំលោភបំពានផ្លូវចិត្តពីគ្រួសាររបស់ពួកគេ។ ១០ ភាគរយបានរាយការណ៍ថាបានទទួលរងអំពើហិង្សាលើផ្លូវភេទដែលភាគច្រើនកើតឡើងដោយសារតែការបង្ខំឱ្យរៀបការ ហើយ ១១ ភាគរយបានទទួលរងនូវការរំលោភបំពានលើរាងកាយដោយសមាជិកគ្រួសារ[75]។

នៅឆ្នាំ២០២១ ផែនការយុទ្ធសាស្រ្តរយៈពេល ៥ ឆ្នាំ (២០១៩-២០២៣) របស់ក្រសួងកិច្ចការនារីនៃប្រទេសកម្ពុជាបានកត់សម្គាល់ថាស្ត្រីស្រឡាញ់ស្ត្រី អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរយេនឌ័រជាស្ត្រី ស្ថិតក្នុងចំណោមសមាជិកដែលងាយរងគ្រោះបំផុតនៅក្នុងសង្គម ហើយជាក្រុមដែលប្រឈមនឹងហានិភ័យខ្ពស់នៃការរើសអើង ការមាក់ងាយ និងអំពើហិង្សាទាក់ទងនឹងផ្លូវភេទ និងយេនឌ័រ[76]។



ក្នុងចំណោមសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា អ្នកប្តូរយេនឌ័រគឺជាបុគ្គលដែលងាយរងគ្រោះបំផុតចំពោះការរើសអើង និងអំពើហិង្សា ដោយសារតែនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទរបស់ខ្លួន ហើយជាទូទៅត្រូវបានគេមើលឃើញជាញឹកញាប់បំផុត។

ការស្ទង់មតិនេះធ្វើឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាក្នុងឆ្នាំ២០១៥ ដែលបង្ហាញថាក្នុងចំណោមអ្នកប្តូរយេនឌ័រជាស្ត្រីជាជនជាតិខ្មែរ ១៣៥ នាក់គឺ៖

- ៩២ ភាគរយធ្លាប់ទទួលរងការប្រមាថមាក់ងាយតាមពាក្យសម្តីនៅទីសាធារណៈ
- ៤៣ ភាគរយធ្លាប់ទទួលរងអំពើហិង្សាលើរូបរាងកាយនៅទីសាធារណៈ
- ៣១ ភាគរយធ្លាប់ទទួលរងការបៀតបៀនផ្លូវភេទនៅទីសាធារណៈ
- ២៥ ភាគរយធ្លាប់ត្រូវគេរំលោភសេពសន្ថវៈ[77]

---

[75] អង្គការសហគមន៍ឥន្ទធនូកម្ពុជា “ខ្ញុំរៀបការជាមួយនឹងបុរស ដើម្បីបំពេញចិត្តឪពុកម្តាយរបស់ខ្ញុំ: របាយការណ៍អំពើហិង្សាគ្រួសារប្រឆាំងនឹងស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ និងស្ត្រីប្តូរយេនឌ័រជាបុរស នៅក្នុងប្រទេសកម្ពុជា (ខែមិថុនា ឆ្នាំ២០១៩) <https://www.rockcambodia.org/wp-content/uploads/2020/07/Family-Violence-LBT_ENG-19.06.2019.pdf>.

[76] ក្រសួងកិច្ចការនារី-នារីរតនៈទី៥៖ ផែនការយុទ្ធសាស្រ្ត ៥ ឆ្នាំសម្រាប់ការពង្រឹងការបញ្ជ្រាបយេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រីឆ្នាំ២០១៩-២០២៣ <https://www.mowa.gov.kh/wp-content/uploads/2021/02/Neary-Rattanak-V-final-Eng.pdf>

[77] ម.ស.ម.ក «ការរើសអើងលើអ្នកប្តូរយេនឌ័រជាស្ត្រីនៅតាមទីប្រជុំជនក្នុងព្រះរាជាណាចក្រកម្ពុជា» (ឆ្នាំ២០១៦) <https://cchrcambodia.org/admin/media/report/report/english/2016_09_21_SOGI_Report_Eng.pdf>.




ក្នុងករណីទាំងអស់នេះ បុគ្គលដែលធ្លាប់ជួបប្រទះនឹងអំពើហិង្សាទាក់ទងនឹងផ្លូវភេទ និងយេនឌ័រជឿថាពីព្រោះតែអត្តសញ្ញាណនៃការប្តូរយេនឌ័ររបស់ខ្លួន។

ករណីសិក្សាស្រាវជ្រាវមួយទៀតធ្វើឡើងដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជំងឺសើស្បែក និងកាមរោគនៅក្នុងឆ្នាំ២០១៦ ដែលផ្តោតលើអ្នកប្តូរយេនឌ័រជាស្ត្រីនៅកម្ពុជាបានរកឃើញតួលេខប្រហាក់ប្រហែលគ្នា។ អ្នកឆ្លើយសំណួរបានបង្ហាញថាការរើសអើងទូទៅលំដាប់ទីពីរដែលពួកគេបានជួបប្រទះ គឺការពិបាកក្នុងការស្វែងរកការងារធ្វើ ការរំលោភបំពានលើផ្លូវភេទ ឬការបៀតបៀនលើផ្លូវភេទដែលស្មើនឹង ៣៩ ភាគរយបានរាយការណ៍ថាពួកគាត់ធ្លាប់ទទួលបានបទពិសោធនេះ។ ២៤ ភាគរយនៃអ្នកឆ្លើយតបបាននិយាយថាពួកគេត្រូវបានគេរំលោភបំពានលើរាងកាយ ឬវាយដំជាដើម[78]។

បន្ថែមលើអំពើហិង្សាដោយផ្ទាល់ដែលក្រុមអ្នកស្រឡាញ់ភេទដូចគ្នាអាចនឹងជួបប្រទះនៅក្នុងប្រទេសកម្ពុជា ពួកគេក៏ប្រឈមនឹងទម្រង់នៃការរើសអើងជារចនាសម្ព័ន្ធសង្គម ឬអំពើហិង្សាដោយប្រយោលផងដែរ។

- **ការរើសអើងផ្នែកច្បាប់៖** អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាប្រឈមទៅនឹងទម្រង់ខុសៗគ្នានៃការរើសអើងដោយច្បាប់រួមមាន ពុំទាន់មានកិច្ចការពារស្របច្បាប់ប្រឆាំងនឹងការរើសអើង និងអំពើហិង្សា អវត្តមាននៃការទទួលស្គាល់អត្តសញ្ញាណយេនឌ័រតាមផ្លូវច្បាប់ដែលកំណត់ដោយខ្លួនឯង អវត្តមាននៃសមភាពអាពាហ៍ពិពាហ៍នៅក្នុងច្បាប់កម្ពុជា និងការបដិសេធទាំងស្រុងលើសិទ្ធិសុំកូនពេញលេញ។
- **ការរើសអើងក្នុងការទទួលបានសេវាកម្មផ្នែកថែទាំសុខភាព ចំណេះដឹង និងការងារ ៖** នៅក្នុងរបាយការណ៍មួយដែលចេញដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានបង្ហាញថា ២១ភាគរយនៃអ្នកស្រឡាញ់ភេទដូចគ្នាដែលបានសម្ភាសន៍បានរាយការណ៍ថាពួកគេត្រូវបានបដិសេធក្នុងការធ្វើការងារ

[78] មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជំងឺសើស្បែក និងកាមរោគ "ការស្ទាបស្ទង់កត្តាជីវសាស្ត្រ និងអាកប្បកិរិយាចម្រុះក្នុងចំណោមស្ត្រីប្តូរយេនឌ័រនៅកម្ពុជាឆ្នាំ២០១៦" (ខែមិថុនា ឆ្នាំ២០១៦) <https://www.nchads.org/Publication/SSS/IBBS%20Report_V08Low.pdf>, ទំព័រទី២១។

ដោយសារតែនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ /ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទរបស់ពួកគេ[79]។

- **ការមាក់ងាយ៖** អ្នកស្រឡាញ់ភេទដូចគ្នាជាជនជាតិខ្មែរនៅតែបន្តត្រូវបានរើសអើង និងត្រូវបានផាត់ចេញពីវិស័យផ្សេងៗនៅក្នុងជីវភាពសង្គម។
- **កង្វះការទទួលស្គាល់ពីសង្គម និងការគាំទ្រពីគ្រួសារ៖** អ្នកស្រឡាញ់ភេទដូចគ្នាជាច្រើននាក់បានរាយការណ៍ថាពួកគាត់មិនទទួលស្គាល់ពីសំណាក់គ្រួសារ ឬការចាប់បង្ខំឱ្យរៀបការ ឬ«យកទៅព្យាបាល» ដោយសារតែពួកគេជាអ្នកស្រឡាញ់ភេទដូចគ្នា ព្រមទាំងមានការរំលោភបំពានផ្លូវចិត្តនិងផ្លូវកាយ[80]។

ជាតុទាំងអស់នេះរួមចំណែកផាត់អ្នកស្រឡាញ់ភេទដូចគ្នាជាច្រើននាក់ចេញពីសង្គម ជាលទ្ធផលអត្រាខ្ពស់ដែលពួកគេអាចប្រឈមនឹងអំពើហិង្សាទាក់ទងនឹងផ្លូវភេទ និងយេនឌ័រក្នុងវដ្តនេះ។




[79] ម.ស.ម.ក. «សិទ្ធិមិនត្រូវបានរើសអើងដោយផ្អែកលើមូលដ្ឋាន និងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រនិងការបង្ហាញនូវទំនោរយេនឌ័រ និងលក្ខណៈភេទ ក្នុងវិស័យការងារនៅប្រទេសកម្ពុជា» (ខែធ្នូ ឆ្នាំ២០១៩) <https://cchrcambodia.org/admin/media/report/report/english/CCHR_SOGIE%20Employment%20Research%20Report_ENG_Final_24Jan2020.pdf>, ទំព័រទី២៦។

[80] ការិយាល័យ OHCHR "ព្យាបាលបញ្ហា មិនមែនប្រជាជនទេ" - របាយការណ៍សំខាន់ៗស្តីពីសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នានៅកម្ពុជាបង្ហាញពីការពិត បទពិសោធន៍ និងអនុសាសន៍នានា» (ខែសីហាឆ្នាំ ២០១៤) <https://www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=14925&LangID=E>.

# មេរៀនទី ៩៖ ការក្លាយជាអ្នកគាំទ្រ និងជំហានឆ្ពោះទៅរកសមភាព

## ៩.១ តើនរណាជាអ្នកគាំទ្រ ហើយនរណាអាចក្លាយជាអ្នកគាំទ្រ?

**អ្នកគាំទ្រអ្នកស្រឡាញ់ភេទដូចគ្នា**

||

បុគ្គលមានភេទផ្ទុយ និង/ឬអ្នកដែលមានយេនឌ័រស្របនឹងភេទកំណើតជាអ្នកដែលគាំទ្រ និងតស៊ូមតិទាមទារសិទ្ធិសម្រាប់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា។ អង្គការ និងក្រុមហ៊ុនសាជីវកម្មក៏អាចក្លាយជាអ្នកគាំទ្ររបស់អ្នកស្រឡាញ់ភេទដូចគ្នាផងដែរ។

**មនុស្សគ្រប់រូប**អាចក្លាយជាអ្នកគាំទ្របាន ហើយគំនិតស្ថិតនៅពីក្រោយពាក្យ « សម្ព័ន្ធមិត្ត ឬអ្នកគាំទ្រ» នោះគឺថា៖

*បុគ្គលណាម្នាក់ក៏ដោយ មិនចាំបាច់ទាល់តែជាអ្នកស្រឡាញ់ភេទដូចគ្នា ទើបអាចគាំទ្រសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាបាននោះទេ។*

**ពាក្យគន្លឹះសំខាន់ៗសម្រាប់មេរៀនទី ៩**

- **អ្នកគាំទ្រ៖** បុគ្គលដែលបង្ហាញការយល់ស្រប និងគាំទ្រដល់បុគ្គលណាម្នាក់ ឬក្រុមណាមួយ។
- **អ្នកស្រឡាញ់ភេទផ្ទុយគ្នា៖** បុគ្គលដែលមានដៃគូជាភេទផ្ទុយគ្នា ឬយេនឌ័រផ្ទុយគ្នា។
- **យេនឌ័រស្របនឹងភេទកំណើត៖** បុគ្គលដែលកំណត់អត្តសញ្ញាណយេនឌ័រ និងបង្ហាញយេនឌ័រស្របនឹងភេទពីកំណើតរបស់ពួកគេ។
- **អ្នកស្រឡាញ់ភេទដូចគ្នា៖** ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ អន្តរភេទ និងអ្នកមិនកំណត់អត្តសញ្ញាណយេនឌ័ររបស់ខ្លួន។
- **ភាពអគតិ៖** ជាគំនិតឬមតិមិនគាំទ្រ ឬក៏ការមិនមានជំនឿចំពោះបុគ្គល ឬក្រុមណាមួយដោយមិនផ្អែកលើហេតុផល ឬបទពិសោធជាក់ស្តែង។

### ការបង្ហាញការគាំទ្រក្នុងប្រទេសកម្ពុជា[81]

**អតីតព្រះមហាក្សត្រសម្តេចព្រះនរោត្តម សីហនុ និងព្រះមហាក្សត្រ នរោត្តមសីហមុនី**

នៅក្នុងសេចក្តីថ្លែងការណ៍មួយដែលបង្ហោះនៅក្នុងគេហទំព័ររបស់ព្រះអង្គនៅក្នុងឆ្នាំ២០០៤ អតីតព្រះមហាក្សត្រសម្តេចព្រះនរោត្តមសីហនុ មានព្រះបន្ទូលថា៖

*"ខ្ញុំមិនមែនជាអ្នកស្រឡាញ់ភេទដូចគ្នាទេ ប៉ុន្តែខ្ញុំគោរពសិទ្ធិរបស់បុរសស្រឡាញ់បុរស និងស្ត្រីស្រឡាញ់ស្ត្រី។ នេះមិនមែនជាកំហុសរបស់ពួកគេទេ ប្រសិនបើព្រះមិនបង្កើតឱ្យពួកគេកើតមកបែបនេះ"*[82]។ ទាំងអតីតព្រះមហាក្សត្រ និងព្រះមហាក្សត្របច្ចុប្បន្ន គឺព្រះបាទនរោត្តមសីហមុនី ទ្រង់បានបង្ហាញការគាំទ្រចំពោះការរៀបអាពាហ៍ពិពាហ៍ភេទដូចគ្នា។

**មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(ម.ស.ម.ក)**

ម.ស.ម.ក ជាអង្គការមិនមែនរដ្ឋាភិបាល ដែលផ្តោតការផ្តោតសំខាន់លើវិស័យការងារស្នូលផ្នែកសមភាព និងការមិនរើសអើង។ គម្រោងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទរបស់ ម.ស.ម.ក ត្រូវបានបង្កើតឡើងដើម្បីលើកកម្ពស់ការគោរព និងការយល់ដឹងអំពីសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា។

**មានអង្គការជាច្រើនផ្សេងៗទៀតដែលធ្វើការងារដើម្បីលើកកម្ពស់សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា**

**......**

**អង្គការសហគមន៍ឥន្ទធនូកម្ពុជា (រ៉ក់)**

**អង្គការថែទាំសុខភាពគ្រួសារកម្ពុជា (រ៉ាក់)**

## ៩.២ ហេតុអ្វីយើងត្រូវការអ្នកគាំទ្រ?




អ្នកគាំទ្រអ្នកស្រឡាញ់ភេទដូចគ្នាមានសារៈសំខាន់ណាស់ក្នុងការទប់ស្កាត់ការរើសអើង និងធ្វើឱ្យអ្នកស្រឡាញ់ភេទដូចគ្នាបានទទួលសិទ្ធិស្មើគ្នា។ ប្រជាពលរដ្ឋស្រឡាញ់ភេទដូចគ្នា ជាក្រុមភាគតិច ពិបាកក្នុងការសម្រេចបានការផ្លាស់ប្តូរដោយខ្លួន

[81] នេះមិនមែនជាបញ្ជីទាំងអស់នោះទេ

[82] Alex Spillius, "ខ្ញុំមិនមែនជាអ្នកស្រឡាញ់ភេទដូចគ្នា, ស្តេចមានព្រះជន្មាយុ ៨១ ព្រះវស្សា មានបុត្រ ១៤អង្គ" (*The Telegraph*, ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០០៤) <https://
.telegraph.co.uk/news/worldnews/asia/cambodia/1455293/Im-not-gay-says-81-year-old-monarch-with-14-children.html>.

ឯងបាន។ អ្នកគាំទ្រអាចជាស្ពានរវាងសហគមន៍ ដោយការអធ្យាស្រ័យចំពោះការតស៊ូរបស់ក្រុមភាគតិច និង បង្ហាញពីតម្រូវការសម្រាប់ការផ្លាស់ប្ដូរទស្សនៈរបស់ក្រុមភាគច្រើន[83]។ អ្នកគាំទ្រអាចជួយលើកកម្ពស់ សំឡេង និងបញ្ជូនសាររបស់អ្នកស្រឡាញ់ភេទដូចគ្នា ហើយជាការចូលរួមចំណែកក្នុងការបង្កើតសង្គមមួយ ប្រកបដោយបរិយាកាសស្វាគមន៍ និងបរិយាប័ន្នផងដែរ។

## ៩.៣ តើអ្នកអាចធ្វើជាអ្នកគាំទ្រដោយរបៀបណា?




[83] Tim Gibson, "ហេតុអ្វីយើងត្រូវការអ្នកគាំទ្រជាអ្នកស្រឡាញ់ភេទផ្ទុយគ្នា?" (myGwork) <https://www.mygwork.com/en/my-g-news/why-we-need-straight-allies>.

មានវិធីជាច្រើនដើម្បីក្លាយជាអ្នកគាំទ្រអ្នកស្រឡាញ់ភេទដូចគ្នា។ ជាទូទៅដើម្បីក្លាយជាសម្ព័ន្ធមិត្តដ៏ល្អ និងមានអត្ថប្រយោជន៍ត្រូវធ្វើដូចខាងក្រោម៖

- ស្តាប់ដោយបើកចិត្តទូលាយនូវសំឡេងអ្នកស្រឡាញ់ភេទដូចគ្នា
- អប់រំខ្លួនឯងឱ្យបានយល់អំពីបញ្ហា និងទុក្ខព្រួយរបស់អ្នកស្រឡាញ់ភេទដូចគ្នា
- ទទួលស្គាល់ថាអ្នកទទួលបានបុព្វសិទ្ធិពិសេស ដោយសារអ្នកមានយេនឌ័រស្របនឹងភេទកំណើត និងឋានៈជាអ្នកស្រឡាញ់ភេទផ្ទុយរបស់អ្នក
- ត្រូវយល់ដឹងអំពីបុរេនិច្ឆ័យរបស់ខ្លួន និងព្យាយាមធ្វើការលុបបំបាត់នូវបុរេនិច្ឆ័យទាំងនោះ
- មិនត្រូវសន្មតជាមុនភ្លាមៗថាបុគ្គលដែលអ្នកជួបគឺសុទ្ធតែមានយេនឌ័រស្របនឹងភេទកំណើត ឬជាអ្នកស្រឡាញ់ភេទផ្ទុយនោះទេ
- ត្រូវហ៊ាននិយាយជំទាស់នឹងការនិយាយបែបកំប្លែង ប្រមាថ មាក់ងាយ ឬការប្រើភាសា ឬសេចក្តីថ្លែងណាមួយដែលមានលក្ខណៈវាយប្រហារទៅលើអ្នកស្រឡាញ់ភេទដូចគ្នា និងប្រើសំឡេងរបស់អ្នកដើម្បីចូលរួមតស៊ូមតិគាំទ្រសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា។